ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ ព្រះរាជានៅក្នុងដួងចិត្តខ្មែរ

◆ ការចងក្រងឯកសារក្រោយពីអំពើឃោរឃៅ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៥៥ ខែវិច្ឆិកា ឆ្នាំ២០១២

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៥៥ ខែវិច្ឆិកា ឆ្នាំ២០១២

## មាតិកា

◆ព្រះរាជានៅក្នុងដួងចិត្តខ្មែរ ..........១

**ផ្នែកឯកសារ**

◆ជីវប្រវត្តិរបស់ព្រះមហាវីរក្សត្រ..........៦

◆សម្តេចព្រះប្រមុខរដ្ឋ នរោត្តម សីហនុ ថ្ងៃផ..........១២

◆ចម្លើយសារភាព ស៊ីសុវត្តិ ប៊ុតសារ៉ា ហៅ ច្រឹង ..........១៧

◆កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍រណសិរ្ស ..........២០

◆បញ្ជីឈ្មោះ និងរូបថតអ្នកទោសនៅមន្ទីរស-២១ ..........២៣

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ "ខ្ញុំនៅតែចងចាំ" ..........២៧

◆តំបន់៥គឺជាកន្លែងដែលឪពុកម្តាយ យ៉ុង សម្បត្តិ ..........២៩

◆គ្រូបង្រៀនជាវិស្វករនៃចំណេះដឹង និងសីលធម៌ ..........៣១

◆ប្រវត្តិសាស្ត្រគឺសម្រាប់បទពិសោធន៍ ..........៣៣

◆កោះត្រល់ក្នុងសម័យខ្មែរក្រហម ..........៣៥

◆បរិដ្ឋានជាតិ : ដី ទឹក ភ្លៀង..........៣៧

**ផ្នែកច្បាប់**

◆ការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ ..........៤០

◆សំណុំរឿង០០២/០១ ..........៤៦

**វេទិកាពិភាក្សាសាធារណៈ**

◆ការបងក្រងឯកសារក្រោយពីអំពើឃោរឃៅ ..........៤៧

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ស៊ីវ ធួន ដំណើរឆ្លងកាត់របបខ្មែរក្រហម..........៥៤




**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ :*** សុខ វណ្ណៈ, ចាន ប្រាថ្នា, ឌី ខាំបូលី, លឹម ជ័យទ័ត្ត, ស៊ីវ ធួន, បន ឆរឆីអារី ***អ្នកនិពន្ធនិងស្រាវជ្រាវ :*** ទាវ សារៈមុនិន្ទ និង ស៊ិន សុធីតា ***អ្នកបកប្រែ :*** នូ ស្រស់លក្ខិណា, នង ច័ន្ទមល្លិកា, ភួង ច័ន្ទប្រណិត ***និពន្ធនាយក :*** ឆាំង យុ និង ញាណ សុជាតិ ***ជំនួយការនិពន្ធនាយក :*** សោម ប៊ុនថន ***ក្រាហ្វិកកុំព្យូទ័រ :*** សោម ប៊ុនថន ***គ្រប់គ្រងការចែកផ្សាយ :*** ឆេង វើង Email: dccam@online.com.kh, Homepage: www.dccam.org

# ព្រះរាជានៅក្នុងដួងចិត្តខ្មែរ

កាលពីខែវិច្ឆិកា ឆ្នាំ១៩៩១ ខ្ញុំហើយនិងអ្នកភូមិប្រមាណជាម្ភៃនាក់បានមើលការផ្សាយបន្តផ្ទាល់ស្តីអំពីដំណើរនិវត្តមកកាន់មាតុប្រទេសវិញរបស់សម្តេច នរោត្តម សីហនុ បន្ទាប់ពីព្រះអង្គបានចាកចេញពីទីក្រុងភ្នំពេញអស់រយៈពេលដប់ពីរឆ្នាំ ។ កាលនោះខ្ញុំមានអាយុដប់មួយឆ្នាំ ។ កាលជំនាន់នោះ ភូមិនីមួយៗមិនសូវមានទូរទស្សន៍មើលទេ ផ្ទះណាមួយដែលមានទូរទស្សន៍ មនុស្សម្នាតែងតែជួបជុំគ្នាមើលមិនថាកម្មវិធីអ្វីទេ ឲ្យតែទូរទស្សន៍ផ្សាយកម្មវិធីអ្វីមួយ មនុស្សម្នាមើលទាំងអស់ ។ អំឡុងពេលនៃការផ្សាយបន្តផ្ទាល់នោះ ខ្ញុំហើយនិងអ្នកភូមិបានអង្គុយនៅចំពីមុខទូរទស្សន៍ស-ខ្មៅមួយគ្រឿងដោយភាពរីករាយចំពោះការមកដល់របស់សម្តេច នរោត្តម សីហនុ ប្រៀបដូចជាទស្សនិកជនកំពុងមើលខ្សែភាពយន្តនៅក្នុងរោងកុនដូច្នោះដែរ ។ ព្រះអង្គត្រូវបានទទួលការរាក់ទាក់ដោយប្រជាពលរដ្ឋរាប់ម៉ឺននាក់ដែលនឹករលឹកនិងក្តីអន្ទះសាចង់ឃើញព្រះភ័ក្ត្ររបស់ព្រះអង្គយ៉ាងខ្លាំង ។ អ្នកភូមិរបស់ខ្ញុំខ្លះដែលធ្លាប់រស់នៅសម័យកាលដ៏សុខសាន្តត្រាណនៃរបបសង្គមរាស្ត្រនិយម ពេលដែលសម្តេច នរោត្តម សីហនុ គឺជាប្រមុខរដ្ឋ បាននិយាយពីមាត់មួយទៅមាត់មួយថា “ប្រទេសយើងនិងសុខសាន្តដូចសម័យសង្គមរាស្ត្រនិយមម្តងទៀតមិនខាន” “ព្រះអង្គមានទឹកមុខញញឹមញញែមដូចមុនដដែល” ហើយ “ព្រះអង្គនៅមានកម្លាំងកាយមាំមួន រហ័សរហួនដូចមុនដដែល” ។ ឪពុកម្តាយខ្ញុំ និងអ្នកភូមិខ្ញុំមានចិត្តសប្បាយរីករាយដែលព្រះអង្គយាងមកកាន់មាតុប្រទេសវិញ ។ អ្នកភូមិទាំងអស់មានជំនឿថា ព្រះអង្គនិងនាំមកនូវសន្តិភាព ភាពសាន្តត្រាណនិងការជួបជុំគ្នាវិញ ។ នៅពេលនោះ ខ្ញុំក៏មានចិត្តរីករាយជាមួយអ្នក



សម្តេច នរោត្តម សីហនុ អមព្រះរាជដំណើរដោយឯកឧត្តម ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរដ្ឋកម្ពុជាក្នុងអំឡុងពេលព្រះអង្គយាងនិវត្តមកប្រទេសកម្ពុជា នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩១ ។ រូបថត John Vink/Magnum Photos



ក្បួនដង្ហែរបស់ព្រះប្រមុខរដ្ឋសម្តេចព្រះ នរោត្តម សីហនុ ក្នុងសម័យសង្គមរាស្ត្រនិយម

ភូមិដែរ ។

នៅពេលដែលខ្ញុំមើលការផ្សាយបន្តផ្ទាល់ និងឃើញមនុស្សម្នាជាច្រើនជួបជុំគ្នាដើម្បីទទួលស្វាគមន៍ សម្តេច នរោត្តម សីហនុ នៅពេលនោះ ខ្ញុំគិតថា នោះគឺជាលើកទីមួយហើយដែលខ្ញុំបានឃើញការជួបជុំដោយភាពរីករាយដ៏ធំ និងសំខាន់បំផុត ។ អ្នកភូមិមានចិត្តត្រេកអរដោយក្តីសង្ឃឹមថានឹងទទួលបាននូវសុខសន្តិភាពក្នុងប្រទេសបន្ទាប់ពីប្រទេសជាតិបានជួបប្រទះនូវអំពើកាប់សម្លាប់ដ៏ឃោរឃៅ និងសង្គ្រាមឈ្លបនៃចលនាខ្មែរក្រហមដែលនៅតែបន្តអុកឡុកដល់ភាពសុខសាន្តរបស់អ្នកភូមិជាហូរហែមក ។ ខ្ញុំឮអ្នកភូមិខ្សឹបខ្សៀវគ្នាអំពីសម័យកាលមួយដែលប្រទេសជាតិទទួលបាននូវភាពសុខសាន្តកាលពីទសវត្សរ៍៦០ក្រោមការដឹកនាំរបស់សម្តេច នរោត្តម សីហនុ ។ ដំណាលគ្នានឹងដំណើរមកដល់របស់ព្រះអង្គនោះដែរគឺវត្តមានរបស់ចម្រៀងរបស់លោក ស៊ីន ស៊ីសាមុត ដែលជាអ្នកមានប្រជាប្រិយមួយរូបមុនរបបខ្មែរក្រហមក៏ត្រូវបានចាក់ផ្សាយដែរ ។ ចាប់តាំងពីពេលនោះមកចម្រៀងរបស់ ស៊ីន ស៊ីសាមុត ត្រូវបានចាក់ផ្សាយក្នុងវិទ្យុទូទាំងប្រទេសដែរ ហើយកាសែតចម្រៀងក៏ចាប់ផ្តើមដាក់លក់ ។ ខ្លួនខ្ញុំផ្ទាល់ចាប់ផ្តើមមានអារម្មណ៍ទទួលបាននូវសន្តិភាព ហើយខ្ញុំក៏ចាប់ផ្តើមចូលចិត្តសំនៀងរបស់ ស៊ីន ស៊ីសាមុត តាំងពីពេលនោះមក ។ រហូតមកដល់ថ្ងៃនេះ ខ្ញុំនៅតែចូលចិត្តស្តាប់សំនៀងរបស់គាត់ដដែល ។

ថ្ងៃនោះ នៅពេលយន្តហោះដែលដឹកសម្តេច នរោត្តម សីហនុ ចុះដល់ដី ទូរទស្សន៍បានចាក់ផ្សាយពីភាពអន្ទះសាមិនអាចនៅស្ងៀមបាន និងក្តីរំភើបរបស់ព្រះអង្គនៅពេលព្រះអង្គសម្លឹងមើលតាមបង្អួចយន្តហោះ និងទតឃើញទឹកដីនិងប្រជាជនកម្ពុជាកំពុងរាដៃទៅកាន់ព្រះអង្គនៅក្នុងព្រលានយន្តហោះ ។ បន្តិចក្រោយមក ទ្វារយន្តហោះក៏បានបើកឡើង ប្រៀបដូចជាទ្វារប្រវត្តិសាស្ត្រថ្មីមួយបានបើកដូច្នោះដែរ ។ មនុស្សម្នាទាំងឡាយហោកញ្ជ្រៀវដោយក្តីអំណរ ដែកាន់ទង់ជាតិរបស់រដ្ឋាភិបាលរដ្ឋកម្ពុជា (១៩៨៩-១៩៩៣) ទង់ជាតិរបស់រដ្ឋាភិបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិ (អ៊ុនតាក់) និងរូបព្រះឆាយាល័ក្ខណ៍របស់ព្រះអង្គ ។ ព្រះអង្គត្រូវបានទទួលស្វាគមន៍ដូចទៅអ្វីដែលខ្ញុំបានឃើញការស្វាគមន៍ពីសំណាក់ប្រជាជនកម្ពុជានៅក្នុងភាពយន្តឯកសារកាលពីសម័យសង្គមរាស្ត្រនិយមដូច្នោះដែរ ។

ក្រោយពីចុះពីយន្តហោះ ព្រះអង្គបានឡើងជិះលើរថយន្តគ្មានដំបូលមួយជាមួយឯកឧត្តម ហ៊ុន សែន ដែលជានាយករដ្ឋមន្ត្រីនៃរបបរដ្ឋកម្ពុជា ខណៈពេលដែលប្រជាជនរាប់ម៉ឺនសែននាក់កំពុងតែអបអរសាទរនៅតាមដងផ្លូវចាប់ពីព្រលានយន្តហោះដល់ទ្វារនៃព្រះបរមរាជវាំង ។ ខ្ញុំហើយនិងអ្នកភូមិមើលព្រឹត្តិការណ៍នោះដោយក្តីរំភើប រីករាយ និងក្តីសង្ឃឹមរហូតដល់ចប់កម្មវិធី ។

កាលនោះ ខ្ញុំនៅរៀនថ្នាក់ទី៦ ហើយមិនសូវជាដឹងរឿងច្រើនទេទាក់ទងទៅនឹងសម្តេច នរោត្តម សីហនុ ។ អ្វីដែលខ្ញុំបានដឹងទាក់ទងទៅនឹងព្រះអង្គគឺតាមរយៈឪពុកម្តាយរបស់ខ្ញុំ អ្នកភូមិ ហើយក្រោយមក ដឹងតាមរយៈការរៀនសូត្រនៅសាលារៀន ។ ពីរបីឆ្នាំក្រោយមក ឪពុករបស់ខ្ញុំដែលជាមន្ត្រីរដ្ឋាភិបាល បានយកសៀវភៅជាច្រើនក្បាលមកផ្ទះ រៀបរាប់អំពីព្រះរាជសកម្មភាពនិងសមិទ្ធិផលផ្សេងៗដែលសម្រេចបានកាលពីរបបសង្គមរាស្ត្រនិយមក្រោមកិច្ចដឹកនាំរបស់ព្រះអង្គ ។ ខ្ញុំបានបើកមើលរូបភាពនៅក្នុងសៀវភៅនោះ ហើយខ្ញុំបានឃើញរូបភាពរោងចក្រផលិតរថយន្ត អគារសាកលវិទ្យាល័យ ពិធីសម្ពោធស្ពាន អគារពហុកីឡដ្ឋានជាតិអូឡាំពិកនិងសមិទ្ធិផលផ្សេងៗទៀត ។ រូបភាពទាំងអស់បានបង្ហាញនូវសមិទ្ធិផលដ៏ត្រចះត្រចង់នៅក្នុងប្រទេសកម្ពុជាការការរីកចម្រើននៅក្នុងប្រទេសកម្ពុជា ហើយរូបភាពទាំងអស់នោះទាក់ទាញចំណាប់អារម្មណ៍ខ្ញុំយ៉ាងខ្លាំង ។ រូបភាពមួយចំនួនដែលខ្ញុំបានឃើញនៅក្នុងសៀវភៅទាំងនោះគឺរូបភាពរោងចក្រស្ករសនៅកំពង់ត្រាំក្នុងខេត្តកំពង់ស្ពឺ ដែលជាទីកន្លែងកំណើតរបស់ខ្ញុំ ហើយរោងចក្រនោះក៏នៅមិនឆ្ងាយពីផ្ទះខ្ញុំប៉ុន្មានដែរ ។ ពីរបីឆ្នាំមុន ខ្ញុំទទួលបានសៀវភៅនេះ រោងចក្រស្កសរកំពង់ត្រាំត្រូវបានបំផ្លាញចោលដោយអ្នកភូមិ ដើម្បីគាស់យកដែកនិងឥដ្ឋសម្រាប់យកទៅលក់ ។ មិនដល់ពីរសប្តាហ៍ផង អគាររោងចក្រស្ករសទាំងមូលបានរលំដល់ដីនិងបំផ្លាញចោលទាំងស្រុង ។ រោងចក្រនោះលែងមានរូបរាងទៀតហើយ ។ ពេលដែលខ្ញុំបានឃើញរូបថត ទីកន្លែងនោះកាលពីរោងចក្រនោះកំពុងដំណើរការ ខ្ញុំមានអារម្មណ៍រំភើបផងនិងសោកស្តាយផង ។


សម្តេចព្រះ នរោត្តម សីហនុ ត្រូវបានទទួលស្វាគមន៍ដោយកងយុវនារី

កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១២ កន្លងទៅនេះ ព្រះមហាវីរក្សត្រនរោត្តម សីហនុ បានធ្វើព្រះរាជនិវត្តមកកាន់មាតុប្រទេសវិញ តែពេលនេះ ប្រជាជនកម្ពុជាទាំងអស់រន្ធត់ឥតឧបមា ។ ប្រជាជនកម្ពុជារាប់សែនលាននាក់ស្ទុះស្ទាធ្វើដំណើរទៅព្រលានយន្តហោះ ឈរតម្រៀបគ្នាជាច្រើនជួរតាមផ្លូវ និង ជួបជុំគ្នានៅមុខព្រលានយន្តហោះដើម្បីទទួលព្រះរាជសពរបស់សម្តេចព្រះមហាវីរក្សត្រ ។ ដោយអារម្មណ៍ទុក្ខសោកក្រៃលែង ប្រជាជនកម្ពុជាដែលឈរទទួលព្រះមហាវីរក្សត្រយំសោកនិងកាន់មរណទុក្ខចំពោះការបាត់បង់ដ៏ធំធេងនេះ ។ សំឡេងទ្រហ៊ុំយំរបស់ប្រជាជនកម្ពុជាកាន់តែកងរំពងខ្លាំងឡើងនៅពេលដែលព្រះទីនាំងដែលនាំព្រះរាជសពរបស់ព្រះមហាវីរក្សត្រនរោត្តម សីហនុ ខិតមកកាន់តែជិត ។ នោះគឺជាថ្ងៃទីមួយ នៃការកាន់ទុក្ខដែលមានរយៈពេលប្រាំពីរថ្ងៃនៅទូទាំងប្រទេស ។ ទង់ជាតិត្រូវបង្ហូតត្រឹមពាក់កណ្តាល

ដែលជាសញ្ញានៃការកាន់ទុក្ខទូទាំងប្រទេសចំពោះការសុគតរបស់ព្រះមហាវីរក្សត្រ ។

ក្រោយពីព្រះរាជសពរបស់ព្រះមហាវីរក្សត្រមកដល់ប្រទេសកម្ពុជា គ្រប់ទូរទស្សន៍ទាំងអស់ផ្សព្វផ្សាយអំពីរឿងរ៉ាវរបស់ព្រះមហាវីរក្សត្រនិងអំពីព្រះរាជសកម្មភាពរបស់ព្រះអង្គនិងសមិទ្ធិផលទាំងឡាយ ដែលប្រទេសសម្រេចបានក្រោមការដឹកនាំរបស់ព្រះអង្គ ។ ខ្ញុំបានជួបនិយាយលេងជាមួយម្តាយខ្ញុំ និងអ្នកភូមិរបស់ខ្ញុំម្តងទៀត ក្នុងនោះអ្នកភូមិខ្លះគឺជាអ្នកដែលធ្លាប់មើលការផ្សាយបន្តផ្ទាល់ជាមួយខ្ញុំកាលពីខែវិច្ឆិកា ឆ្នាំ១៩៩១ ។ ពេលនេះ អ្នកភូមិដែលខ្ញុំជួបសុទ្ធតែកាន់ទុក្ខដោយភាពទុក្ខសោកចំពោះការបាត់បង់របស់ព្រះមហាវីរក្សត្រ ។ ទាំងអស់គ្នាចាប់ផ្តើមនិយាយពីសមិទ្ធិផលនានារបស់ព្រះអង្គកាលពីព្រះអង្គជាប្រមុខរដ្ឋនៃប្រទេស ។ អ្នកភូមិទាំងអស់គ្នានិយាយថា ព្រះមហាវីរក្សត្រនរោត្តម សីហនុ គឺជាមេដឹកនាំមួយរូបដែល នៅជិតស្និទ្ធនិងប្រជាជន និងចេះជួយទុក្ខធុរៈប្រជាជន ។ អ្នកខ្លះនិយាយថា គាត់ធ្លាប់បានជួបព្រះមហាវីរក្សត្រនរោត្តម សីហនុ ជាច្រើនលើកច្រើនសារកាលពីទសវត្សរ៍៦០ ។ ម្តាយរបស់ខ្ញុំបានរៀបរាប់ពីពេលមួយដែលគាត់និងម្តាយរបស់គាត់បានជួបព្រះអង្គនៅពេលដែលព្រះអង្គមកធ្វើផ្ទះជូនប្រជាជនក្រីក្រនៅក្នុងភូមិ ។ ម្តាយរបស់ខ្ញុំបាននិយាយថា កាលនោះគាត់បានឃើញអ្នកភូមិម្នាក់ហុចផ្លែទទឹមពីរផ្លែជូនព្រះអង្គ ហើយព្រះអង្គបានហែកផ្លែទទឹមនោះសោយភ្លាមៗ ។ អ្នកភូមិផ្សេងទៀតបានបេះផ្លែឈើថ្វាយព្រះអង្គនៅពេលដែលព្រះអង្គចុះជួយធ្វើស្រែជាមួយអ្នកភូមិ ។ អ្នកភូមិទាំងអស់បានរៀបរាប់ពីសម័យកាលដែលប្រទេសជាតិទទួលនូវភាពសុខសាន្ត ។ ការយាងចូលមរណភាពរបស់ព្រះមហាវីរក្សត្រនរោត្តម សីហនុ បានរំឭកឡើងវិញនូវភាពសុខសាន្តនៅក្នុងសម័យកាលដឹកនាំរបស់ព្រះអង្គ ។

មកដល់ថ្ងៃនេះគឺមានរយៈពេលជាងមួយសប្តាហ៍ហើយដែលយើងទាំងអស់គ្នាដឹងពីដំណឹងមរណភាពរបស់ព្រះមហាវីរក្សត្រនរោត្តម សីហនុ ។ ម្តាយរបស់ខ្ញុំហើយនិងអ្នកភូមិដទៃទៀត



ក្បួនដង្ហែព្រះបរមសពព្រះមហាវីរក្សត្រ នរោត្តម សីហនុ មកប្រទេសកម្ពុជា កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១២ ។

ព្រមទាំងប្រជាជនកម្ពុជាទូទាំងប្រទេសកំពុងតែកាន់ទុក្ខចំពោះមរណភាពរបស់ព្រះមហាវីរក្សត្រ ។ ទូរទស្សន៍កំពុងតែផ្សព្វផ្សាយកម្មវិធីនានាអំពីជីវិតរបស់ព្រះមហាវីរក្សត្រ អំពីការដឹកនាំរបស់ព្រះអង្គ និងសកម្មភាពនានា ។ កាលពីចុងសប្តាហ៍កន្លងទៅនេះម្តាយខ្ញុំបានត្រឡប់មកដល់ផ្ទះវិញនៅម៉ោងប្រាំបីកន្លះយប់ជាមួយអ្នកភូមិខ្ញុំ ។ ពេលដែលខ្ញុំសួរគាត់ថា គាត់មកពីណា គាត់បានឆ្លើយថា គាត់មកពីវត្តនៅក្បែរភូមិដើម្បីចូលរួមបុណ្យសពរបស់ព្រះមហាវីរក្សត្រជាមួយគេ ។ កាលនោះ ម្តាយរបស់ខ្ញុំកំពុងតែស្រក់ទឹកភ្នែកដោយក្តីអាឡោះអាល័យចំពោះព្រះមហាវីរក្សត្រ ។ នៅពីមុខខ្ញុំ ពេលដែលខ្ញុំកំពុងតែសរសេរអត្ថបទមួយនេះទូរទស្សន៍កំពុងតែចាក់ផ្សាយអំពីដំណើរមកសួរសុខទុក្ខរបស់អ្នកតំណាងបរទេសផ្សេងៗដែលបានគោរពវិញ្ញាណក្ខន្ធព្រះមហាវីរក្សត្រ នរោត្តម សីហនុ ។ ព្រះករុណាព្រះបាទព្រះ នរោត្តម សីហមុនី កំពុងទ្រង់កន្សែង ។ គ្រួសាររបស់ខ្ញុំប្រជាជនកម្ពុជាទាំងអស់កំពុងតែមានទុក្ខយ៉ាងក្រៀមក្រំចំពោះការបាត់បង់នេះ ។

ប្រសូតមកប្រកបដោយនូវអំណាចនិងឋាមពលព្រះមហាវីរក្សត្រ នរោត្តម សីហនុ បានបង្ហាញនូវការឈ្លាសវៃដែលធ្វើឲ្យប្រជាជនរបស់ព្រះអង្គស្រឡាញ់ពេញចិត្តយ៉ាងខ្លាំង ។ ព្រះអង្គគឺជាមេដឹកនាំដែលនាំមកនូវឯករាជ្យថ្ងៃទី៩ ខែវិច្ឆិកាឆ្នាំ១៩៥៣ ពីបារាំងក្រោយពីប្រទេសជាតិឋិតក្រោមការគ្រប់គ្រងពីអាណានិគមនិយមបារាំងអស់រយៈពេល៩០ឆ្នាំ ។ ព្រះអង្គគឺជាមេដឹកនាំមួយរូបដែលបានធ្វើការបង្រួបបង្រួមជាតិឲ្យក្លាយជាជាតិខ្មែរតែមួយ ។ ព្រះអង្គបានតុះតារការពារបូរណភាពដែនដីដោយបានទាមទារប្រាសាទព្រះវិហារហើយប្រាសាទនេះត្រូវបានទទួលស្គាល់ជាអន្តរជាតិថាជាកម្មសិទ្ធិរបស់ប្រទេសកម្ពុជា ។ ដោយសារតែសមិទ្ធិផលធំៗដែលព្រះមហាវីរក្សត្រ នរោត្តម សីហនុ បានបន្សល់ទុកទើបកូនចៅបានថ្វាយព្រះនាមថា ជាព្រះអង្គដែលត្រូវបានចងចាំជារៀងរហូតគឺ "បិតាឯករាជ្យជាតិ និងឯកភាពជាតិខ្មែរ" ។

ព្រះមហាវីរក្សត្រនរោត្តម សីហនុ នឹងឋិតនៅក្នុងចិត្តប្រជាជនកម្ពុជាជារៀងរហូត ។ **ញាណ សុជាតិ**



លោក ឆាំង យុ ចូលគាល់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ កាលពីថ្ងៃទី៩ ខែសីហា ឆ្នាំ២០០៣ នៅព្រះបរមរាជវាំង ។

# ជីវប្រវត្តិរបស់ព្រះមហាវីរក្សត្រ នរោត្តម សីហនុ

ព្រះមហាវីរក្សត្រ នរោត្តម សីហនុ ប្រសូតនៅថ្ងៃអង្គារ ទី៣១ ខែតុលា ឆ្នាំ១៩២២ នៅព្រះរាជដំណាក់រាជធានីភ្នំពេញ (បច្ចុប្បន្នស្ថានទូតកូរ៉េខាងជើង) ។

ពីឆ្នាំ១៩៣០ ដល់ឆ្នាំ១៩៤០ ព្រះអង្គបានចូលសិក្សានៅសាលាបឋមសិក្សា FRANÇOIS BAUDOIN(បច្ចុប្បន្នវិទ្យាស្ថានជាតិអប់រំ) និងវិទ្យាល័យព្រះស៊ីសុវត្ថិ រាជធានីភ្នំពេញ ។ បន្ទាប់មក ព្រះអង្គបានបន្តការសិក្សានៅវិទ្យាល័យបារាំង សាសលូឡូបា (CHASSELOUP LAUBAT) នៅព្រៃនគរ (សព្វថ្ងៃក្រុងហូជីមិញ) ។

លុះដល់ខែមេសា ឆ្នាំ១៩៤១ ក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក បានជ្រើសតាំង និងថ្វាយព្រះរាជឋានៈព្រះអង្គជា "ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា" ។ ព្រះអង្គឡើងគ្រងរាជសម្បត្តិនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៤១ ។

នៅឆ្នាំ១៩៤១ ព្រះអង្គបានយាងទស្សនកិច្ចជាលើកដំបូងនៅប្រទេសបារាំងតាមការអញ្ជើញរបស់ប្រធានាធិបតី FELIX GOUIN និងបានជួបឧត្តមសេនីយ៍ សាលដឺហ្គោល នៅទីក្រុង COMLOMBEY ។

ពីឆ្នាំ១៩៤៦ ដល់ឆ្នាំ១៩៤៨ ព្រះអង្គបានបន្តការសិក្សាជាន់ខ្ពស់នៅសាលាអនុវត្តទ័ពសេះ និងទ័ពរថពាសដែក នៅសូមៀរ ប្រទេសបារាំង ។

ក្នុងឆ្នាំ១៩៤៧ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ បានទាមទារឲ្យប្រទេសថៃប្រគល់មកឲ្យកម្ពុជាវិញនូវខេត្តខ្មែរ ដែលប្រទេសថៃបានយកក្នុងអំឡុងពេលសង្គ្រាមលោកលើកទី២ រួមមាន ខេត្តបាត់ដំបង សៀមរាប កំពង់ធំ និងខេត្តស្ទឹងត្រែង ។

នៅក្នុងឆ្នាំ១៩៤៩ ព្រះអង្គបានទាមទារឲ្យបារាំងបញ្ឈប់សន្ធិសញ្ញាអាណាព្យាបាលដែលបានចុះព្រះហស្តលេខានៅឆ្នាំ១៨៦៣ និង១៨៨៤ ។




សម្តេចព្រះ នរោត្តម សីហនុ នៅក្នុងសន្និសីទកាសែតអន្តរជាតិ

ក្នុងឆ្នាំ១៩៤៩ដដែល ព្រះអង្គបានឡាយព្រះហស្ថលេខាលើសន្ធិសញ្ញាឯករាជ្យដែលប្រទេសបារាំងព្រមទទួលស្គាល់តាមផ្លូវច្បាប់នូវឯករាជ្យរបស់ព្រះរាជាណាចក្រកម្ពុជា ។

នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ព្រះអង្គបានទាមទារឯករាជ្យបានទាំងស្រុងពីសាធារណរដ្ឋបារាំង ហើយព្រះអង្គត្រូវបានថ្វាយព្រះកិត្តិនាមព្រះអង្គជា "ព្រះមហាវីរបុរសជាតិ ព្រះបិតាឯករាជ្យជាតិ" ។

នៅឆ្នាំ១៩៥៤ ព្រះអង្គបានបញ្ជូនគណៈប្រតិភូជាតំណាងរបស់ព្រះអង្គទៅចូលរួមនៅក្នុងសន្និសីទអន្តរជាតិស្តីពីបញ្ហាឥណ្ឌូចិននៅទីក្រុងហ្សឺណែវក្នុងឋានៈជារដ្ឋឯករាជ្យ ឯកភាពជាតិ ។

នៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៥៥ ព្រះអង្គបានដាក់រាជ្យថ្វាយព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សុរាម្រិត ជាព្រះរាជបិតា ។ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រិត បានប្រទានព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ នូវព្រះបរមងារជា"សម្តេចព្រះឧបយុវរាជនៃព្រះរាជាណាចក្រកម្ពុជា" ។

ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៥៥ សម្តេច នរោត្តម សីហនុ បានបង្កើតចលនាសង្គមរាស្ត្រនិយមដែលមានគណបក្សជាច្រើនចូលរួមក្នុងចលនានេះ ។

ពីថ្ងៃទី១៨ ដល់ថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៥៥ ព្រះអង្គបានយាងចូលរួមក្នុងសន្និសីទកំពូលអាហ្វ្រិក-អាស៊ីលើកទី១ នៅទីក្រុងបានឌុង ប្រទេសឥណ្ឌូណេស៊ី ហើយនៅទីនោះ ព្រះអង្គបានប្រកាសពីនយោបាយអព្យាក្រឹតរបស់ប្រទេសព្រះអង្គ ។

ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៥៥ ព្រះអង្គបានទទួលមហាជោគជ័យក្នុងការបោះឆ្នោតសភាជាតិ ហើយព្រះអង្គបានទទួលព្រះរាជឋានៈជានាយករដ្ឋមន្ត្រី ។

ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៥៥ ព្រះអង្គបានដឹកនាំប្រទេសកម្ពុជាចូលជាសមាជិកអង្គការសហប្រជាជាតិ ។

នៅឆ្នាំ១៩៥៦ នៅប្រីយ៉ូនី នៃសាធារណរដ្ឋសហព័ន្ធសង្គមនិយមយូហ្គោស្លាវី ព្រះអង្គបានឡាយព្រះហស្ថលេខាលើធម្មនុញ្ញនៃចលនាមិនចូលបក្សសម្ព័ន្ធ ហើយព្រះអង្គបានក្លាយជាបិតាស្ថាបនិកទី៥នៃចលនានេះ ។

នៅខែកុម្ភៈ ឆ្នាំ១៩៥៦ ព្រះអង្គបានយាងទៅបំពេញទស្សនកិច្ចជាផ្លូវរដ្ឋនៅសាធារណរដ្ឋប្រជាមានិតចិន និងបានជួបជាមួយប្រធាន ម៉ៅ សេទុង និងថ្នាក់ដឹកនាំចិនជាច្រើនរូបទៀត ។



សម្តេចព្រះ នរោត្តម សីហនុ និង ជូ អេនឡាយ

ព្រះអង្គបានឡាយព្រះហស្ថលេខាលើសេចក្តីប្រកាសរួមស្តីពី “មិត្តភាពកម្ពុជាចិន” ។

នៅឆ្នាំ១៩៦០ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រិត ទ្រង់សោយព្រះទិវង្គត ពេលនោះ សម្តេចព្រះ នរោត្តម សីហនុ ត្រូវបានសមាជិកសភាខ្មែរសម្រេចជាឯកច្ឆន្ទជ្រើសតាំងព្រះអង្គជា “ព្រះប្រមុខរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា” ។

នៅខែកញ្ញា ឆ្នាំ១៩៦០ នៅមហាសន្និបាតអង្គការសហប្រជាជាតិ សម្តេច នរោត្តម សីហនុ បានលើកឡើងនូវផែនការបង្កើតអាស៊ីអាគ្នេយ៍ជាតំបន់អាព្យាក្រឹត ។

ចាប់ពីខែឧសភា ឆ្នាំ១៩៦១ ព្រះអង្គបានបំពេញព្រះរាជបេសកកម្មនយោបាយការទូតទាមទារប្រាសាទព្រះវិហារពីប្រទេសថៃ ហើយតុលាការយុត្តិធម៌អន្តរជាតិនៅទីក្រុងឡាអេបានសម្រេចប្រគល់ប្រាសាទព្រះវិហារមកឲ្យខ្មែរវិញនៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ១៩៦២ ។

នៅខែវិច្ឆិកា ឆ្នាំ១៩៦១ ព្រះអង្គបានយាងចូលរួមក្នុងសន្និសីទកំពូលលើកទី១ នៃចលនាមិនចូលបក្សសម្ព័ន្ធនៅបែលក្រាដ ប្រទេសយូហ្គោស្លាវី ដែលមាន២៩ប្រទេសចូលរួម ។

នៅខែមិថុនា ឆ្នាំ១៩៦៤ ឧត្តមសេនីយ៍ សាល ដឺហ្គោល ប្រធានាធិបតីសាធារណរដ្ឋបារាំងបានរៀបចំបដិសណ្ឋារកិច្ចជាឱឡារិកថ្វាយសម្តេច នរោត្តម សីហនុ នៅទីក្រុងប៉ារីស ។ នៅទីនោះ ប្រធានាធិបតីបារាំងបានទទួលនូវសំណើរបស់កម្ពុជាស្តីពីការទទួលស្គាល់អព្យាក្រឹតនៃព្រះរាជាណាចក្រកម្ពុជា ។

នៅចុងខែសីហា និងដើមខែកញ្ញា ឆ្នាំ១៩៦៦ សម្តេច នរោត្តម សីហនុ បានរៀបចំបដិសណ្ឋារកិច្ចទទួលជាឱឡារិក លោកឧត្តមសេនីយ៍ សាល ដឺហ្គោល ប្រធានាធិបតីនៃសាធារណរដ្ឋបារាំង ដែលបានមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ។ នៅ


សម្តេចព្រះ នរោត្តម សីហនុ និងប្រធានាធិបតីសហរដ្ឋអាមេរិក រ៉ូណាល់ រីហ្គេន នៅសេតវិមាន កាលពីខែតុលា ឆ្នាំ១៩៨៨ ។

ក្នុងសុន្ទរកថាថ្លែងនៅពហុកីឡដ្ឋានជាតិអូឡាំពិក លោកប្រធានាធិបតីបានគាំទ្រព្រះរាជាណាចក្រកម្ពុជាដែលបានការពារឯករាជ្យ បូរណភាពទឹកដី អព្យាក្រឹត និង សន្តិភាពរបស់ខ្លួន ។



ពីថ្ងៃទី២៦ ខែវិច្ឆិកាដល់ថ្ងៃទី៦ ខែធ្នូឆ្នាំ១៩៦៦ សម្តេចព្រះនរោត្តម សីហនុ បានយាងជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងឱកាសព្រះរាជពិធីបើក និងបិទការប្រកួតកីឡាហ្គាណេហ្វូអាស៊ីលើកទី១ នៅពហុកីឡដ្ឋានជាតិអូឡាំពិក ។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក្នុងពេលដែលព្រះអង្គកំពុងបំពេញព្រះរាជទស្សនកិច្ចជាផ្លូវការនៅសហភាពសូវៀត លន់ លន់ បានធ្វើរដ្ឋប្រហារទម្លាក់ព្រះអង្គចេញពីអំណាច ។ សាធារណរដ្ឋខ្មែររបស់ លន់ នល់ ត្រូវបានបង្កើតឡើងនៅខែតុលា ឆ្នាំ១៩៧០ ។

នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ សម្តេចព្រះ នរោត្តម សីហនុ បានគង់ជាព្រះប្រធានចលនាតស៊ូកម្ពុជា «រណសិរ្សរួបរួមជាតិកម្ពុជា» ព្រមជាមួយនោះក៏បានបង្កើត «រដ្ឋាភិបាលរួបរួម



សម្តេចព្រះ នរោត្តម សីហនុ យាងថ្វាយព្រះភ្លើងជ័យនៅក្នុងឱកាសព្រះរាជពិធីបុណ្យឯករាជ្យជាតិ ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០០៩



ជាតិកម្ពុជា» ដែរ ។

នៅខែមេសា ឆ្នាំ១៩៧០ នៅកង់តុង សាធារណរដ្ឋប្រជាមានិតចិន សម្តេចព្រះ នរោត្តម សីហនុ បានផ្តួចផ្តើមសន្និសីទកំពូលប្រជាជនឥណ្ឌូចិន ដែលមានការចូលរួមពីប្រទេសកម្ពុជា ពីសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ដឹកនាំដោយ ផាំ វ៉ាន់ដុង ពីរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង ដឹកនាំដោយ ង្វៀង ហ៊ុវថ និង ពីប្រទេសឡាវដឹកនាំដោយព្រះអង្គម្ចាស់ សុផានុវង្ស ។ ភាគីទាំងអស់បានប្រកាសជាឱឡារិកថា ប្រទេសរបស់ខ្លួនទទួលស្គាល់និងគោរពជាដរាបនូវបូរណភាពទឹកដីក្នុងព្រំដែនបច្ចុប្បន្នរបស់កម្ពុជា ។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពប្រជាជនរំដោះជាតិនៃរណសិរ្សរួបរួមជាតិកម្ពុជាដណ្តើមបានជ័យជម្នះទាំងស្រុងនៅកម្ពុជា ។ “កម្ពុជាប្រជាធិបតេយ្យ” ត្រូវបានបង្កើតឡើងដែលមានសម្តេចព្រះ នរោត្តម សីហនុ ជាព្រះប្រធាន ។ ប៉ុន្តែនៅខែមេសា ឆ្នាំ១៩៧៦ ព្រះអង្គបានលាលែងពីព្រះប្រធាននៃកម្ពុជាប្រជាធិបតេយ្យ ហើយត្រូវក្រុមខ្មែរក្រហមឃុំឃាំងព្រះអង្គនិងសម្តេចព្រះរាជអគ្គមហេសី ព្រមទាំងធ្វើគត់ព្រះរាជបុត្រនិងរាជវង្សមួយចំនួនទៀត ។

នៅឆ្នាំ១៩៨២ សម្តេចព្រះ នរោត្តម សីហនុ បានគង់ជាព្រះប្រធានកម្ពុជាប្រជាធិបតេយ្យលើកទី២ ។ ពីឆ្នាំ១៩៨២ ដល់ឆ្នាំ១៩៩០ ព្រះអង្គគង់ជាព្រះប្រធានចលនាតស៊ូជាតិកម្ពុជា ។

នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៩១ សម្តេចព្រះ នរោត្តម សីហនុ បានប្រកាសជាឱឡារិកនូវក្រុមប្រឹក្សាជាតិជាន់ខ្ពស់ដើម្បីទទួលស្គាល់ការបញ្ឈប់ជាបណ្តោះអាសន្ននូវការឈប់បាញ់គ្នានៅក្នុងប្រទេសកម្ពុជាទាំងមូលនិងបញ្ឈប់ការផ្តល់ជំនួយយោធាពីប្រទេសដទៃដល់កងទ័ពកម្ពុជាទាំងបីភាគី ។

នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩១ សម្តេចព្រះ នរោត្តម សីហនុ ព្រះអង្គបានយាងចាកចេញពីប្រធាននៃកម្ពុជាប្រជាធិបតេយ្យ និងចលនាតស៊ូជាតិកម្ពុជា ហើយព្រះអង្គត្រូវបានសមាជិក ១១រូប នៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជាជ្រើសតាំងជាឯកច្ឆន្ទជាព្រះប្រធាន “អព្យាក្រឹត” នៃក្រុមប្រឹក្សានេះ ។

នៅថ្ងៃ២៣ ខែតុលា ឆ្នាំ១៩៩១ នៅទីក្រុងប៉ារីស សម្តេចព្រះ នរោត្តម សីហនុ បានឡាយព្រះហស្តលេខា “លើកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមនៃជម្លោះកម្ពុជា” ជាមួយសមាជិកនៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា១១រូបទៀត ជាមួយតំណាងរដ្ឋាភិបាល១៨ប្រទេស និងអគ្គលេខាធិការអង្គការ



សហប្រជាជាតិ ។

នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩១ សម្តេចព្រះ នរោត្តម សីហនុ យាងនិវត្តមកកាន់រាជធានីភ្នំពេញវិញ ។

នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ សម្តេចព្រះ នរោត្តម សីហនុ បានឡើងគ្រងរាជ្យសម្បត្តិជាថ្មី ជា "ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា" ហើយព្រះអង្គបានឡាយប្រហត្ថលេខាលើព្រះរាជក្រមប្រកាសឲ្យប្រើប្រាស់ជាផ្លូវការនូវរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

នៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៤ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ បានដាក់រាជ្យសម្បត្តិ ដោយសារមូលហេតុព្រះរាជសុខភាពរបស់ព្រះអង្គ ដែលក្រោយមកពេទ្យរកឃើញថា ព្រះអង្គមានជំងឺមហារីក ជំងឺលើសឈាម ជំងឺទឹកនោមផ្អែម និងជំងឺជាច្រើនប្រភេទទៀត ។



ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ បានយាងចូលព្រះទិវង្គតនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២ ដោយជំងឺគាំងបេះដូងនៅមន្ទីរពេទ្យក្រុងប៉េកាំងនៃសាធារណរដ្ឋប្រជាមានិតចិន ក្នុងព្រះជន្មាយុ៨៩ព្រះវស្សា ។

**សោម ប៊ុនថន និង ស៊ិន សុធីតា**

# សម្តេចព្រះប្រមុខរដ្ឋ នរោត្តម សីហនុ ថ្លែងទៅកាន់សភាទាំងពីរ

## *ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៦៧ សម្តេច នរោត្តម សីហនុ ថ្លែងអំពីបញ្ហាខ្មែរក្រហមនិងខ្មែរខៀវ*

### បញ្ហាផ្ទៃប្រទេសអំពីខ្មែរក្រហម និងខ្មែរខៀវ

ដូចសហជីវិន-សហជីវិនីជ្រាបស្រាប់បញ្ហាដែលគួរព្រួយបារម្ភជាងគេបញ្ហាសំឡូត ។

ឥឡូវនេះបញ្ហាសំឡូតនោះក៏បានស្រាយហើយ ។ ដោយសារការខ្នះខ្នែងរបស់ខ្ញុំ និងរបស់សហជីវិនជាអ្នកជាតិនិយមពិតប្រាកដដែលជួយខ្ញុំ ពួកអ្នកស្រុកដែលបានទទួលបាបគ្រោះដោយពាក្យឃោសនារបស់ខ្មែរក្រហមបានភ្ញាក់ស្មារតីថា ខ្លួនចាញ់បោកគេជាពិតប្រាកដពីពេលមុន ។ ជនរួមជាតិយើងក្នុងតំបន់រំដោះនោះទាំងប៉ុន្មានបានធ្វើសេចក្តីសច្ចាប្រណិធានថាអំណឹះតទៅនឹងតាំងខ្លួនជាពលរដ្ឋស្មោះត្រង់បំផុតចំពោះរាជបល្ល័ង្កនិងសង្គម ព្រមទាំងតាំងចិត្តថានឹងពិរចារណាមើលឲ្យច្បាស់លាស់សិនមុននឹងជឿតាមគេ ។ កូនចៅទាំងនោះ បាននាំគ្នាមកគាល់ខ្ញុំយ៉ាងសន្ធឹកសន្ធាប់ពេកទៅទាល់តែខ្ញុំបញ្ឈាក់ជូនហើយបញ្ឈាក់ទៀតថា សុំកុំឲ្យអញ្ជើញមកភ្នំពេញដើម្បីនឹងសំដែងនូវសេចក្តីស្នេហាយ៉ាងខ្លាប់ខ្លួននិងសេចក្តីស្មោះត្រង់របស់ខ្លួនចំពោះខ្ញុំទៀត ពីព្រោះការធ្វើដំណើរពីស្រុកភូមិមករាជធានីភ្នំពេញនាំឲ្យគេខាតពេលវេលានិងសោហ៊ុយច្រើនណាស់ ។

ក្នុងអំឡុងប៉ុន្មានខែក្រោយនេះ នៅតាមខេត្តនានាទាំងអស់ ខ្ញុំបានទទួលទទួលនូវភ័ស្តុតាងយ៉ាងរំភើបហើយដ៏ច្រើនលើសលប់ សម្តែងឲ្យឃើញនូវស្មារតីភក្តីរបស់ប្រជារាស្ត្រយើង ចំពោះឧត្តមគតិនៃសង្គម ។ នៅគ្រប់ទិសទីមហាចលនាជាតិ យើងបានទទួលសេចក្តីអបអរសាទរយ៉ាងគ្រេកគ្រអាលបំផុត ហើយខ្ញុំពុំដែលបានជួបនឹងអ្នកណាម្នាក់ដែលប្រកែកពុំព្រមជួយការពារនូវឧត្តមគតិជាតិ និងពុំព្រមជួយស្ថាបនាប្រទេសជាតិឡើយ ។ បើបែបនេះ ចុះហេតុដូចម្តេចបានជាពួកខ្មែរវង្វេងបឹងមួយក្តាប់តូចចង់ពន្លិចនូវលទ្ធិជាតិនិងអង្គការរដ្ឋនៃជាតិខ្លួនព្រមទាំងចង់បំផ្លាញនូវឯកភាពជាតិដែលនៅកម្លាំងធំបំផុតរបស់យើងក្នុងសកលលោកដ៏សាហាវនេះដល់ម្ល៉េះ? ពីព្រោះនៅក្នុងចំណោមជនរួមជាតិយើង មានមនុស្សប្រកបដោយមហិច្ឆតាផ្ទាល់ខ្លួន ព្រមទាំងមានជំនឿស៊ប់ចំពោះមនោគមវិជ្ជាបរទេសមួយ ហើយបណ្តោយខ្លួនឲ្យក្បត់មាតុប្រទេសរបស់ឯងដែលខ្លួនអួតអាងថា ខ្លួនស្រឡាញ់ព្រមទាំងក្បត់ប្រជារាស្ត្រដែលខ្លួនហ៊ានអះអាងថាបម្រើទៅវិញ ។ អំពើទាំងនោះបានធ្វើឲ្យខ្ញុំក្រៀមក្រំជារាល់ថ្ងៃ ខ្ញុំដែលទទួលបន្ទុកខុសត្រូវចំពោះកិច្ចទ្រទ្រង់ឯករាជ្យ និងសន្តិភាព នៅក្នុងផ្ទៃនៃរដ្ឋកម្ពុជរដ្ឋនិងចំពោះសុភមង្គលរបស់ជនរួមជាតិយើងចំនួន៦លានកន្លះ ។

ពួកខ្មែរក្រហមដែលចេះតែបន្តនូវសកម្មភាពធ្វើវិទ្ធង្សនារបស់ខ្លួន ឥតឈប់ឈរជាអាទិ៍ ក្នុងចំណោមយុវជនយើងដោយអយុត្តិធម៌យ៉ាងជាក់ស្តែងបំផុត ។ ចំណែកខ្លួនខ្ញុំ ខ្ញុំពុំអាចបណ្តោយឲ្យពួកនេះចេះតែរំលោភលើសុទ្ធចិត្តឬលើគំនិតជឿគេរបស់យុវជនទាំងនោះប្រយោជន៍ដើម្បីដឹកនាំឲ្យធ្លាក់ខ្លួនក្នុងមាគ៌ានយោបាយដែលផ្ទុយនឹងឧត្តមប្រយោជន៍ ផ្ទុយនឹងឧត្តមគតិរបស់ប្រជារាស្ត្រអ្នកជាតិនិយមនោះបានតាមចិត្តទេ ។ លទ្ធិកុម្មុយនីស្តដែលនាំចូលមកពីក្រៅ គ្មាននាំអ្វីដទៃឲ្យបានចម្រើនល្អលាស់គ្រាប់បើជាងនេះក្រៅអំពីការរំលាយនូវអត្តសញ្ញាណជាតិគឺការបាត់បង់នូវឯករាជ្យជាតិតែប៉ុណ្ណោះ ។

ខ្ញុំបានដោបញ្ឈាក់ជាច្រើនលើកច្រើនគ្រាមកហើយថាខ្ញុំមិនមែនប្រឆាំងនឹងលទ្ធិកុម្មុយនីស្ត មុនទទួលការពិសោធន៍នោះទេ ឲ្យតែលទ្ធិលេចចេញពីឆន្ទះរបស់ប្រជាពលរដ្ឋពិតៗ ។

នៅហាណូយ គេកាន់លទ្ធិកុម្មុយនីស្តយៀកណាម នៅប៉េកាំងលទ្ធិកុម្មុយនីស្តចិន នៅព្យុងយ៉ាងលទ្ធិកុម្មុយនីស្តកូរ៉េ នៅឡាហាវ៉ាន លទ្ធិកុម្មុយនីស្តគុយបា ។ ឯលទ្ធិដែលខ្មែរក្រហមចង់បង្ខំឲ្យភ្នំពេញកាន់ គឺលទ្ធិកុម្មុយនីស្តមិនមែនខ្មែរដែលនឹងដឹកនាំឲ្យប្រទេសកម្ពុជាទទួលនូវការប្រមាថមើលងាយ ឬការចំអក ឡក

ឡើយយ៉ាងជូរចត់ អំពីសំណាក់នៃសាកលលោកទាំងមូល ។ ក៏ប៉ុន្តែពួកខ្មែរក្រហមទាំងនោះសុទ្ធសឹងជាសត្វលោកដែលសូត្រនូវមេរៀនដែលខ្លួនបានទន្ទេញយ៉ាងចាំមាត់ពីលោកគ្រូរបស់ខ្លួនមក ហើយដែលឥតរវល់ដល់ការរស់រានមានអាយុនៃប្រទេសជាតិ នឹងដល់សុភមង្គលនៃប្រជាពលរដ្ឋយើងសូម្បីបន្តិចឡើយ ។

ដូចខ្ញុំបានជម្រាបរួចមកហើយ ខ្ញុំគ្មានញញើតនឹងចាត់វិធានការយ៉ាងម៉ឺងម៉ាត់ជាការចាំបាច់ លើពួកចង្រៃដល់សង្គមជាតិយើងនោះទេ ។ ខ្ញុំបានក្រើនរំឭកឥតឈប់ឈរសុំឲ្យពួកទាំងនេះបម្រើប្រជារាស្ត្រដោយពិតប្រាកដ តាមរយៈនៃសង្គមរាស្ត្រនិយមឬយ៉ាងហោចណាស់ក៏ត្រូវគោរពច្បាប់ជាតិទៅចុះៗ ក៏ប៉ុន្តែពួកអកុសលទាំងនេះបានធ្វើឲ្យខ្លួននិរាសចេញពីសហគមន៍ជាតិដោយខ្លួនឯង ដោយស្ម័គ្រចិត្តដើរតាមពួកគ្រូអាចារ្យបរទេសរបស់គេជាដាច់ខាត ។ ហេតុនេះសុំពួកទាំងនេះកុំឲ្យងឿងឆ្ងល់ចំពោះផលកម្មដែលខ្លួនបានទទួលសោះ ។

រីឯចំណែកខាងពួកខ្មែរខៀវវិញ ដែលប្ញងស្ញងចង់ឲ្យប្រទេសយើងក្លាយខ្លួនជាប្រទេសចំណុះរបស់សហរដ្ឋអាមេរិកនោះ ក៏គួរឲ្យយើងស្អប់ខ្ពើមដូចពួកខ្មែរក្រហមដែរ ។ ពួកខ្មែរខៀវនេះផ្ញើអនាគតរបស់ខ្លួនលើពួកខ្មែរសេរីក្បត់ជាតិដែលនឹងបានឡើងកាន់អំណាចនៅពេលណាដែលពួកព្រៃនគរ និងបាងកក ជាបច្ចាមិត្តនៃយើង បានច្បាំងឈ្នះយើងដោយសារសហរដ្ឋអាមេរិកជួយជាកម្លាំង ។ ទម្រាំដល់ពេលនោះ ពួកទាំងនោះគិតតែបន្តុះបង្អាប់ និងចាក់រុកឲ្យពួកកាសែតចក្រពត្តិនិយមបន្តុះបង្អាប់សង្គមនិងសមិទ្ធិផលដែលសង្គមបានធ្វើកើតឡើង ហើយនិងឃោសនាមួលបង្កាច់ខ្លួនខ្ញុំ ។ ក៏ប៉ុន្តែ ខ្ញុំសូមជម្រាបដោយត្រង់ថាពួកខ្មែរខៀវនេះ ពុំអាចធ្វើឲ្យយើងទទួលគ្រោះថ្នាក់អ្វីបានទេ ពីព្រោះក្រៅពីក្រុមដ៏តូចនៃពាណិជ្ជករចិត្តអាក្រក់លោភលន់ពន់ប្រមាណចេញគ្មានអ្នកណាគេជឿតាមទេ ។ ម្យ៉ាងទៀត មកពីជនជាតិខ្មែរយើងជាជនជាតិប្រឆាំងនឹងអាណានិគមនិយមជាងគេបំផុត ។

អាស្រ័យហេតុនេះ វិបត្តិនយោបាយ គ្មានជិតជាមអ្វីបន្តិចដល់ប្រជារាស្ត្រយើងទេ ។ ប្រជារាស្ត្រយើងនៅតែស្មោះត្រង់ចំពោះរាជបល្ល័ង្កជាតិ ចំពោះព្រះពុទ្ធសាសនា ចំពោះសង្គមនិយមព្រះពុទ្ធសាសនាគឺថា ចំពោះសង្គមយើង ដូចពីពេលមុនជាដរាប ។ ក៏ប៉ុន្តែខ្ញុំសុំឲ្យអស់ទាំងសហជីវិនជាអ្នកជាតិនិយម ប្រយ័ត្នឲ្យមែនទែនចំពោះវិទ្ធង្សនានេះ អាចគំរាមកំហែងដល់សន្តិភាពខាងផ្លូវចិត្តខាងនយោបាយរបស់ជាតិយើងដែលញ៉ាំងឲ្យខ្មែរយើងបានថ្ងៃថ្នូររហូតមកដល់ទល់ពេលនេះនៅឡើយ» ។

## បញ្ហាសេដ្ឋកិច្ចនិងសង្គមកិច្ច

ក្នុងវិស័យពង្រីកសេដ្ឋកិច្ចនិងសង្គមកិច្ច យើងចេះតែលូតលាស់ទៅមុខជានិច្ច ទោះបីយើងមានការលំបាកខាងហិរញ្ញវត្ថុក៏ដោយ ល្បឿននៃការស្ថាបនាផ្លូវថ្នល់ សាលារៀន គិលានដ្ឋាន និងមន្ទីរពេទ្យគ្មានថយទេ គឺមានតែលឿនថែមទៀត ។ ក្នុងពេលនេះ ខ្ញុំរកតែពេលតែនឹងទទួលសេចក្ដីអញ្ជើញរបស់ខេត្តនានាទៅសម្ពោធសមិទ្ធិផលថ្មីៗពុំបានអស់ទេ ។ ការនេះបង្ហាញឲ្យឃើញច្បាស់ថា សង្គមមិនមែនជិតដាច់ខ្យល់ ដូចពួកបន្តុះបង្អាប់យើងខិតខំផ្សាយនោះទេ ។

ការរៀបខាងផ្នែកខស្សរាហកម្មឲ្យមានរបៀបរៀបរយឡើងកំពុងតែប្រព្រឹត្តទៅជាលំដាប់ ។ សហគ្រាសរដ្ឋបានទទួលការគ្រប់គ្រងមានរបៀបរៀបរយឡើង ហើយសង្ឃឹមថានឹងបានចំណេញជាងពេលមុន ។ ឯខាងរោងចក្រឯកជនយើងត្រូវបោសសម្អាតពីព្រោះនៅមានរោងចក្រខ្លះដែលស្រូបយករូបិយប័ណ្ណបរទេសអស់ជាច្រើន ដោយពុំសូវសមហេតុផល ហើយមានលក្ខណៈពុំស្របនឹងលក្ខខណ្ឌនៃការផ្ដល់ផលិតផលតាមធម្មតាផង ។ ហេតុនេះ ខ្ញុំសង្ឃឹមថាសហជីវិនសហជីវិនី អ្នកតំណាងរាស្ត្រនិងទីប្រឹក្សានៃព្រះរាជាណាចក្រកម្ពុជាដែលទទួលពាក្យអង្វរករពីមជ្ឈដ្ឋានសេដ្ឋកិច្ចខ្លះសុំឲ្យធ្វើអន្តរាគមន៍ មុខជានឹងមានសេចក្ដីប្រុងប្រយ័ត្នមែនទែនជាមិនខាន ។

ខាងរបរកសិកម្មវិញ គឺឃើញថាមានសេចក្ដីកក់ក្ដៅច្រើនជាងដើម ។ បើគ្មានហេតុភេទអ្វីចម្លែកទេ យើងសង្ឃឹមថានឹងបានផលស្រូវជាច្រើនជាងឆ្នាំមុន ។ ក្នុងឱកាសនេះ ខ្ញុំសូមថ្លែងនូវសេចក្ដីសរសើរជាអតិបរមាចំពោះសហជីវិន សហជីវិនីខ្ញុំ ដែលបានផ្ដល់នូវជំនួយផ្ទាល់ខ្លួនដល់មណ្ឌលបោះឆ្នោតរបស់ខ្លួន ។ យើងនៅមានកិច្ចការធ្វើជាច្រើន ដើម្បីដោះស្រាយនូវបញ្ហាទឹក បញ្ហាពូជស្រូវ និងបញ្ហាដី ។ អ្នកតំណាងរាស្ត្រនិងទីប្រឹក្សានៃព្រះរាជាណាចក្រកម្ពុជាមានលទ្ធភាពនិងជួយពង្រីកកសិកម្មយើង

បានជាពិតប្រាកដដោយរួបរួមយ៉ាងជិតស្និទ្ធជាមួយនឹងពួករដ្ឋបាល និងពួកបច្ចេកទេសយើង ។ ហេតុនេះខ្ញុំសុំឲ្យសហជីវិនសហជីវិនីគ្រប់រូបមេត្តាជួយរាជរដ្ឋាភិបាលនិងខ្លួនខ្ញុំក្នុងកិច្ចការជាមូលដ្ឋាននេះ គឺជួយបង្កើនផលិតផលនិងជួយឲ្យសេដ្ឋកិច្ចជាតិមានជំហររឹងប៉ឹងមែនទែនឡើង ។

## យើងត្រូវពឹងផ្អែកតែលើខ្លួនយើង

ពេលនេះជាងពេលណាៗទាំងអស់យើងត្រូវមានករណីកិច្ចសង្ឃឹមលើខ្លួនយើងតែម្យ៉ាងប៉ុណ្ណោះ ។ ប្រជាជាតិយើងត្រូវតម្កល់ចិត្តឲ្យនឹងកាលណាមិត្តបរទេសគេបន្ថយជំនួយ ឬក៏ផ្តាច់ជំនួយទាំងស្រុងរបស់គេដល់ប្រទេសយើង ។ ពីព្រោះយើងមិនត្រូវស្រឡាញ់ជំនួយទាំងនោះរហូតដល់ទៅសុខចិត្តខូតខាតឯករាជ្យជាតិ និងបាត់បង់សន្តិភាពជាតិទេ ។

ក្នុងសម័យនេះ ពួកយក្សដែលជានិមិត្តរូបយ៉ាងរបឹងរឹងរូសនៃមនោគមវិជ្ជាពីរកំពុងតែតទល់គ្នាដែលជាហេតុអាចនាំឲ្យប្រជាពលរដ្ឋទាំងអស់ក្នុងសកលលោកដ៏អកុសលវិនាសអន្តរាយបាន ។ ហេតុនេះការដែលពឹងលើជំនួយគេដោយឥតអៀនខ្មាសនិងប្រទាញប្រទង់ឲ្យយើងចូលក្នុងបក្សពួកខាងនេះឬខាងនោះជាដាច់ខាតគឺនាំឲ្យមានវិទ្ធង្សនា និងការវិនាសអន្តរាយដល់ប្រទេសយើង ។ ជំនួយបរទេសដែលប៉ះពាល់ដល់ឯករាជ្យជាតិមិនមែនជាការប្រសើរទេ ទុកណាជាជំនួយនោះញ៉ាំងឲ្យសេដ្ឋកិច្ចយើងហាក់ដូចជារីកដុះដាលបែបណាក៏ដោយ ។ ជំនួយនោះត្រឡប់ទៅជាថ្នាំពុលបណ្តាលឲ្យស្លាប់បង់បាន កាលណាជំនួយនេះនាំឲ្យបង់នូវឯកភាព និងសន្តិភាព ។

តើប្រទេសថៃឡង់ដ៏ អាចឆ្អែងនឹងជំនួយខាងហិរញ្ញវត្ថុខាងសេដ្ឋកិច្ច និងយោធាដែលសហរដ្ឋអាមេរិកបំប៉នដល់ខ្លួន ឥតសំចៃបានទេ? តើខ្មែរយើងអាចសុខចិត្តទទួលរងផ្នូរនៃជំនួយទាំងនេះដោយការបាត់បង់ឯករាជ្យទាំងស្រុង ការពុករលួយដល់សង្គមនិងដល់សេដ្ឋកិច្ចដោយការកើតអសន្តិសុខនិងចម្បាំងគ្នាឯងឬទេ? តាមការពិត នៅគ្រប់ទីកន្លែងទាំងអស់ក្នុងលោកយើងសង្កេតឃើញនូវផលអាក្រក់នៃជំនួយបរទេសទាំងនោះ ដែលតែងមានផ្នូរអាក្រក់ជាដរាប ។ ក៏ប៉ុន្តែគេខិតខំបិទបាំងនូវផ្នូរអាក្រក់នោះដូចជាសន្និសីទ «បាន់ឌុង» សេដ្ឋកិច្ចនៃក្រុងអាល់ហ្សេរី ជាដើម ។

ពីព្រោះការដែលពួកអ្នកតំណាងនៃប្រទេសអាហ្វ្រិក អាស៊ី និង ឡាទីន អាមេរិករួមប្រជុំគ្នា ហើយអង្វររកសុំឲ្យពួកមហាអំណាចផ្តល់ជំនួយខាងសម្ភារនិងខាងហិរញ្ញវត្ថុជាការគួរអាម៉ាស់មុខណាស់ ពួកមហាអំណាច មហាសេដ្ឋីទាំងនោះ គេចាត់ទុកខ្លួនគេថាគ្មានជំពាក់ទាក់ទិនអ្វីជាមួយប្រទេសក្រីក្រ និងតូចតាចទេ យើងត្រូវយល់ច្បាស់ថា ពាក្យដែលគេហៅ «ជំនួយ» ត្រូវតែសងគេវិញជាដាច់ខាត តាមរបៀបជាអកុសលណាមួយជាមិនខាន ព្រមទាំងមានការប្រាក់យ៉ាងធ្ងន់ធ្ងរថែមទៀតផង ចំណែកខាងខ្មែរយើង យើងពេញចិត្តនឹងខ្លួនយើងណាស់ យើងមិនអាចលះបង់នូវកិត្តិយសនិងសភាពថ្លៃថ្នូររបស់ជាតិយើងបានទេ ។

ហេតុនេះយើងត្រូវតែពឹងផ្អែកលើកម្លាំងផ្ទាល់របស់យើង លើឯកភាពជាតិយើង លើសន្តិភាពក្នុងសង្គមជាតិយើង លើភោគទ្រព្យនិងការងារផ្ទាល់របស់យើងឲ្យបានដើរទៅមុខជានិច្ច ។ ជាការពិត យើងជាអ្នកក្រីក្រ ក៏ប៉ុន្តែសភាពក្រីក្រដែលមិនទប់មិនឲ្យប្រទេសជាតិចម្រើនលូតលាស់ បានយ៉ាងឆាប់រហ័សនោះទេ មានតែនាំឲ្យយើងបានចម្រើនយ៉ាងឆាប់រហ័សទៅវិញទេ ។

## ត្រូវនិយមផ្លូវជាតិនិងប្រាកដនិយម

អាស្រ័យហេតុនេះ ខ្ញុំសូមឲ្យសភាទាំងពីររកផ្លូវដោះស្រាយនូវបញ្ហាសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់យើង តាមផ្លូវជាតិនិងផ្លូវប្រាកដនិយមទៅវិញ ។ ជាអាទិ៍ ត្រូវដោះស្រាយបញ្ហានានាឲ្យបានយ៉ាងឆាប់រហ័ស ប្រយោជន៍ដើម្បីឲ្យបានទាន់នឹងល្បឿនដែលខ្ញុំខិតខំរុញរដ្ឋាភិបាលពិសេសឲ្យដើរទៅមុខ ។ ក្នុងគោលបំណងនេះ ខ្ញុំសូមឲ្យសហជីវិន-សហជីវិនី ពិភាក្សាហើយអនុម័តដោយរួសរាន់ នូវសេចក្តីព្រាងច្បាប់ស្តីអំពីការបែងចែកនូវសកម្មភាពខាងសេដ្ឋកិច្ចជាផ្នែកៗនិងសេចក្តីព្រាងច្បាប់ស្តីអំពីថវិកាប្រធ្លួនសម្រាប់ឆ្នាំ១៩៦៧ ។

ក្នុងវិស័យសង្គមកិច្ចយើងចាត់នូវការផ្តើមគំនិតថ្មីៗដែលខ្ញុំសូមឲ្យសហជីវិន-សហជីវិនី មេត្តាជួយចូលរួមជាកម្លាំងផងដែរ ។ គឺការកែប្រែទម្រង់នៃការសិក្សានិងការរៀបចំសាលាឯកជនឲ្យមានរបៀបរៀបរយឡើងវិញ ឬការប្រយុទ្ធជាថ្មីចំពោះអនក្ខរកម្ម ដែលសហជីវិន-សហជីវិនីត្រូវជួយជាវិភាគទានឲ្យបានយ៉ាងទូលំទូលាយបំផុត ។ ឯយុវជនរាជសង្គមនិយមខ្មែរយើង

ក៏ចាប់មានភាពស្វាហាប់ឡើងវិញ ជាលំដាប់រាល់ថ្ងៃដូចដើមវិញហើយ ។ ខ្ញុំយល់ថា សមាជិកនៃសភាទាំង២ អាចជួយអ្នកទទួលខុសត្រូវនៅតាមខេត្តនានាបានយ៉ាងស័ក្តិសិទ្ធិ ។

សរុបសេចក្តីទៅ ទោះបីបើយើងមានការលំបាកក្នុងបច្ចុប្បន្នកាលនេះ ទោះបើយើងនៅមានឧបសគ្គដែលត្រូវពុះពារ និងមានបញ្ហាដែលដោះស្រាយថែមទៀតក៏ដោយ ក៏យើងអាចមានសេចក្តីកក់ក្តៅចំពោះអនាគតដ៏ខ្វីរបស់យើងបាន ឲ្យតែយើងមានគតិបណ្ឌិត និងកម្លាំងធួនល្មមនឹងតាំងខ្លួនយើងនៅជាចៅហ្វាយលើវាសនារបស់ខ្លួនយើង គឺថាបើយើងនៅតែតាំងខ្លួនយើងជាអ្នកជាតិនិយម យ៉ាងតឹងរឹងដដែល ។

## ការប្រាស្រ័យទាក់ទងខាងយើងនិងបរទេស

### កកល្អក់ក្នុងការទាក់ទងជាមួយនឹងចិន

ដូចសហជីវិន-សហជីវិនី ជ្រាបស្រាប់ ការប្រាស្រ័យទាក់ទងរវាងយើងនិងប្រទេសចិនបានទទួលការកកល្អក់ បណ្តាលមកពីការដែលគេល្បួងចង់ដឹកនាំការបដិវត្តន៍វប្បធម៌ ឲ្យចូលមកក្នុងប្រទេសយើង ។ ខ្ញុំត្រូវតែទប់ទល់នឹងការបញ្ចូលនូវមនោគមវិជ្ជានេះ ដែលជាកិច្ចគំរាមកំហែងដល់ស្ថេរភាពនិងសន្តិភាពខាងក្នុងផ្ទៃប្រទេសហើយរំពុកថាការប្រាស្រ័យទាក់ទងខ្មែរ-ចិន ត្រូវយកគោលការណ៍ បាន់ឌុង ជាមូលដ្ឋានតែម្យ៉ាងប៉ុណ្ណោះ មិនត្រូវយកគោលការណ៍អ្វីដទៃទៀតមកលាយឡំជាដាច់ខាត ។ យើងបានរិះរកផ្លូវស្រោចស្រង់មិត្តភាពយើងជាមួយនឹងប្រទេសចិន ហើយខ្ញុំស្មានមើលទៅ ប្រហែលជាប៉េកាំងយល់រឿងនេះដែរ ថាប្រទេសកម្ពុជាបានសម្រេចជាដាច់ខាតថា នឹងតម្កល់អព្យាក្រឹតរបស់ខ្លួន និងអត្តសញ្ញាណរបស់ខ្លួនជាខ្មែរជាដាច់ខាត ។

### វ៉ាស៊ីតោនត្រូវបំពេញលក្ខខណ្ឌយើងបានកំណត់

មានពួក "ខ្មែរខៀវ" ខ្លះហើយជាពិសេស ពួកមជ្ឈដ្ឋានបរទេសខាងលោក "សេរី" ខ្លះនៃកម្ពុជរដ្ឋបានប្រកាសជាឱឡារិកថា សីហនុ ទើបតែនឹងភ្ញាក់ខ្លួនបើកភ្នែកយ៉ាងធំបំផុត ហើយមុខជានឹងងាកមកស្រវាឱបអាមេរិកកាំងវិញហើយ ។ ក្នុងរឿងនេះ សុំអ្នកទាំងនោះកុំប្រឡំឲ្យសោះ ។ យើងដាច់ខាតជាមិនធ្វើជាអ្នកសមគំនិត ឬជាបាវព្រាវរបស់សហរដ្ឋអាមេរិកជាពិតប្រាកដ ។ ប្រទេសកម្ពុជាមិនមែនជាប្រទេសយៀកណាមរបស់ ង្វៀន កាវគី ឬប្រទេសថៃឡង់ដ៏របស់ ថ្នម គិទិកាចន ទេ ។ ដរាបណា វ៉ាស៊ីនតោន មិនបានបំពេញនូវលក្ខខណ្ឌដែលខ្ញុំបានកំណត់រួចមកហើយ ដរាបនោះ ការប្រាស្រ័យទាក់ទងជាធម្មតារវាងយើងនិងអាមេរិកកាំងគ្មានផ្លូវនឹងធ្វើឲ្យកើតឡើងវិញបានឡើយ ។

### នយោបាយបដិការ

ការប្រាស្រ័យទាក់ទងរបស់យើងជាមួយនិងបរទេសនឹងតាំងលើនយោបាយបដិការជានិច្ច គឺយើងធ្វើមិត្តជាមួយប្រទេសទាំងឡាយណាដែលជាមិត្តយើង ជាសត្រូវជាមួយនឹងប្រទេសណាដែលយកយើងជាសត្រូវ ។ ប្រទេសទាំងឡាយណាគោរពឯករាជ្យ និងអព្យាក្រឹតយើង ហើយទទួលស្គាល់បូរណភាពនៃដែនដីយើងក្នុងបរិវេណនៃព្រំប្រទល់សព្វថ្ងៃ យើងចាត់ទុកប្រទេសនោះជាមិត្តយើង ។ ប្រទេសដទៃក្រៅអំពីនេះ យើងមិនត្រូវការទេ ។ ក្នុងរឿងនេះ សេចក្តីថ្លែងការណ៍ទទួលស្គាល់ មិនទទួលស្គាល់ ឬមិនច្បាស់លាស់របស់រដ្ឋាភិបាលនានាលើព្រំប្រទល់នៃដែនដីយើង ក្នុងបច្ចុប្បន្នកាលជាវិញ្ញាសាមួយដ៏មានសារសំខាន់ ។ ក៏បន្ថែមកទល់នឹងពេលនេះ សេចក្តីថ្លែងការណ៍ដែលយើងទទួលទាំងប៉ុន្មានសុទ្ធសឹងជាកិច្ចធានាអះអាង ដល់បច្ចុប្បន្នកាល និងអនាគតកាលរបស់យើងទល់នឹងនយោបាយពង្រីកទឹកដីដោយចោរកម្មរបស់អ្នកជិតខាងយើង ។

### ជោគជ័យថ្មីៗនៃការទូតយើង

ក្នុងរឿងនេះជោគជ័យថ្មីៗរបស់យើងខាងការទូតមានសភាពគួរឲ្យកក់ក្តៅជាពន់ពេកណាស់ ។ នៅទ្វីបអាហ្វ្រិក យើងរកបាននូវមិត្តថ្មីៗទៀត គឺប្រទេសម៉ូរីតានី ប្រទេសហ្គីណេ និងប្រទេសសេណេហ្កាល់ ដែលទើបនឹងទទួលស្គាល់ព្រំប្រទល់ដែនដីយើងសព្វថ្ងៃហើយ ថែមទាំងស្នើសុំប្តូរអគ្គរដ្ឋទូតជាមួយនឹងយើងទៀត ។ រីឯមិត្តអាហ្វ្រិកយើងជាន់ចាស់ គឺសាធារណរដ្ឋអារ៉ាប់រួម និងប្រទេសអាល់ហ្សេរី ប្រទេសទាំងនេះបានផ្តល់យើងនូវជំនួយយ៉ាងគាប់ប្រសើរបំផុតគឺបានទ្រទ្រង់យើងយ៉ាងច្បាស់លាស់ទល់នឹងបំណងវាតទឹកដីរបស់របបគ្រប់គ្រងព្រៃនគរ និងបាងកក ។ មួយវិញទៀត សហព័ន្ធអាល្លឺម៉ង់បានទទួលគោរពទាំងស្រុងចំពោះព្រំប្រទល់យើងសព្វថ្ងៃ ព្រមទាំងទទួលស្គាល់នូវសភាពជាស្ថាពរ

នៃព្រំប្រទល់នេះ មិនត្រូវអ្នកណាមកប៉ះពាល់បានឡើយ ។ ម្យ៉ាងទៀត ខ្ញុំទើបនឹងបានទទួលពីប្រទេសហ្វីលីពីន ដែលជាប្រទេសចូលខាងអាមេរិកាំងនូវសេចក្ដីថ្លែងការណ៍ទទួលគោរព និងទទួលស្គាល់ចំពោះបូរណភាពទឹកដីក្នុងបរិវេណនៃព្រំប្រទល់ដែនខ្មែរយើងសព្វថ្ងៃ ។

## ផែនការថ្មីនៃពួកអាមេរិកាំង

ហេតុនេះឃើញថា ទោះបើមានការបង្កិតបង្ខំរបស់ពួកចក្រពត្តិនិយមបែបណាក៏ដោយ ក៏កិច្ចប្រឹងប្រែងរបស់យើងដើម្បីតទល់នឹងបំណងវាតទឹកដីរបស់អ្នកនៅជិតខាងយើងតែងតែបានទទួលជោគជ័យជានិច្ច ក្នុងបច្ចុប្បន្នកាល និងអនាគត ។ ពួកអាមេរិកាំងដឹងខ្លួនច្បាស់អំពីជោគជ័យដែលពួកវាទើបនឹងបានទទួលហើយបើយោលទៅតាមសារព័ត៌មានរបស់វាឃើញថា មានផែនការថ្មីសម្រាប់បម្រើប្រយោជន៍របស់ប្រទេសថៃឡង់ដ៏និងយៀកណាមខាងត្បូងជាវណបរបស់គេ ។ ផែនការនេះមានសេចក្ដីស្នើសុំឲ្យប្រទេសកម្ពុជាចូលរួមក្នុងសន្និសីទមួយជាមួយនឹងអ្នកតំណាងក្រុងបាងកក និងព្រៃនគរ ដើម្បីសម្រុះសម្រួលអំពីបញ្ហាព្រំប្រទល់ដែនយើងដែលគេថា មានលក្ខណៈ "មិនជាក់លាក់" សន្និសីទនេះនឹងរាលដាលចេញពីកម្មវត្ថុដើម ហើយគេចង់ឲ្យមានការអញ្ជើញសហរដ្ឋអាមេរិក សហភាពសូវៀត និងប្រទេសចិនឲ្យចូលរួមប្រជុំផងដើម្បីសម្រុះសម្រួលអំពីវាសនារបស់យៀកណាម ។

ចម្លើយរបស់ប្រទេសកម្ពុជាចំពោះឧបាយកលរបស់អាមេរិកកាំងនេះគឺការពុំព្រមទទួលស្គាល់ជាដាច់ខាត ។ ព្រំប្រទល់ដែនយើងសព្វថ្ងៃមានសភាពជាក់លាក់បំផុត ហើយមានទាំងគេទទួលស្គាល់ថែមទៀតផង ។ ទោះជាអាងលើលេសបែបណាក៏ដោយ ក៏យើងមិនយល់ព្រមឲ្យគេលើកមកជជែកវែកញែកទៀតទេ ។ ការដែលនឹកឃើញថាមានកិច្ចចរចា ឬកិច្ចសន្ទនាលើបញ្ហានេះដែលបានទទួលការអារកាត់ស្រេចបាច់រួចហើយនោះ ជាការគួរឲ្យអស់សំណើចណាស់ ។ រីឯសេចក្ដីស្នើសុំឲ្យមានការសម្រុះសម្រួលរឿងយៀកណាមដោយពួកមហាអំណាចវិញ ប្រទេសកម្ពុជាដោយគោរពតាមគោលការណ៍របស់ខ្លួនយ៉ាងខ្ជាប់ខ្ជួននិងជិតាស់ជាដាច់ខាត ហើយមុខជានឹងគាំទ្រជានិច្ច ហើយយ៉ាងមុឹងម៉ាត់បំផុតផងចំពោះឧត្តមប្រយោជន៍នៃប្រជាជាតិយៀកណាមដែលទទួលការឈ្លានពានយ៉ាងអយុត្តិធម៌ ហើយដែលត្រូវកម្លាំងអាមេរិកាំង និងពួកស៊ីឈ្នួលវាដណ្ដើមយកទឹកដីទាំងកម្រោល ។

ឥរិយាបថរបស់រណសិរ្សនិងរបស់យៀកណាមខាងជើងមានសភាពត្រឹមត្រូវណាស់ ។

ឥរិយាបថរបស់រណសិរ្សសេរីកាជាតិយៀកណាមខាងត្បូង និងសាធារណរដ្ឋប្រជាធិបតេយ្យយៀកណាមខាងជើងមានសភាពត្រឹមត្រូវណាស់ ពួកអ្នករាតត្បាតត្រូវតែដកខ្លួនថយចេញពីយៀកណាមដោយគ្មានលក្ខខណ្ឌអ្វីដល់បន្តិច ហើយត្រូវតែទុកឲ្យជនជាតិយៀកណាម ដោះស្រាយកិច្ចការផ្ទាលរបស់គេដោយខ្លួនឯងផ្ទាល់ ។

យើងមិនទទួលយល់ព្រមឲ្យមហាអំណាចបរទេសណាមួយឬច្រើនគ្នា មានសិទ្ធិចូលមកបំផ្លាញឯករាជ្យពេញបរិបូរណ៍របស់ប្រទេសមួយទៀតទេ ។

ពួកចក្រពិត្តនិយមអាមេរិកាំង និងពួកអ្នកសមគំនិតរបស់គេ នៅតែបន្តការឃោសនាចោទប្រកាន់លើប្រទេសកម្ពុជា ហើយនៅតែចង់ចូលរួមរាតត្បាតយើងជានិច្ច ។ ជារៀងរាល់ថ្ងៃនៅតាមទល់ដែនកងទ័ពដ៏ក្លាហានរបស់យើងត្រូវរុញច្រានពួកខ្មាំងដែលស្ទាបស្ទង់សមត្ថភាពនិងសន្ទុះចិត្តតទល់របស់យើង ។ យើងទទួលនូវការបាត់បង់ជីវិតមនុស្សនិងការបំផ្លាញអំពីវា ក៏ប៉ុន្តែពួកបច្ចាមិត្តនៃយើងនេះត្រូវជឿឲ្យច្បាស់ថា យើងមិនបណ្ដោយឲ្យវាធ្វើតាមចិត្តបានជាដាច់ខាត ។

សរុបសេចក្ដីទៅ ពួកមហាអំណាចនៃបរទេសខ្លះ ទទូចតិះដៀលមួលបង្កាច់ប្រមាថមើលងាយកម្ពុជរដ្ឋយើង ។ តែកម្ពុជាយើងនៅតែមានការកិត្យានុភាពនិងទទួលសេចក្ដីរាប់អានពីគ្រប់ទិសទីក្នុងសកលលោក កិត្យានុភាព និងសេចក្ដីរាប់អាន ដែលប្រទេសដទៃទៀតច្រើនចង់បានដូចប្រទេសយើងតែធ្វើពុំកើត ។ ប្រទេសកម្ពុជានឹងស្ថិតនៅក្នុងឋានៈខ្ពង់ខ្ពស់បែបនេះជានិច្ចតទៅដរាបណាជនរួមជាតិយើងថែរក្សាឯកភាពសាមគ្គីធម៌របស់ខ្លួនបានគង់វង្ស ។ ហេតុនេះ ខ្ញុំសុំឲ្យអ្នកតំណាងរាស្ត្រ និងទីប្រឹក្សានៃព្រះរាជាណាចក្រកម្ពុជា កុំឲ្យសំចៃកម្លាំងក្នុងការផ្គត់ផ្គង់ឯកភាពនិងសាមគ្គីនេះនៅក្នុងផ្ទៃនៃសភាទាំង២ និងនៅក្នុងមណ្ឌលបោះឆ្នោតរៀងៗខ្លួន ។

# ចម្លើយសារភាព ស៊ីសុវត្ថិ ប៊ុតសារ៉ា ហៅ ច្រឹង

## ដកស្រង់ចេញពីឯកសារចម្លើយសារភាព D0៧៥៣៣

ស៊ីសុវត្ថិ ប៊ុតសារ៉ា ជាអតីតជាទាហានសក្តិ២ លន់ នល់ ដែលត្រូវចាប់បញ្ជូនមកមន្ទីរស-២១ ឬទួលស្លែង នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៧៦ ពីបទធ្វើវិទ្ធង្សនាប្រឆាំងបដិវត្តន៍ ។ នៅក្នុងឯកសារចម្លើយសារភាពកម្រាស់សែសិបបួនទំព័រ និងមានឈ្មោះ ង៉ែត ជាអ្នកកត់ត្រានោះ ឈ្មោះ ស៊ីសុវត្ថិ ប៊ុតសារ៉ា បានរៀបរាប់ពីជីវប្រវត្តិ និងសកម្មភាពវិទ្ធង្សនាប្រឆាំងបដិវត្តន៍ផ្ទាល់របស់ខ្លួន ជាពិសេស រៀបរាប់អំពីឈ្មោះខ្សែ សេ.អ៊ី.អា តួនាទី សកម្មភាព និងប្រវត្តិរូបរបស់អ្នកទាំងនោះម្នាក់ៗយ៉ាងលម្អិត ។ ស៊ីសុវត្ថិ ប៊ុតសារ៉ា មានឪពុកឈ្មោះ ស៊ីសុវត្ថិ ដួងលក្ខិណា (ស្លាប់) ម្តាយឈ្មោះ សុខ សួន (រស់) និងមានបងប្អូនពីរនាក់ ទី១) ប៊ុតសារ៉ា និងទី២) ញ៉េប សំមិត្ត នៅលីវ អាយុ១៩ឆ្នាំ រៀនថ្នាក់ទី៣ នៅភូមិលេខ៦ សព្វថ្ងៃទាំងអស់គ្នារស់នៅភូមិលេខ៦ ឃុំពោធិ៍បាន ។ ប៊ុតសារ៉ា មានប្រពន្ធឈ្មោះ តាក់ លីអេង និងឪពុកក្មេកឈ្មោះ តាក់ ឃុយ (រស់) រកស៊ីថតរូប ម្តាយក្មេកឈ្មោះ ហេង ឡេងជូ (រស់) ។ ខាងក្រោមនេះជាសេចក្តីសង្ខេបចេញពីចម្លើយសារភាពរបស់ ស៊ីសុវត្ថិ ប៊ុតសារ៉ា ៖

ខ្ញុំឈ្មោះ ស៊ីសុវត្ថិ ប៊ុតសារ៉ា ហៅ ច្រឹង អាយុ៣៣ឆ្នាំ ជាតិខ្មែរ កើតនៅភូមិសង្កាត់លេខ៣ ក្រុងភ្នំពេញ ។ លំនៅសព្វថ្ងៃនៅភូមិលេខ៦ ឃុំពោធិ៍បាន ស្រុក១៨ (កោះធំ) តំបន់២៥ ។ កម្រិតវប្បធម៌ រៀនដល់ថ្នាក់ទីបញ្ចប់ និងធ្វើទាហានសក្តិ២ ។

ឆ្នាំ១៩៥១ ខ្ញុំរៀនថ្នាក់ទី២ នៅសាលាឌូដា ក្រុងភ្នំពេញ ដល់ឆ្នាំ១៩៥៧ ខ្ញុំប្រឡងបឋមសិក្សាធ្លាក់ ក៏មករៀនថ្នាក់ទី៦ អនុវិទ្យាល័យកម្ពុជបុត្រ ។ ដល់ឆ្នាំ១៩៦១ ខ្ញុំផ្លាស់មករៀនវិទ្យាល័យឯកជន ថាច់ ង៉ុកថ្វាន់ ខាងត្បូងផ្សារស៊ីឡឹប ភ្នំពេញ ។ រៀននៅវិទ្យាល័យនេះ ចាប់ពីឆ្នាំ១៩៦៤ ដល់ថ្នាក់ទីបញ្ចប់ក៏ឈប់រៀន ហើយក៏មកចូលធ្វើការក្នុងហាងសូណាព្រឹម ក្រុមហ៊ុនជាតិក្រោមការទទួលខុសត្រូវរបស់ប្រធានអគ្គនាយក អ៊ុក ស៊ុន ។ ខ្ញុំមានភារកិច្ចជាអ្នកលក់ថ្មពិល និងក្រណាត់ ដោយប្រាក់ខែក្នុងមួយខែបីពាន់រៀល ។ រហូតដល់ឆ្នាំ១៩៦៧ ខ្ញុំឈប់ធ្វើការមកចូលធ្វើទាហាននៅអគ្គសេនាធិការយោធាខេមរភូមិន្ទ ក្នុងការិយាល័យទី៦ និងជានាយផ្នែក ជាទាហានកងការពារសន្តិសុខពេលបុណ្យរបស់រដ្ឋ ក្នុងរយៈនោះខ្ញុំបានឋានៈជាព្រិន្ទុបាលទោ ។

ក្នុងឆ្នាំ១៩៧០ ក្រោយរដ្ឋប្រហារ ខ្ញុំបានឋានៈសក្តិ១ ហើយផ្លាស់ទៅនៅបន្ទាយច្បារមន (កំពង់ស្ពឺ) ផ្នែកការិយាល័យទី២ ក្រោមការទទួលខុសត្រូវរួមរបស់ ឈឹម ឈួន ។ រហូតដល់ឆ្នាំ១៩៧៣ ខ្ញុំឡើងសក្តិ២ ហើយធ្វើការនៅក្នុងការិយាល័យទី២នេះ រហូតចប់សង្គ្រាម ប្រាក់ខែចុងក្រោយក្នុងមួយខែ ពីរម៉ឺនប្រាំមួយពាន់រៀល ។

ខ្សែសន្ទាក់សេ.អ៊ី.អា ដែលចូលនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៧០

១) ឈឹម ឈួន ពាក់ផ្កាយ១ ជាប្រធាន សេ.អ៊ី.អា

២) ម៉ម សារិន ពាក់សក្តិ៥ ជាអនុប្រធាន

៣) ហុយ ហែម ពាក់សក្តិ៥ ជានាយក្រុម

៤) ឡៅ សារី ពាក់សក្តិ៤ ជានាយក្រុម

៥) ពៅ ស៊ីជូ ពាក់សក្តិ៤ ជានាយក្រុម

៦) ម៉ម រតនា ពាក់សក្តិ២ ជាសមាជិក

៧) អុល ពាក់សក្តិ២ ជាសមាជិក

៨) ស៊ីសុវត្ថិ ប៊ុតសារ៉ា ពាក់សក្តិ២ ជាសមាជិក

៩) ហាក់ ឆៃហុក ពាក់សក្តិ២ ជាសមាជិក

១០) គង់ សុភមង្គល ពាក់សក្តិ៣ ជាសមាជិក

១១) ឆេង យាងម៉េង ពាក់សក្តិ៣ ជាសមាជិក

១២) កែវ ម៉ាន់ថា ពាក់សក្តិ៣ ជាសមាជិក

១៣) ស៊ីវ វន ពាក់សក្តិ២ ជាសមាជិក

១៤) ឃុត ឃុន ពាក់សក្តិ៣ ជាសមាជិក

១៥) សំណាង ពាក់សក្តិ២ ជាសមាជិក

១៦) ម៉ាយ៉ាសិទ្ធិ ពាក់សក្តិ៣ ជាសមាជិក

១៧) សានី ពាក់សក្តិ៣ ជាសមាជិក

១៨) មុិច សាលឿន ពាក់សក្តិ២ ជាសមាជិក

**ផែនការមុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥**

ប្រធាន សេ.អុី.អា ឈឹម ឈួន បានដាក់ផែនការឲ្យក្រុមសមាជិកខ្ញុំបាទមានដូចតទៅនេះ ៖

១) ឲ្យបំផុសបំផុលប្រជាជនក្រុងភ្នំពេញធ្វើការប្រឆាំងចំពោះកុម្មុយនីស្តខ្មែរឲ្យខ្លាំងក្លាបំផុត ។

២) ឲ្យឃ្លាំមើលសកម្មភាពនៃការជ្រៀតចូលមកលាក់បំពួននៃភ្នាក់ងាររបស់កងទ័ពរំដោះ ។

៣) ឲ្យស៊ើបអង្កេតមើលការលាក់គ្រាប់រំសេវ និងសម្ភារសឹករបស់កុម្មុយនីស្តខ្មែរនៅក្នុងទីក្រុងភ្នំពេញ ។

៤) ឲ្យតាមកម្ចាត់សកម្មភាពនៃការបាចខិតបណ្ណរបស់ភ្នាក់ងារកុម្មុយនីស្តខ្មែរនៅក្នុងទីក្រុងភ្នំពេញ ។

៥) ឲ្យបញ្ជាទៅលើទ័ព និងក្រសួងមានសមត្ថកិច្ចទាំងអស់ និងប្រជាជនក្នុងទីក្រុងកុំឲ្យជនចម្លែកមកស្នាក់អាស្រ័យជាដាច់ខាត ។

**ផែនការក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥**

ប្រធាន សេ.អុី.អា ឈឹម ឈួន និង ឡៅ សារី បានដាក់ផែនការឲ្យក្រុមអនុវត្តដូចតទៅ ៖

១) ឲ្យបំផុសបំផុលប្រជាជនមូលដ្ឋាន និងអ្នកជម្លៀសឲ្យស្អប់ខ្ពើមចំពោះកងទ័ពរំដោះ ។

២) ឲ្យធ្វើការទាមទារពេលម៉ោងឈប់សម្រាកឲ្យបានច្រើន ដើម្បីឲ្យស្ទះដំណើរការជឿនលឿនរបស់អង្គការរំដោះ ។

៣) ឲ្យបំផ្លិចបំផ្លាញសមាជិករបស់អង្គការបដិវត្តន៍ ។

៤) ធ្វើឲ្យអ្នកមូលដ្ឋាន និងជម្លៀស ធ្វើបាតុកម្មប្រឆាំងនឹងអង្គការបដិវត្តន៍ ។

**ក) អំពីខ្សែចាត់តាំងក្បត់**

ខ្ញុំពិតជាបានទទួលការចាត់តាំងក្បត់ពីលោកសក្តិ៤ ឡៅ សារី នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៧៥ ទីកន្លែងចាត់តាំងនៅវត្តភ្នំក្រុងភ្នំពេញ ។

**ខ) អំពីខ្លឹមសារណែនាំ**

របបសាធារណរដ្ឋគឺជារបបរស់នៅមានសិទ្ធិសេរីភាពគ្រប់បែបយ៉ាង ចង់ធ្វើអ្វីបានតាមចិត្ត គ្មានអ្នកណាត្រួតត្រាទេ ហើយរស់នៅដោយសប្បាយហឺហារ មានស្រីស្រា កុនល្ខោន ស៊ីឆ្ងាញ់ ដេកស្រួល ហើយធ្វើការមានបុណ្យសក្តិ ប្រាក់ខែ មិនដូចនៅខាងខ្មែរក្រហមទេ ។

ក្រុមខ្មែរក្រហមរស់នៅក្រោមការត្រួតត្រារបស់យួនយៀកកុង ជាខ្ញុំកញ្ជះយួន បើកដៃឲ្យយួនចូលឈ្លានពានទឹកដីខ្មែរ ។

ខ្មែរក្រហមជាទមិឡឥតសាសនា ធ្វើបាបលោកសង្ឃ ដុតវត្តអារាមតាមអំពើចិត្ត ហើយខ្មែរក្រហមកុម្មុយនីស្តប្រើអំណាចផ្តាច់ការលើប្រជារាស្ត្រ កាប់សម្លាប់តាមអំពើចិត្ត គ្មានគិតគូរដល់ប្រជារាស្ត្រក្រីក្រទេ ហើយបង្ខិតបង្ខំឲ្យប្រជារាស្ត្រធ្វើការទាំងយប់ទាំងថ្ងៃ ហើយឲ្យស៊ីមិនគ្រប់គ្រាន់ទៀត ។

**គ) អំពីបក្សពួកដែល ឡៅ សារី ចាត់តាំង**

ក្រុមដែល ឡៅ សារី ចាត់តាំងឲ្យប្រឆាំងជាមួយខ្មែរក្រហមមានចំនួនបីនាក់គឺ

១) ម៉ម រតនា ជាទាហានអនុសេនីយ៍ទោ ។

២) អុល ជាទាហានអនុសេនីយ៍ទោ និងខ្ញុំ ។

៤) ផែនការក្បត់ដែល ឡៅ សារី ដាក់ឲ្យខ្ញុំអនុវត្តគឺ

◆ ដើរឃោសនាបំផុសបំផុលប្រជារាស្ត្រឲ្យក្រោកឡើងប្រឆាំងជាមួយបដិវត្តន៍

◆ ដើរទាក់ទងអ្នករដ្ឋការចាស់ និងថ្មី ដើម្បីត្រៀមខ្លួននាំកងទ័ព សឹង ង៉ុកថាញ់ ចូល

◆ ឲ្យដើរលួចសម្ភារប្រជារាស្ត្រគ្រប់យ៉ាង តាំងពីការស៊ីចុកទៅ ដើម្បីធ្វើឲ្យស្មុគស្មាញ

**ឃ) អំពីសកម្មភាពដែលខ្ញុំបានអនុវត្តហើយ**

អ្នកដែលខ្ញុំបានណែនាំអប់រំចាត់តាំងឲ្យប្រឆាំងបដិវត្តន៍ដូចរូបខ្ញុំមានគ្នាបួននាក់គឺ ប៊ូ ខេង ធ្វើពេទ្យ, មាស ម៉េងហ៊ាង ធ្វើការនៅក្រសួងឃោសនាការ, ផល្លា ជាទាហានសក្តិ១ និង តៃ ស្មាន់ ហាត់កីឡាអង្គការបញ្ជូនទៅលើហើយ ។ រយៈនៅក្នុងមូលដ្ឋានភូមិលេខ៦ ឃុំពោធិ៍បាន ខ្ញុំពិតជាបាននិយាយឃោសនាបំផុសបំផុលអ្នកធ្វើការជាមួយឲ្យស្អប់ខ្ពើមអង្គការពិតមែន ។ ការងារពលកម្ម ខ្ញុំធ្វើដោយចុងដៃចុងជើងធ្វើដោយក្តៅក្រហាយ

នឹងអង្គការពិតមែន ក្រៅពីនេះខ្ញុំបានលួចកាប់ពោត កាប់ចេក បេះផ្លែល្មុតអង្គការជាញឹកញាប់ក្នុងបំណងធ្វើឲ្យស្អុកស្អាញដល់អង្គការប្រាកដមែន ។

តាមរយៈឯកសារចម្លើយសារភាពរបស់ ស៊ីសុវត្ថិ ប៊ុតសារ៉ា បានសរបញ្ជាក់ឲ្យដឹងថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ មិនត្រឹមតែប្រជាជនខ្មែរស្លូតត្រង់ទេ ដែលខ្មែរក្រហមជម្លៀសចេញពីលំនៅស្ថាន បង្ខំឲ្យធ្វើការងារជាទម្ងន់ និងសម្លាប់ សូម្បីតែញាតិវង្សានុវង្ស ក៏ត្រូវខ្មែរក្រហមជម្លៀស បង្ខំឲ្យធ្វើពលកម្មជាទម្ងន់ ចាប់យកមកធ្វើទារុណកម្ម និងសម្លាប់ដែរ ។ ញាតិវង្សានុវង្សមួយចំនួនត្រូវបានចាប់យកមកមន្ទីរស-២១ (ទួលស្លែង) ដើម្បីធ្វើទារុណកម្ម និងកម្ទេច ដោយសារតែមានជាប់និន្នាការជាមួយរបប លន់ នល់ ឬចោទប្រកាន់ថា ជាភ្នាក់ងារ សេ.អ៊ី.អា បង្កប់ស៊ីរូងផ្ទៃក្នុងប្រឆាំងនឹងអង្គការបដិវត្តន៍ ។ ជាក់ស្តែង នៅក្នុងសៀវនៅដែលមានចំណងជើងថា "អនុស្សាវរីយ៍ផ្អែមល្ហែម និងជូរចត់" ដែលជាស្នាព្រះហស្តរបស់ព្រះមហាវីរក្សត្រ នរោត្តម សីហនុក៏បានបង្ហាញនូវចំនុចខ្លះថា បុត្រា បុត្រីមួយចំនួនរបស់ព្រះអង្គ និងម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ ពង្សសានមុនី ក៏ត្រូវខ្មែរក្រហមជម្លៀសទៅឆ្ងាយដោយគ្មានដំណឹង និងខ្លះត្រូវបានសម្លាប់ទៀតផង ក្រោយពេលតាមដានផ្លូវដំណើរព្រះអង្គមកប្រទេសកម្ពុជាវិញ ។

**ផាច សារៈមុនិន្ទ**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១៦) ៨៧៦ ៦៩២

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

Email: truthsocheat@dccam.org

Home page: www.dccam.org

www.cambodiatribunal.org

# ព្រះរាជវង្សានុវង្សដែលបានសម្លាប់នៅមន្ទីរស-២១

| ល.រ | នាមនិងគោត្តនាម | ភេទ | មុខងារ | ប្រភពឯកសារថ្ងៃ | ចូលមន្ទីរស-២១ | ថ្ងៃកម្ទេចចោល |
|---|---|---|---|---|---|---|
| ១ | ស៊ីសុវត្ថិ ប៊ុតសារ៉ា | ប្រុស | ទាហានពាក់សក្តិ២ | បបគ ២០៦ | ១-៣-៧៦ | ៣-៥-៧៦ |
| ២ | ស៊ីសុវត្ថិ កេតារ៉ាវ៉ាក់ | ស្រី | ប្រពន្ធសក្តិ២ យាមគុក | បបគ ២០៦ | ១-៣-៧៦ | កម្ទេច |
| ៣ | ស៊ីសុវត្ថិដួងខារ៉ា ហៅម្ចាស់ហ៊ុត | ប្រុស | ពាណិជ្ជករ | K ០៦៥០៩ | (ឥតមាន) | (ឥតមាន) |
| ៤ | ស៊ីសុវត្ថិ អៀមម៉ារិយ៉ា | ( ) | កូនស្តេច | TSL ០២៨៤ | ១០-១០-៧៦ | ១៤-១០-៧៦ |
| ៥ | ស៊ីសុវត្ថិ ប៊ុនវីរៈវង្ស | ( ) | កូនស្តេច | TSL ០២៨៤ | ៣០-១០-៧៧ | (ឥតមាន) |
| ៦ | ស៊ីសុវត្ថិ នរៈនរិនដារ៉ារិទ្ធ ហៅចិន្តា | ស្រី | កូនស្តេច | TSL ០២០៤ | ២៩-៨-៧៨ | ១៤-១០-៧៦ |
| ៧ | ម៉ារីយ៉ា ហៅ ម៉ារី | ប្រុស | កូនស្តេច | បបគ ២១០ | ៨-១១-៧៦ | (ឥតមាន) |

# កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍រណសិរ្ស ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦

*គណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាបានបើកអង្គប្រជុំមួយដើម្បីសម្រេចទៅលើការលាលែងតំណែងរបស់សម្តេច នរោត្តម សីហនុ ។ សមាសភាពចូលរួមក្នុងអង្គប្រជុំនោះរួមមាន សមមិត្តលេខា ប៉ុល ពត, សមមិត្តអនុលេខា នួន ជា, សមមិត្ត វន (វន វេត), សមមិត្ត ខៀវ (សុន សេន), សមមិត្ត ហែម (ខៀវ សំផន), សមមិត្ត ឌឿន , សមមិត្ត ទុំ (សៀក ឆែ) និងសមមិត្ត ទូច ដោយបានសម្រេចលើការលាលែងរបស់សម្តេច នរោត្តម សីហនុ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦ ។ ខាងក្រោមនេះគឺជាកំណត់ហេតុនៃកិច្ចប្រជុំនោះ ។*

កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៧៦ គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាបានបើកអង្គប្រជុំមួយដែលសម្រេចទៅលើការលាលែងរបស់សម្តេច នរោត្តម សីហនុ ពីប្រធានកម្ពុជាប្រជាធិបតេយ្យ ។ សមាសភាពចូលរួមអង្គមានៈ

សមាសភាព សមមិត្តលេខា សមមិត្តអនុលេខា សមមិត្តវន
សមមិត្ត ខៀវ សមមិត្ត ហែម សមមិត្ត ឌឿន
សមមិត្ត ទុំ សមមិត្ត ទូច ។

របៀបវារៈ សីហនុ លាឈប់ពីតំណែង

## ១) សេចក្តីរាយការណ៍ស្តីអំពី សីហនុ លាឈប់

សមមិត្ត ហែម បានរាយការណ៍ជូនអចិន្ត្រៃយ៍អំពីការដែល សីហនុ លាឈប់ ។ សីហនុ ផ្ញើសំបុត្រជាភាសាបារាំងជូនមកអង្គការជាពីរច្បាប់ ។

មួយច្បាប់ស្នើសុំលាឈប់ ហើយបញ្ជាក់ពីមូលហេតុសំខាន់ៗដែលនាំឲ្យគាត់លាឈប់ ។ ពិសេស គាត់សង្កត់លើបញ្ហារោគផ្សេងៗរបស់គាត់ដែលពុំអនុញ្ញាតឲ្យបន្តតទៅទៀតបាន ។

មួយច្បាប់ទៀត ជាសេចក្តីថ្លែងការណ៍ជូនចំពោះប្រជាជនកម្ពុជាប្រជាធិបតេយ្យថាគាត់លាឈប់មុនថ្ងៃទី២០ មីនា១៩៧៦ ។

ពេលជួបទូត ម៉ូរីតានី និងទូត សេណេហ្គាល់ សីហនុ ក៏បានប្រាប់ថា គាត់លាឈប់ដាច់ខាតដែរ ។ ដល់ជួបគណៈប្រតិភូសេដ្ឋកិច្ចពាណិជ្ជកម្មចិន គាត់ត្អូញអំពីជំងឺគាត់........ ។

## ២) មតិរបស់អង្គការ

ក) មូលហេតុដែលនាំឲ្យ សីហនុ លាឈប់

មានពីរយ៉ាងគឺ ៈ មូលហេតុវែងឆ្ងាយនិងចំពោះមុខ ។

ក.១) មូលហេតុវែងឆ្ងាយ ៈ គឺទំនាស់វណ្ណៈជាមូលដ្ឋានរវាងបដិវត្តន៍និងគាត់ ព្រមទាំងគ្រួសារគាត់ ។ គាត់រស់នៅជាមួយយើងមិនបាន ។ កន្លងមក គាត់រស់នៅបានជាយុទ្ធវិធីទេ ។ ដោយយើងដំណើរការជាយុទ្ធវិធីទៅ គាត់ចេះតែនៅបានជាបណ្តើរៗ ។ សីហនុ មិនមែនលាឈប់តែម្តងនេះទេ ។ គាត់លាឈប់តាំងពីឆ្នាំ១៩៧១ មក ។

ក.២) មូលហេតុចំពោះមុខ ៈ គឺទំនាស់ជាយុទ្ធវិធីបន្ថែមលើទំនាស់ជាមូលដ្ឋាន ។ ឧទាហរណ៍ ដូចជាយើងឲ្យទូតចេញទៅក្រៅដោយពុំសួរគាត់ ។ គឺជារឿងតូចតាចទេ តែគាត់ស្មានថា ប្រហែលជាយើងលែងត្រូវការគាត់ហើយ ។ ដូច្នោះ ក៏ទំនាស់ចង់បានតំណែងតទៅទៀតដែរ ។

ក៏ប៉ុន្តែ ស្ថានការណ៍វិវត្តខ្លាំងជាងពេលមុនបន្តិចហើយ ។ នៅក្រៅប្រទេស គាត់រួមជាមួយយើងបាន ។ ដល់មកក្នុងប្រទេស គាត់ឃើញអស់រលីងគ្មានអនាគតសោះ ។ គាត់តានតឹងក្នុងចិត្តយ៉ាងខ្លាំង ។ គាត់អត់ការងារធ្វើ គាត់អផ្សុក ហើយបរិយាកាសនៅជុំវិញគាត់ ពិសេស ប្រពន្ធយំជាប់ ជំរុញឲ្យគាត់ទ្រាំមិនបាន ។ នៅតទៅទៀត ក៏មិនបានយូរ យ៉ាងច្រើនមួយឆ្នាំប្តូពីរឆ្នាំ ។ បើគង់តែទៅជាដដែល ទៅមុនឲ្យហើយទៅល្អជាង ។

ខ) បច្ច័យអាក្រក់បណ្តាលមកពីការលាលែងរបស់ សីហនុ

ខ.១) បច្ច័យឲ្យបដិវត្តន៍យើង ៈ ម្យ៉ាងប្រជាជនកម្ពុជាយើងទាំងមូល បានដកដង្ហើមធំចុងក្រោយរបស់ខ្លួនផុតហើយ ។

កម្មាភិបាលយើងទាំងអស់ កងទ័ពយើងទាំងអស់ក៏ដូច្នោះ ។ ឯ ប្រជាជនសកលលោកក៏គ្មានបញ្ហាអីដែរ ។

ម្យ៉ាងទៀត យើងដោះស្រាយការចាត់តាំងក្នុងអង្គការរដ្ឋយើងបានស្រួល តាមរយៈនេះយើងធ្វើបានស្រួលគ្មានទាក់ទាមអ្វីទៀតទេ ។

ទីបីការងារបរទេសយើង ក៏នឹងល្អជាងមុន ព្រោះយើងធ្វើខ្លួនយើង យើងយកជំហរដោយខ្លួនយើង ព្រោះអត់ សីហនុ យើងជ្រះស្រឡះ ។

ខ.២) បច្ច័យមិនឲ្យយើងៈ

ម្យ៉ាងវៀតណាមវាយយើង ថាយើងឆ្កួត ។ សីហនុ ជួយយើងម៉េចចោល សីហនុ ។ វាប្រាប់បដិវត្តន៍ផ្សេងៗល្អពីខ្លួន វាបន្ទុះបន្ទាប់យើង ។ តែបញ្ហានេះជាបណ្តោះអាសន្នទេ ។ ជាបញ្ហាចុងក្រោយ ឲ្យតែយើងនៅជិតស្និទ្ធនឹងគេទៅ អត់ចោទអីទេ ។

ម្យ៉ាងទៀត ខ្មាំងក៏វាយយើង ឲ្យវាយកន្ទះខែចុះ ។ តែបើ សីហនុ មិនលាលែង ក៏វានៅវាយយើងដែរ ចារកម្មក៏វានៅតែធ្វើ ។ បើវាវាយយើងអីចឹងទៅ តើលំបាកឲ្យយើងឬទេ? អត់អីទេ ព្រោះវាឯកោយើងពុំបាន ។

### ៣) វិធានការរបស់យើងៈ ទិសវិធានការមានពីរ

ក) ទិសទីមួយ យើងមិនប្រានគាត់ទេ យើងឲ្យគាត់នៅជាធម្មតា ។ បើគាត់ចង់នៅរស់ជាមួយយើង គាត់នៅបាន ចង់នៅប្រាំខែ មួយឆ្នាំឬបីឆ្នាំក៏បាន ។ បើនៅមិនបាន មិនមែនមកពីយើងទេ ។ តាមពិត គាត់នៅមិនបានទេ ។ ខ្លួនគាត់និងគ្រួសារគាត់ឃើញច្បាស់ហើយ គ្មានសុភមង្គលរបស់គាត់ទៀតទេ ។ យើងឲ្យផ្លូវនេះមួយទៅគាត់ គាត់នៅមិននៅ ស្រេចតែគាត់ ។

ដូច្នោះ យើងត្រូវទៅជួប ប្រាប់គាត់ថា យើងរវល់ ពុំបានមកញឹកញាប់ ឲ្យគាត់អធ្យាស្រ័យ ។ យើងទទួលសំបុត្រគាត់ហើយ ។ ហេតុនេះ ទើបជួបជុំគ្នា មកជួបគាត់ ។ សភាពការណ៍ប្រទេសយើងក្រីក្រលំបាកគ្រប់យ៉ាង ។ យើងត្រូវដោះស្រាយបញ្ហាក្នុងកិត្តិយសជាតិ ។ ទាល់តែអីចឹង ទើបឯករាជ្យ ។ គោលជំហរយើងទាំងអស់គ្នា ទាំងរដ្ឋាភិបាល គឺនៅតែថា គាត់មានគុណលើប្រទេស ពិសេសនៅលើឆាកអន្តរជាតិ ។ គាត់មានសគុណលើជាតិដែលមហាសន្និបាតបានសម្រេចហើយ ។ យើងខ្ញុំគោរពសមូហភាពណាស់ បើថាម៉េច គឺអីចឹងហើយ ។ តែសុំឲ្យគាត់នៅជាមួយប្រជាជនទៀត ។ ប្រជាជនតម្កល់ទុក សគុណគាត់តទៅទៀត យើងមានអំណរសាទរណាស់ ហើយខំឲ្យអស់លទ្ធភាពអនុវត្តសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតជាតិពិសេសរបស់យើង ។

ខ) ទិសទី២ ៈ ក្នុងករណីដែលគាត់នៅមិនព្រម

យើងអរគុណ ។ ក្នុងប៉ុន្មានឆ្នាំមកនេះ យើងកៀកស្មាគ្នា គាត់ឈប់ យើងស្តាយណាស់ ។ យើងនឹងប្រជុំគណៈរដ្ឋមន្ត្រីដើម្បីសម្រេច ។

បើយើងឈប់ហើយ មិនឲ្យគាត់ចេញទេ ។ បើឲ្យគាត់ចេញទៅស្អុកដល់ចិន ។ ខ្មាំងវាដេរយើងជាប់ ។ បើយើងមិនឲ្យចេញ ឲ្យវាដេរយើងមួយខែចុះ ។ សីហនុ ល្មមទេ គាត់មានស្មារតីស្នេហាជាតិខ្លះ តែប្រពន្ធគាត់គ្មានសោះ ។ ដូច្នោះ បើយើងដោះស្រាយមិនស្រឡះ យើងនៅជាប់កន្ទុយ នាំស្អុកដល់យើងច្រើន ។

ដូច្នោះ ចេញតាមច្រកទីមួយ ។ បើច្រកទីមួយ មិនរួចចេញតាមច្រកទីពីរ ។

គ) មតិរបស់អង្គការ អង្គប្រជុំយប់ថ្ងៃទី១៣

សមមិត្ត ហែម រាយការណ៍ជូនអចិន្ត្រៃយ៍អំពីបញ្ហាសីហនុ ។ គាត់សម្រេចសុំលាលែងពីតំណែងដាច់ខាត ។ ការឈប់នេះ មិនមែនជាការប្រឆាំងនឹងយើងទេ ។

សមមិត្តលេខាបានបញ្ជាក់ថា បញ្ហានេះជាបញ្ហាធំ ទុកឲ្យអង្គការមជ្ឈិមយើងអារកាត់ចុះ ។ ក៏ប៉ុន្តែ សមមិត្តលេខាបានព្រាងជាគោលគំនិតដែលអង្គការអចិន្ត្រៃយ៍ទាំងមូលយល់ស្របផងដែរ ដូចតទៅ ៖

១) មិនឲ្យ សីហនុ ចេញទៅក្រៅទេ នេះវិធានការទីមួយ

២) ត្រូវប្រជុំគណៈរដ្ឋមន្ត្រី រាយការណ៍ជូនគណៈរដ្ឋមន្ត្រីដើម្បីសម្រេចរួចហើយ ទៅជួប សីហនុ ទៀត ដោយមាន ប៉ែន នុត ចូលរួមផង ។

បើលែលកគាត់ថតសំឡេងបានរឹតតែជាការប្រសើរ ។ យើងត្រូវនិយាយយ៉ាងណាឲ្យគាត់មានសង្ឃឹម ហើយព្រមថតសំឡេង ។ យើងទុកជាឯកសារ ។

៣) វាយខ្សែលួសឲ្យកូនគាត់គាត់មកក្លាមដោយបញ្ជាក់ថា ឲ្យមករួមចូលឆ្នាំ និងបុណ្យឯករាជ្យ យើងចង់ដោះស្រាយបញ្ហា

នេះឲ្យស្អាត ។ យើងត្រូវដោះស្រាយយ៉ាងនេះ ទើបចំណោញបដិវត្តន៍ ។

៤) ជាសីលធម៌បដិវត្តន៍យ៉ាងណា ចំពោះការសម្រេចរបស់យើង

៤.ក) សីលធម៌បដិវត្តន៍ ឬជាផលប្រយោជន៍បដិវត្តន៍ ព្រោះសីលធម៌បដិវត្តន៍ត្រូវឈរលើផលប្រយោជន៍បដិវត្តន៍ ។ ជាសីលធម៌បដិវត្តន៍គឺថា ចំណោញបដិវត្តន៍ ។ ឲ្យគាត់ចេញខាតបដិវត្តន៍ ។

ការពិត សីហនុ ជាខ្លាសង្គម នៅតែស្បែក និងឆ្អឹង អត់ក្រចក អត់ចង្កូម ។ ពុកមាត់ក៏ត្រូវដកអស់ទៀត ។ ដូច្នោះ ចាំតែថ្ងៃស្លាប់ ។

ក៏ប៉ុន្តែ បើលែងខ្លាចាស់នេះឲ្យដើរទៅតាមផ្លូវ ក្មេងៗច្បាស់ជាខ្លាច ។ មនុស្សចាស់ខ្លះដែលពុំស្គាល់ថា ជាខ្លាស្គម ក៏ខ្លាចដែរ ។

៤.ខ) គាត់បានចូលរួមក្នុងបដិវត្តន៍ជាមួយយើងដែរ ទោះគាត់មានទំនាស់ជាមួយយើងក្តី ។ ដោយហេតុនេះហើយ បានជាបក្សសម្រេចឲ្យគាត់ធ្វើប្រធានគណៈប្រធានរដ្ឋទៀត ។ តែគាត់មិនព្រម ។ ដូច្នោះ គាត់នៅបាន ឬមិនបានជារឿងគាត់ ។

យើងទុកការសម្រេចរបស់យើង សមហេតុសមផលគ្រប់យ៉ាង ។

យើងនៅតែរក្សាគាត់ ។ តែបើគាត់នៅតែរើបម្រះយើងត្រូវបញ្ចប់ ។

៥) ទិសវិវត្តន៍របស់បដិវត្តន៍ ៖ គឺត្រូវតែបញ្ចប់សក្តិភូមិយ៉ាងដូច្នេះឯង ។ ក្រឡាអុកវាចេញមកដល់ត្រង់ហ្នឹងហើយ ។ របបសក្តិភូមិទាំងមូលត្រូវបដិវត្តន៍កម្ទេចនិងគាស់រំលើងជាស្ថាពរ ។ ស្តេចដែលមាន២០០០ឆ្នាំមកហើយ ទីចុងបំផុតត្រូវស្អាត ។ យើងគ្មានផ្លូវអីចេញក្រៅពីនេះទេ ។

ប្រតិកម្មច្បាស់ជាមានខ្លះ តែយើងត្រូវតែដើរតាមផ្លូវបដិវត្តន៍ចំណោញ ។

៦) វិធានការមួយទៀត ៖ ចាប់ពីថ្ងៃនេះទៅ លែងឲ្យជួបទូតបរទេស ត្រូវពន្យល់គេ ដោយលេសសមរម្យ ។



នៅព្រលានយន្តហោះពោធិចិនតុង ប៉ុល ពត ដើរជាមួយគណៈប្រតិភូចិន ដឹកនាំដោយ វ៉ាង ដុងស៊ីង (ឆ្វេង) ក្នុងអំឡុងពេលដំណើរទស្សនកិច្ចមកកាន់ប្រទេសកម្ពុជាកាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ។ ថ្នាក់ដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យរួមមាន នួន ជា, ខៀវ សំផន និង អៀង សារី ក៏មានវត្តមានក្នុងឱកាសនោះដែរ ។ ពេលនោះ ប៉ុល ពត បានស្នើសុំជំនួយយោធាពីចិនដើម្បីទប់ទល់ជាមួយវៀតណាមខណៈពេលដែលជម្លោះរវាងប្រទេសទាំងពីរតានតឹងកាន់តែខ្លាំង តែត្រូវចិនបដិសេធ ។ ជិតពីរខែក្រោយមក វៀតណាមបានវាយចូលកម្ពុជា ។ រូបស្ត្រីនៅខាងស្តាំ សមមិត្ត ស៊ៀ អ្នកបកប្រែភាសាចិន-ខ្មែរ ។

# បញ្ជីឈ្មោះនិងរូបថតអ្នកទោសមន្ទីរស-២១ដែល ទទួលបាននៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១២

**អ្នកកត់ត្រា ៖ ឆាំង យុ, ញាណ សុជាតិ និង ស៊ីវ សាវីណា**

| ល.រ | ឈ្មោះ | ភេទ | លេខរូបថត | រឿងរ៉ាវទាក់ទងនឹងប្រវត្តិរូបសង្ខេប |
|---|---|---|---|---|
| ១ | គីម ស្រ៊ិន | ស្រី | ២០ | ប្រពន្ធ ហឹង ចុង ៨.១១.៧៦ (អាចជាថ្ងៃខែចាប់ខ្លួន) |
| ២ | សៀ យ៉ាត | ប្រុស | ១ | ប្រជាជនថ្មីតំបន់៣៣ ៥.៩.៧៦ |
| ៣ | ឈុន ដៀន-ដឿន | ប្រុស | ៤ | សមាជិកពាណិជ្ជកម្ម |
| ៤ | សាប់ ទៀន | ប្រុស | ៣ | យុទ្ធជន ព.រ |
| ៥ | ដូ ព្រិន្ទ | ប្រុស | ? | យុទ្ធជន កង១៣ ស-២១យ ៣.៨.៧៦ |
| ៦ | ទា ឈុនកេង | ស្រី | ១២ | ប្រពន្ធ ម៉ៅ សុផានី ៨.១១.៧៦ អគ្គការចក្រអង្រែ (ស-២១យ) |
| ៧ | សួន នេ | ប្រុស | ៩ | ផ្នែកឃ្លាំង |
| ៨ | សុក ណាំង | ប្រុស | ៨ | នេសាទភាគនិរតី |
| ៩ | រត់ វណ្ណៈ | ប្រុស | ៨ | យុទ្ធជន ឧស្សាហកម្មរដ្ឋដឹកជញ្ជូន |
| ១០ | ទីប ផាត់ | ប្រុស | ៤ | យុទ្ធជន ដឹកជញ្ជូនភូមិភាគបូព៌ា |
| ១១ | អ៊ូ សុន (សារុន) | ប្រុស | ២ | កងហា |
| ១២ | លី សៀ | ប្រុស | ១៥ | កម្មករចាស់រទេះភ្លើង ២៨.១០.៧៦ |
| ១៣ | យិន ណែម | ប្រុស | ៣១ | រទេះភ្លើង ២៨.១០.៧៦ |
| ១៤ | យឹម យុទ្ធ (ស៊ីម) | ប្រុស | ២ | ពេទ្យកម្មករ |
| ១៥ | សែម គីមទីង | ប្រុស | ១ | ស័ក្តិពីរ ម៉ារីន |
| ១៦ | សុក ដិប | ប្រុស | ៣ | ចោរព្រៃ |
| ១៧ | ម៉ឹល ថន (យុត) | ប្រុស | ១០ | ពាណិជ្ជកម្ម |
| ១៨ | សេង វណ្ណៈ | ប្រុស | ១៣ | កង១៣ ស-២១យ |
| ១៩ | សោម រស់ | ប្រុស | ២៣ | យុទ្ធជន ៩?៧៦ (សោម រស់រដា)? |
| ២០ | វ៉ា ប៊ុនគ្រី | ប្រុស | ១៤ | ប្រធានក្រុម យ |
| ២១ | អ៊ុំ ធុល | ស្រី | ១៥ | រទេះភ្លើង ប្រពន្ធ មួង ផង់ ២៨.១០.៧៦ |
| ២២ | ម៉ុន គង់ | ប្រុស | ១១ | មេក្រុម ៨.១១.៧៦ |
| ២៣ | ម៉ា សួសប្រែម | ប្រុស | ១០ | អគ្គការចក្រអង្រែ ៨.៨.៧៦ |
| ២៤ | នៅ ខន | ប្រុស | ៧ | ពេទ្យ |
| ២៥ | ងួន សារ៉ាត | ប្រុស | ៣ | ចក្រអង្រែ ៤.៨.៧៦ |
| ២៦ | ព្រុំ សុខា (ឯក) | ប្រុស | ៥ | ស័ក្តិពីរ យន្តហោះ |

| | | | | |
|---|---|---|---|---|
| ២៧ | ស៊ីន សេង | ប្រុស | ៩ | លោកសង្ឃ |
| ២៨ | គាំ ឆែម | ស្រី | ២៩ | ម្ដាយ ម៉ុក សាមឿន ២០.១០.៧៦ |
| ២៩ | វ៉ា ដេស៊ីឡា | ស្រី | ៣២ | សិស្សសាលា ប្អូនថ្លៃ តឹក កូ ៨.១១.៧៦ |
| ៣០ | លី ទ្រី | ប្រុស | ៣៦ | ឪ ចៅសន ៣០.១១.៧៦ |
| ៣១ | ឈៀម សុកជា | ប្រុស | ៧ | វិស្វករ |
| ៣២ | ថាញ់ ពេជ | ប្រុស | ១០ | លោកសង្គ្រាប |
| ៣៣ | សួង សៅខន | ស្រី | ២០ | កម្មករចាស់រទេះភ្លើង ២៨.១០.៧៦ |
| ៣៤ | ព្រុំ ស៊ីម | ស្រី | ៣ | ម្ដាយ ជុំ សាខន ២៨.១០.៧៦ |
| ៣៥ | ណុប សាលួត | ប្រុស | ១ | មេក្រុម១២ ៨.១១.៧៦ |
| ៣៦ | ឃីម អន | ប្រុស | ៩ | នីរសារ |
| ៣៧ | សុខ ផល្លី | ប្រុស | ១៣ | អនុកងវរយ១៧០ (រូបថតញញឹម) |
| ៣៨ | ប៉ែន យឿន | ប្រុស | ២ | ស្នងការកងវរយ កងពល១៧០ |
| ៣៩ | ឌិប សេង | ស្រី | ៩ | ប្រពន្ធ គុប ម៉ុង ៣០.១០.៧៦ |
| ៤០ | គង់ វ៉ានថន | ស្រី | ១៧ | ប្អូនថ្លៃ សំ ហម ៨.១១.៧៦ |
| ៤១ | ណុម ស៊ី | ស្រី | ១២ | ប្រពន្ធ យិន ណែម ២៩.១០.៧៦ |
| ៤២ | ម៉ឹង សឿន | ស្រី | ៨ | ប្រពន្ធកម្មករចាស់ |
| ៤៣ | ឈុំ ឈឿន | ប្រុស | ២០ | អនុក្រុម១៧០ ៦.៩.៧៦ |
| ៤៤ | ឆាយ ចេង | ប្រុស | ៣ | កងពល ៧០៣ |
| ៤៥ | ចក់ សុង | ប្រុស | ២៩ | ប្រជាជន ផ្ទះ ០៥ |
| ៤៦ | យស់ សឿន | ប្រុស | ២២ | យានដ្ឋានផ្សារថ្មី |
| ៤៧ | ណោ ស៊ីណា | ប្រុស | ១៨ | យុទ្ធជន ១៧០ |
| ៤៨ | ឃុឹម អឿន | ប្រុស | ១២ | ពាណិជ្ជកម្ម (អោនមុខចុះ) |
| ៤៩ | អ៊ុន ប៉ាង | ប្រុស | ២ | យុទ្ធជន ១៧០ |
| ៥០ | ព្រុំ អឿន | ប្រុស | ៣ | ១៧០ |
| ៥១ | សួន មី | ប្រុស | ៥ | អនុក្រុម៣ ៨.១១.៧៦ |
| ៥២ | ប៊ុល សឿន | ស្រី | ២៤ | ប្រពន្ធ កាយា ២៨.១០.៧៦ |
| ៥៣ | ហែរ ហម (សារឿន) | ប្រុស | ២ | អនុសេនាតូច |
| ៥៤ | ព្រុំ អេងឈុន | ប្រុស | ១៣ | បើកប្រាក់ខែទាហាន (រូបថតញញឹម) |
| ៥៥ | ឡុប សុភី | ស្រី | ១៦ | កូន ឡុប ឈុន ៣០.១០.៧៦ |
| ៥៦ | ស៊ឹង ភឿក ថ | ប្រុស | ១ | កម្ពុជាក្រោម កាសែតមាតុភូមិ |
| ៥៧ | អួង យ៉ែន | ស្រី | ១៨ | ស-២១យ ៨.១១.៧៦ |
| ៥៨ | ឃីម សារុន | ប្រុស | ៧ | ១៧០ |

| | | | | |
|---|---|---|---|---|
| ៥៩ | ហែម សុខុន | ប្រុស | ៣៨ | កូន ហែម ដៃ ៣០.១០.៧៦ |
| ៦០ | ស័ក្ក ប៊ុនថុន | ប្រុស | ១៥ | ប្រជាជនថ្មី |
| ៦១ | ហម ហុក | ប្រុស | ៧ | ពេទ្យកងពល៥០២ ៥.៩.៧៦ |
| ៦២ | ប៊ី រួន | ប្រុស | ១៨ | (ដែក) យុទ្ធជន |
| ៦៣ | ព្រុក វឿន | ស្រី | ២៣ | ប្រពន្ធ វ៉ាត ២២.១០.៧៦ |
| ៦៤ | ម៉ៅ ហង់សុភី | ប្រុស | ២០ | យុទ្ធជន កង៤៨៨ ៤.៨.៧៦ (អាវយឺតកម្ពូល) |
| ៦៥ | យី សុខន | ប្រុស | ៧ | ទាហានស័ក្តិ២ |
| ៦៦ | ចាន់ សុក | ប្រុស | ១ | ក្រុម ១៧០ |
| ៦៧ | អៀម ហៀង | ប្រុស | ៣ | កម្មករបច្ចេកទេស |
| ៦៨ | ស៊ូថៃ វ៉ា | ប្រុស | ១៨ | មេពួកកងពល១៧០ ៦.៩.៧៦ |
| ៦៩ | អ៊ូ សារុន | ប្រុស | ៣០ | កម្មករចាស់ ២៨.១០.៧៦ |
| ៧០ | គីម ប៊ុនថូ | ប្រុស | ១ | សហករណ៍ស៊ីងមានជ័យ ៤.៨.៧៦ |
| ៧១ | ពុង យួន (យឿង) | ប្រុស | ៩ | កងវរយ ៣១០ (អត់ពាក់អាវ) |
| ៧២ | តុប ស្រុន | ប្រុស | ២៦ | ឪ តុប ម៉េង ៣០.១០.៧៦ |
| ៧៣ | សូ ឈន | ប្រុស | ១៧ | និរសារ កងពល១៧០ |
| ៧៤ | សាន់ ភី (ម៉ុន) | ប្រុស | ៨ | យុទ្ធជន ៥០២ |
| ៧៥ | ង៉ាន ថុន | ប្រុស | ១ | កងធំ ឃ្លាំងរដ្ឋ |
| ៧៦ | អាយ លី | ប្រុស | ៤ | យុទ្ធជនកង១៣ ២៦.៨.៧៦ |
| ៧៧ | កាំង វណ្ណាសី | ប្រុស | ១០ | កាឡី ទាហានជាងម៉ាស៊ីនយន្តហោះ ៣.៨.៧៦ |
| ៧៨ | នួវ ណៃអៀង | ស្រី | ១ | រទេះភ្លើង |
| ៧៩ | មាស អាន (អុល) | ប្រុស | ២១ | ដែកកំពង់សោម ២៩.៩.៧៦ |
| ៨០ | ញ៉ឹក វេងហៀង ញ៉ឹក វេ ហួរ | ប្រុស | ៨ | ស័ក្តិពីរ |
| ៨១ | ឈឹម ឌុក | ប្រុស | ៣ | យុទ្ធជន កង១៧០ |
| ៨២ | សា ឌី | ប្រុស | ៥ | អនុក្រុម បើកបរកសិកម្មរដ្ឋ |
| ៨៣ | យិន យីន | ប្រុស | ២០ | ខ្មែរកម្ពុជាក្រោម |
| ៨៤ | សឹម សំ | ប្រុស | ១១ | ទទួលភ្ញៀវកំពង់សោម |
| ៨៥ | ទឹម ហ៊ុំ | ប្រុស | ៦ | ១៧០ |
| ៨៦ | អ៊ូ សារ៉ុន | ប្រុស | ៣៧ | អគ្គិសនីទី៣ |
| ៨៧ | ណាន ឡាក់ | ប្រុស | ៧ | ប៉េអឹម ស័ក្តិមួយ |
| ៨៨ | កែវ វ៉ែន | ប្រុស | ៦ | កងវរយ ៥០២ |
| ៨៩ | ខៀវ ថ្មី | ប្រុស | ? | ក្រសួងប្រេង |
| ៩០ | ពុធ សុវណ្ណ | ស្រី | ១៣ | កូនសិស្សស្វាយរៀង |

| | | | | |
|---|---|---|---|---|
| ៩១ | ហ៊ិន អឿន | ប្រុស | ៥ | ១៧០ |
| ៩២ | ជុំ ឱ្យាន | ប្រុស | ២១ | កម្មករចាស់ ២៩.១០.៧៦ |
| ៩៣ | គឹម វង់ | ប្រុស | ? | ទាហានស័ក្ដិពីរ (អាវផ្កា) |
| ៩៤ | រស់ ផាន | ប្រុស | ៧ | អនុក្រុម កងពល ១៧០ |
| ៩៥ | ជា ប៉ោ | ប្រុស | ៣ | ក្រុម១៧០ |
| ៩៦ | ស ផល្លា (ភាក់) | ប្រុស | ៧ | ថាមពល ១១.៨.៧៦ |
| ៩៧ | ឡាវ អៀវ | ប្រុស | ២៤ | ទាហានស័ក្ដិពីរ |
| ៩៨ | លឿង សុក | ប្រុស | ៤ | មេក្រុម៣ ៨.១១.៧៦ |
| ៩៩ | ទឹម សារិន | ប្រុស | ២១ | ព្រិនបាលឯក ដើងទឹក |
| ១០០ | ពក កា | ប្រុស | ៦ | ស-២១យ ៣១.៨.៧៦ |
| ១០១ | ប៉ុក ពក | ប្រុស | ២០ | ប្រជាជន |
| ១០២ | សឹម ស៊ុត | ប្រុស | ? | និរសារ ៥.៩.៧៦ |
| ១០៣ | ឆុង ឆេង (ឆេន) | ប្រុស | ១៣ | យោធា ១៧០ |
| ១០៤ | ជុំ ចន | ប្រុស | ? | ជាតិខ្មែរ |
| ១០៥ | ជូ ឈិត | ប្រុស | ១៣ | ថត ១២.១១.៧៦ |
| ១០៦ | ឯម ម៉េតរិន | ស្រី | ២ | មេពួកស្រី កំពង់ដៃ កំពង់សោម |
| ១០៧ | គល ឌុល | ប្រុស | ៦ | កងពល៥០២ ២៤.៩.៧៦ |
| ១០៨ | សូ លុន | ប្រុស | ៦ | អនុកងរយ |
| ១០៩ | គឹម ពិសតូ (ញ៉ើម ណុច) | ប្រុស | ២ | កម្មករផាក់ស៊ីក្លូ |
| ១១០ | ឯក ភឿងភាព | ប្រុស | ២៤ | ពាណិជ្ជកម្ម |
| ១១១ | ហម សុគង់ | ប្រុស | ១ | ស្រុកបារាំង |
| ១១២ | ជឹង កុកហួរ | ប្រុស | ៨ | ភារៈស្ដីទីស្ថានទូត |
| ១១៣ | លី ប៊ុនណង | ប្រុស | ៤ | ស័ក្ដិបួន |
| ១១៤ | ឈឿង ហ៊ីនណាង | ប្រុស | ១៩ | យុទ្ធជន ស-២១យ ១៥.៩.៧៦ |
| ១១៥ | ថោង ដៃ | ប្រុស | ៣ | ១៧០ |
| ១១៦ | កែវ សុភី | ស្រី | ២១ | ប្រពន្ធ ទិត គង់ ៨.១១.៧៦ |
| ១១៧ | លី ហ៊ុយ | ប្រុស | ២ | យុទ្ធជន ២៦០ ៣១.៨.៧៦ |
| ១១៨ | ងិន សារិន | ប្រុស | ? | ១៧០ |
| ១១៩ | ឆាយ សារិន | ស្រី | ១០ | កម្មកររទេះភ្លើង |
| ១២០ | អេង សារដ្ឋ | ប្រុស | ៦ | កូន គឹក សេង អេង ១៩.១២.៧៦ |
| ១២១ | ជា សំសុត | ប្រុស | ២៣ | ទាហានស័ក្ដិបី |

**(នៅមានត)**

# "ខ្ញុំនៅតែចងចាំ"



សេង ទិត អាយុ៣៦ឆ្នាំ ជាក្មេងកំព្រា មានស្រុកកំណើតនៅភូមិវត្តថ្មី ឃុំព្រែកដំបូក ស្រុកមុខកំពូល ខេត្តកណ្តាល ។ បច្ចុប្បន្ន ទិត រស់នៅខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ទិត ជាគ្រូបង្រៀននៅខេត្តកោះកុង ប៉ុន្តែបានផ្លាស់មករៀនបន្តនៅវិទ្យាស្ថានជាតិអប់រំនៅក្រុងភ្នំពេញដើម្បីប្រឡងយកសញ្ញាបត្រក្របខណ្ឌគ្រូកម្រិតឧត្តមសិក្សាសម្រាប់មុខវិទ្យាប្រវត្តិវិទ្យា ។ ប្រវត្តិវិទ្យាគឺជាមុខវិទ្យាមួយដែលគាត់ស្រឡាញ់ ជាពិសេសគាត់យល់ថាពិតជាសំខាន់ណាស់សម្រាប់ជាតិសាសន៍នីមួយៗដែលត្រូវតែយល់ដឹងពីប្រវត្តិសាស្ត្ររបស់ជាតិខ្លួនក៏ដូចជាប្រទេសដទៃ ។ ទិត បានចូលរួមវគ្គបណ្តុះបណ្តាលគរុនិស្សិតស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយវិទ្យាស្ថានជាតិអប់រំនៃក្រសួងអប់រំ យុវជន និងកីឡាកាលពីខែសីហាកន្លងទៅ ។

ទោះបីជានៅរបបខ្មែរក្រហម ទិត ជាកុមារដែលមានអាយុទើបតែបួនឆ្នាំក៏ដោយតែគាត់ នៅចាំបានរឿងរ៉ាវខ្លះដែលកើតមានដែរ ។

ក្នុងឆ្នាំ១៩៧០ ក្រោយរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ក្រុមគ្រួសាររបស់ ទិត ត្រូវបានចាកចេញពីផ្ទះមួយរយៈដោយសារតែមានការទម្លាក់គ្រាប់បែក ។ នៅឆ្នាំ១៩៧៣ ក្រុមគ្រួសារឪពុកម្តាយរបស់ ទិត បាននាំគ្នារត់ចូលជាមួយនឹងប្រជាជនផ្សេងទៀតតាមការអំពាវនាវរបស់សម្តេច សីហនុ ដើម្បីធ្វើការតស៊ូប្រឆាំងនឹង លន់ នល់ ។

ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ គ្រួសាររបស់ ទិត ត្រូវបានអង្គការចាត់តាំងឲ្យទៅរស់នៅភូមិក្រពើហារ ។ ពេលនៅដល់ទីនោះ ម្តាយរបស់ ទិត ត្រូវបានអង្គការចាត់តាំងឲ្យនៅសហករណ៍ភូមិព្រៃដំបង ។ ក្រុមគ្រួសាររបស់ ទិត ត្រូវបានអង្គការចែកកូនផ្ទះខ្ទមមួយដើម្បីឲ្យស្នាក់នៅមួយរយៈ ។ ការរស់នៅទីនេះអង្គការបានចែកជាម្តៃក្រុមតូចៗសម្រាប់ឲ្យប្រជាជនស្នាក់នៅ ។ ក្រោយមក ក្រុមម្តាយរបស់ ទិត ត្រូវបានអង្គការចាត់តាំងឲ្យធ្វើស្រែ លើកទំនប់ និង ស្ទូងស្រូវ ជាដើម ។ ការងារនៅទីនោះ ម្តាយរបស់ ទិត មិនមានពេលសម្រាកបានគ្រប់គ្រាន់នោះទេ ជាងនេះទៅទៀត ចំពោះការហូបចុកវិញក៏មិនគ្រប់គ្រាន់ដែរ ប្រជាជនជាច្រើននៅសហករណ៍មានជំងឺហើមនិងអ្នកខ្លះទៀតស្លាប់ដោយសារការអត់ឃ្លាន ។ ថ្ងៃមួយម្តាយរបស់ ទិត បានឃើញសមាជិកដែលធ្វើការនៅក្នុងសហករណ៍ជាមួយគ្នាត្រូវបានកងឈ្លបហៅយកទៅរៀនសូត្រ ចាប់តាំងពីនោះមក អ្នកទាំងនោះក៏បាត់ដំណឹងរហូត ។ ចំពោះម្តាយរបស់គាត់តែងតែភ័យក្នុងចិត្តជានិច្ចដោយគិតថាមិនដឹងថ្ងៃណាប៉ះមកលើរូបគាត់នោះទេ ព្រោះអ្នកដែលឈ្លបមកហៅទៅរៀនសូត្រគឺមិនដែលឃើញត្រឡប់មកវិញនោះទេ ។

ថ្ងៃមួយម្តាយរបស់ ទិត បានអង្គុយនៅក្បែរស្នូលពោតដែលនៅសល់ ចៃដន្យពេល ឈ្លបមកទាន់ឃើញ រួចក៏បានចាប់

បញ្ជូនទៅថ្នាក់លើដោយចោទគាត់ថា "ជាខ្មាំងក្បត់អង្គការ" និងយកទៅកសាងណែនាំនិងអប់រំដើម្បីកុំឲ្យខុសទៅនឹងវិន័យរបស់អង្គការទៀត ។ ក្រោយមក ម្តាយរបស់ ទិត ក៏បានត្រឡប់មកសហករណ៍ធ្វើការតាមធម្មតា ។ ដោយសារតែនៅឆ្ងាយពីឪពុកម្តាយគ្មានអ្នកថែទាំបងស្រីរបស់ ទិត បានស្លាប់ដោយសារកើតជំងឺអុជ ។ ចាប់តាំងពីនោះមក ម្តាយរបស់ ទិត សោកស្តាយយ៉ាងខ្លាំងបានត្រឹមតែអង្គុយយំតែម្នាក់ឯងមិនហ៊ានបញ្ចេញសំឡេងឲ្យអ្នកផ្សេងដឹងឡើយ ។

លើសពីនេះទៀត បងស្រីទីមួយ របស់ ទិត ឈ្មោះ សេង ធី ត្រូវបានរៀបចំជ្រើសរើសឲ្យប្តេជ្ញាដើម្បីជ្រើសរើសគូស្រករតាមបញ្ជារបស់អង្គការ ។ នៅក្នុងនោះ បងស្រី របស់ ទិត ត្រូវបានអង្គការចាត់តាំងជាគូទី៥ ជាគូចុងក្រោយបង្អស់ ។ ទោះបីជាយ៉ាងណាក៏ដោយគ្មាននរណាម្នាក់ហ៊ានបដិសេធមិនព្រមរៀបការនោះទេ ប្រសិនបើអ្នកណាហ៊ានជំទាស់ ពិតជាត្រូវអង្គការយកទៅសម្លាប់ចោលមិនខាន ។ មានពេលមួយ ទិត បានឃើញកងឈ្លបចាប់ចងអ្នកនៅភូមិជាមួយគាត់ជាច្រើននាក់ដាក់ឡានដឹកចេញទៅ ចាប់តាំងពីពេលនោះមក អ្នកទាំងនោះបាត់ដំណឹងរហូតមិនដែលឃើញត្រឡប់មកវិញទេ ។ មានពេលមួយនោះ ជីដូនរបស់ ទិត នាំគាត់ទៅមុជទឹកនៅមាត់ទន្លេ ទិត ឃើញសាកសពជាច្រើនអណ្តែតលើទឹកទន្លេដែលមើលទៅគួរឲ្យខ្លាចខ្លាំងណាស់ ។ មកដល់សព្វថ្ងៃទិដ្ឋភាពទាំងនេះនៅតែដិតដាមជាប់នឹងចិត្តរបស់គាត់ជានិច្ច ។

នៅឆ្នាំ១៩៧៩ ពេលដែលវៀតណាមចូលមករំដោះប្រទេសទាំងស្រុង ប្រជាជនម្នាក់ៗបានត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួន ក៏ដូចជាក្រុមគ្រួសាររបស់ ទិត បាននាំគ្នាត្រឡប់មករស់នៅស្រុកកំណើតវិញ និងបានចាប់ផ្តើមកសាងជីវិតសាជាថ្មីដោយប្រកបមុខរបរធ្វើស្រែចម្ការ ។

ជាចុងក្រោយ ទិត សំណូមពរឲ្យតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមឲ្យបានកាន់តែឆាប់ ពីព្រោះមេដឹកនាំទាំងអស់នោះមានវ័យចំណាស់ៗទៅហើយ ។ ដូច្នេះមានតែតុលាការខ្មែរក្រហមទេដែលអាចស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះដែលបានបាត់បង់ជីវិតអស់ប្រមាណជាងពីរលាននាក់ ។ ជាពិសេសជាងនេះទៅទៀត ទិត បានបន្ថែមថា តុលាការនេះជាមេរៀនមួយសម្រាប់ក្មេងជំនាន់ក្រោយកុំឲ្យប្រព្រឹត្តអំពើដូចមេដឹកនាំទាំងនោះ ។

**ស៊ិន សុធីតា**




គរុនិស្សិតនៅក្នុងវគ្គបណ្តុះបណ្តាលស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ១៩៧៥-១៩៧៩ នៅវិទ្យាស្ថានជាតិអប់រំ

# តំបន់៥ជាកន្លែងដែលឪពុកម្តាយ យ៉ុង សម្បត្តិ ស្លាប់

យ៉ុង សម្បត្តិ សព្វថ្ងៃរស់នៅស្រុកថ្មគោល ខេត្តបាត់ដំបង ។ ទន្ទឹមនឹងការផ្ញើការទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងគោលបំណងផ្តល់ព័ត៌មានដែលទាក់ទងនឹងឈ្មោះបងប្អូនសាច់ញាតិដែលបាត់ខ្លួននិងស្លាប់ក្នុងសម័យខ្មែរក្រហមដើម្បីដាក់ឈ្មោះអ្នកទាំងនោះនៅក្នុងសៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលនឹងត្រូវបោះពុម្ពផ្សាយនាពេលខាងមុខ ។ សម្បត្តិ បានរៀបរាប់រឿងរ៉ាវខ្លះៗដែលទាក់ទងនឹងការស្លាប់និងបាត់ខ្លួនរបស់សមាជិកគ្រួសារគាត់ថា ៖

កាលជំនាន់ លន់ នល់ រស់នៅជាមួយឪពុកម្តាយនៅភូមិកំពង់សំណាញ់ ឃុំតាខ្មៅ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដោយគ្រួសារប្រកបរបរធ្វើស្រែចម្ការ ។ សម្បត្តិ មានបងប្អូនប្រាំមួយនាក់ ប្រុសបួននាក់ ស្រីពីរនាក់ ។

ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ សម្បត្តិ និងគ្រួសារត្រូវបានខ្មែរក្រហមជម្លៀសទៅស្រុកស្អាង ។ នៅទីនោះ បានបីខែ អង្គការបានបញ្ជូនបន្តតាមរថភ្លើងទៅខេត្តពោធិ៍សាត់ ។ មួយអាទិត្យក្រោយមក សម្បត្តិ និងគ្រួសារត្រូវបានអង្គការឲ្យធ្វើដំណើរបន្តទៅរហូតដល់ស្រុកសេរីសោភ័ណ ។ ពេលទៅដល់ទីនោះ អង្គការបានយកត្រាក់ទ័រមកដឹកទៅទម្លាក់នៅស្រុកភ្នំស្រុក ខេត្តបាត់ដំបង ។ ពេលទៅដល់ទីនោះភ្លាម បងប្រុសរបស់ សម្បត្តិ ត្រូវបានអង្គការចាត់តាំងឲ្យទៅដឹកអាងត្រពាំងថ្ម លើកប្រឡាយនៅតាមតំបន់៥ និងធ្វើនៅកងចល័តយុវជនតំបន់ ហើយក៏បាត់ដំណឹងរហូតតាំងពីពេលនោះមក ។ ពេលនោះហើយ ដែលសមាជិកគ្រួសាររបស់ សម្បត្តិ ត្រូវបាត់បង់ជាបន្តបន្ទាប់ ។

មួយរយៈក្រោយមក គ្រួសាររបស់គាត់ ក៏ដូចជាគ្រួសារឯទៀតដែរ ត្រូវខ្មែរក្រហមយករទេះគោទៅដឹកយកមកទម្លាក់នៅក្នុងព្រៃជ្រៅមួយហើយក៏បានបង្កើតទៅជាភូមិថ្មីមួយឈ្មោះថាភូមិមុខឈ្នាង ។ ពេលទៅដល់ភូមិមុខឈ្នាងនោះដំបូង ម្តាយរបស់ សម្បត្តិ ត្រូវបានអង្គការចាត់តាំងឲ្យធ្វើជាអ្នកដាំបាយនៅភូមិក្រោយមក អង្គការបង្កើតជាសហករណ៍ ក៏ទៅដាំនៅសហករណ៍វិញ ។ ដាំបាយនៅទីនោះ ម្តាយរបស់ សម្បត្តិ ខស្ប្រាហ៍លួចបាយក្តាំងខ្លះមកផ្ញើអ្នកផ្ទះណាស់ តែសំណាងមិនដែលខ្មែរក្រហមតាមទាន់ម្តងណាទេ ។

រស់នៅទីនោះមួយអាទិត្យ ឪពុករបស់ សម្បត្តិ យ៉ុង សុខ ត្រូវបានអង្គការហៅទៅរៀនសូត្រនៅមន្ទីរស្រុកភ្នំស្រុកប្រាំមួយខែ ។ ប៉ុន្មានខែក្រោយមក អង្គការបានមកជួបគ្រួសាររបស់ សម្បត្តិ ដោយប្រាប់ម្តាយគាត់ថា ប្រសិនបើចង់ទៅជួបប្តី ឬឪពុកលុះត្រាតែឆ្លើយសំណួរត្រឹមត្រូវឲ្យដូចនឹងចម្លើយរបស់ សុខ ឆ្លើយប្រាប់អង្គការតែបើឆ្លើយខុសគ្នានោះអង្គការនឹងសម្លាប់ សុខ ចោល ។ ហេតុតែចង់ជួបមុខប្តី ម្តាយរបស់គាត់ សួន សូត្រ សុខចិត្តឆ្លើយហើយបានត្រឹមត្រូវទៀតផង អង្គការក៏បាននាំគ្រួសាររបស់ សម្បត្តិ ទៅជួបឪពុកនៅមន្ទីរនោះ ។ គាត់មិនចាំទេថា កាលនោះអង្គការសួរពីអ្វី និងម្តាយឆ្លើយអ្វីខ្លះនោះទេ ព្រោះពេលនោះគាត់នៅក្មេងនៅឡើយ ។

រហូតដល់ឆ្នាំ១៩៧៧ អង្គការបានអនុញ្ញាតឲ្យឪពុករបស់ សម្បត្តិ មកជួបជុំគ្រួសារវិញ ។ ឪពុកគាត់បាននិយាយប្រាប់គ្រួសារឲ្យដឹងថា នៅការដ្ឋានការងារ គឺពិបាកខ្លាំងណាស់ បើចង់ហូបផ្អែត លុះត្រាតែហ៊ានប្រថុយជីវិតធ្វើពុតជាឈឺទៅសម្រាកនៅពេទ្យទើបបានហូប ។

នៅពាក់កណ្តាលឆ្នាំ១៩៧៧ ដោយភាពស្រេកឃ្លានខ្លាំងពេកបងប្រុសរបស់ សម្បត្តិ ឈ្មោះ យ៉ុង ម៉ៅ បានលួចកាច់អំពៅដែលដាំនៅមុខផ្ទះរបស់ខ្លួនហូប ថៃជន្យកងឈ្លបបីបួននាក់ឃើញទាន់ ក៏ចាប់វាយទាត់ធាក់យ៉ាងចាស់ដៃ កន្លងទៅប្រហែលជាបីថ្ងៃបងប្រុសរបស់គាត់បានស្លាប់ ដោយសារតែគ្រាំក្នុងខ្លាំងពេកនិងគ្មានថ្នាំព្យាបាលផង ។ នេះជាទិដ្ឋភាពមួយដក់នៅក្នុងចិត្ត សម្បត្តិ ដែលមិនបំភ្លេចបាន ។

នៅក្នុងឆ្នាំ១៩៧៨ ជាឆ្នាំដែលលំបាកវេទនារកអ្វីហូប

មិនបានទេ ដោយអំណាចនៃសេចក្ដីស្រេកឃ្លានហួសប្រមាណ ឪពុករបស់ សម្បត្តិ បានសម្រេចចិត្តដើរសំដៅទៅផ្ទះប្រធានភូមិ ដោយនិយាយជាមួយប្រធានភូមិនោះថា “សុំហូបបាយមួយវែ្តត ហើយយកគាត់ទៅណាក៏យកចុះ” ពេលនោះ មេភូមិឆ្លើយថា “មិនអីទេ! គាត់ឲ្យហូបតែត្រូវរៀបចំខ្លួនទៅចាំព្រឹកឡើងមកជួបគាត់” ។ លុះព្រឹកឡើង ឪពុករបស់ សម្បត្តិ បានរៀបចំខ្លួនហើយដើរសំដៅទៅផ្ទះប្រធានភូមិ ពេលទៅដល់ទីនោះមានកាណូតនៅចាំជាស្រេច ហើយឪពុកគាត់ត្រូវបានខ្មែរក្រហមចាប់បញ្ជូនចូលកាណូតនោះ យកទៅដាក់នៅភ្នំលៀប តំបន់៥ ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង (បច្ចុប្បន្នខេត្តបន្ទាយមានជ័យ) ។

កន្លងទៅមួយរយៈទើបបានដឹងថា ឪពុកគាត់ត្រូវបានខ្មែរក្រហមយកទៅសម្លាប់នៅភ្នំលៀបតាំងពីពេលនោះម៉្លេះ ។ ការស្លាប់របស់ឪពុក សម្បត្តិ គឺដឹងតាមរយៈមេភូមិនិយាយដោយផ្ទាល់មាត់នៅពេលដែលបងប្រុសម្នាក់ទៀតរបស់គាត់ឃ្លានខ្លាំងពេកក៏បានឡើងលួចបេះដូងហូប ហើយត្រូវបានពួកឈ្លបចាប់បានបញ្ជូនទៅឲ្យមេភូមិពេលនោះមេភូមិបានគំហកខ្លាំងៗដាក់បងគាត់ថា “ម៉េចអ្នែង! ចង់ងាប់ដូចឪពុកអ្នែងឬ? បានជាលួចស៊ីបែបនេះ?

នៅចុងឆ្នាំ១៩៧៨ ម្ដាយរបស់ សម្បត្តិ បានធ្លាក់ខ្លួនឈឺដោយជំងឺរាគមួលឈាមដោយគ្មានថ្នាំសង្កូវអ្វីព្យាបាលផងធ្វើឲ្យម្ដាយរបស់គាត់ឈឺកាន់តែធ្ងន់ទៅៗរហូតដល់ស្លាប់នៅឆ្នាំដដែល ។

ក្រោយរបបខ្មែរក្រហមបានដួលរលំ សមាជិកគ្រួសារបងប្អូនសាច់ញាតិរបស់ យ៉ុង សម្បត្តិ បានស្លាប់ និងបាត់ខ្លួនជាច្រើន ។ តាមរយៈការចូលរួមផ្ដល់ព័ត៌មានពីឈ្មោះបងប្អូនញាតិមិត្តដែលបានស្លាប់និងបាត់ខ្លួនក្នុងរបបខ្មែរក្រហមមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីចងក្រងជាសៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ក្នុងរបបខ្មែរក្រហម សម្បត្តិ សង្ឃឹមថាវិញ្ញាណក្ខន្ធជនរងគ្រោះទាំងនោះនឹងបានទៅកាន់សុគតិភព ជាពិសេសតាមរយៈសៀវភៅនេះក៏អាចជាភស្តុតាងមួយសម្រាប់ក្មេងៗជំនាន់ក្រោយដឹងថានៅក្នុងរបបខ្មែរក្រហមប្រជាជនខ្មែរជាច្រើនលាននាក់ពិតជាត្រូវបានស្លាប់ដោយការអត់ឃ្លានជំងឺ និងសម្លាប់ចោលពិតប្រាកដមែន ។

**ធាច សារៈមុនិន្ទ**



***ទំនប់អាងត្រពាំងថ្ម កសាងឡើងចាប់ពីឆ្នាំ១៩៧៧ និងបញ្ចប់នៅអំឡុងខែសីហា ឆ្នាំ១៩៧៨ ក្នុងរបបខ្មែរក្រហម ។ ការកសាងទំបន់នេះ បានបណ្ដាលឲ្យប្រជាជនជាច្រើនស្លាប់ដោយសារ អត់អាហារ ជំងឺ ការធ្វើការងារហួសកម្លាំង និងការចាប់យកទៅសម្លាប់ចោល ។ បច្ចុប្បន្ន ទំនប់អាងត្រពាំងថ្មស្ថិតនៅក្នុងឃុំណាំតាវ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ។***

# គ្រូបង្រៀនជាវិស្វករនៃចំណេះដឹង និងសីលធម៌សង្គម

គ្រូបង្រៀនប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជាគួរទទួលបានការទទួលស្គាល់ចំពោះសមត្ថភាពរបស់ខ្លួនមិនមែនត្រឹមតែការតស៊ូ ដើម្បីរួចរស់ជីវិតពីរបបខ្មែរក្រហមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការប្តេជ្ញាចិត្តនៅក្នុងការបង្រៀនប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍នេះទៅកាន់សិស្សរាប់លាននាក់ថែមទៀត ។ ដូច្នេះ ប្រទេសកម្ពុជាឈរប្រកបដោយមោទកភាពនៅចំពោះមុខពិភពលោកជាសាក្សីនៃការរស់រានឡើងវិញនៃមនុស្សជាតិនៅចំពោះមុខនៃអំពើឃោរឃៅដ៏រន្ធត់ ។

នៅថ្ងៃទី៥ ខែតុលា ជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ១៩៩៤មក ពិភពលោកបានប្រារព្ធពិធី «ទិវាគ្រូបង្រៀនពិភពលោក» ដើម្បីទទួលស្គាល់និងជាការដឹងគុណចំពោះគ្រូបង្រៀនដែលបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកសាងចំណេះដឹងនិងសម្រួចសីលធម៌សង្គមដល់សិស្ស ។ គ្រូបង្រៀនដើរតួនាទីជាច្រើននៅក្នុងអំឡុងពេលនៃការបង្រៀន ដូចជាអ្នកសម្របសម្រួល អ្នកសង្កេត អ្នកផ្តល់ប្រឹក្សា អ្នកថែរក្សា និង ជាគំរូមួយដែលរួមចំណែកយ៉ាងធំធេងដល់ការសិក្សាដោយខ្លួនឯងរបស់សិស្សក្នុងការត្រិះរិះពិចារណាវិន័យ សេចក្តីថ្លៃថ្នូរការអភិវឌ្ឍន៍ជាបុគ្គលនិងអាជីពនិងការកសាងអត្តចរិតនិងឥរិយាបថសង្គមរបស់ក្មេងជំនាន់ក្រោយ កុំថាឡើយដល់ទៅនិយាយអំពីកាតព្វកិច្ចរបស់គ្រូក្នុងការធ្វើការងារជាមួយសិស្សជាច្រើនដែលមានអត្តចរិតនិងកម្រិតនៃភាពឆ្លាតវៃខុសៗគ្នា ។ ជាងនេះទៅទៀត គ្រូបង្រៀនកសាងសិស្សឲ្យក្លាយទៅជាសិស្សល្អនៅក្នុងសាលាជាកូនល្អនៅឯផ្ទះ និងជាពលរដ្ឋល្អនៅក្នុងសង្គម ។ ដើម្បីទទួលស្គាល់តួនាទីនិងកិច្ចខិតខំប្រឹងប្រែងរបស់គ្រូបង្រៀនដែលមិនអាចកាត់ថ្លៃបាននេះ ខ្ញុំសូមហៅគ្រូបង្រៀនថាជា «វិស្វករនៃចំណេះដឹង និង សីលធម៌សង្គម» ។

គ្រូបង្រៀននៅក្នុងប្រទេសដែលហែកហួរទៅដោយ



គរុនិស្សិតធ្វើកិច្ចតែងការបង្រៀន ដើម្បីឡើងបង្រៀនសាកល្បងពីប្រវត្តិសាស្ត្រកម្ពុជា ប្រជាធិបតេយ្យ ពីឆ្នាំ១៩៧៥-៧៩ បង្ហាញដល់សិក្ខាកាមទាំងអស់

សង្គ្រាមនិងប្រទេសក្រោយអំពើប្រល័យពូជសាសន៍ដូចជាប្រទេសកម្ពុជាកាន់តែប្រឈមមុខនឹងបញ្ហាជាច្រើនថែមទៀតដែលមិនអាចជៀសបាន ។ ភ្លាមៗបន្ទាប់ពីងើបចេញពីបទពិសោធន៍ប្រកបដោយការឈឺចាប់និងដ៏សែនរន្ធត់ដែលមិនអាចថ្លែងបាននៅក្នុងរយៈកាលនៃរបបខ្មែរក្រហមកម្លាំងនិងការលើកទឹកចិត្តផ្នែករាងកាយនិងស្មារតីរបស់គ្រូត្រូវបានបំផ្លាញយ៉ាងខ្លាំងដោយការកម្ទេចផ្នែកស្មារតីដោយសារតែការបាត់បង់សមាជិកគ្រួសារជាទីស្រឡាញ់ និងដោយសារភាពចលាចលក្នុងសង្គមជាមួយនឹងការវាយឆ្មក់ពីសំណាក់កងទ័ពសេសសល់ខ្មែរក្រហម ។ ជាងនេះទៅទៀត បន្ថែមពីលើការដើរស្វែងរកសមាជិកគ្រួសារដែលបាត់ខ្លួន គ្រូបង្រៀនក៏ដូចជាប្រជាពលរដ្ឋកម្ពុជាទាំងមូលដែរ បានតស៊ូជាមួយនឹងការរស់រានមានជីវិតផ្នែកសេដ្ឋកិច្ចដែលរបបខ្មែរក្រហមបានបន្សល់ទុកនូវមូលដ្ឋានគ្រឹះស្ទើរស្ទើសូន្យដែលរបបដឹកនាំបន្ទាប់គឺរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាមានការលំបាកនៅក្នុងការកសាងប្រទេសជាតិ ប្រព័ន្ធអប់រំ និងហេដ្ឋារចនាសម្ព័ន្ធអប់រំឡើងវិញ ។ ទោះជាយ៉ាងនេះក្តី របបសាធារណរដ្ឋប្រជាមានិតកម្ពុជាទទួលជោគជ័យយ៉ាងលំបាកនៅក្នុងការដាក់ឲ្យដំណើរការឡើងវិញនូវការអប់រំកម្រិតបឋមសិក្សា ហើយគ្រូបង្រៀនបានលះបង់ពេលវេលា កម្លាំងកាយ និងចំណេះដឹងដែលនៅសេសសល់ដើម្បីបង្រៀនកូនចៅជំនាន់ក្រោយ ដែលបានបាត់បង់ឱកាសទទួលបានការអប់រំនៅក្នុងរបបខ្មែរក្រហមនិងដែលបានកើតក្រោយអំពើប្រល័យពូជសាសន៍ ។

នាពេលបច្ចុប្បន្ននេះ គ្រូបង្រៀនកាន់តែដើរតួនាទីសំខាន់ថែមទៀតនៅក្នុងការបង្ហាត់បង្រៀនសិស្សមិនមែនត្រឹមតែអំពីចំណេះដឹងទូទៅប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអំពីរបៀបនៅក្នុងការដោះស្រាយជាមួយនឹងអតីតកាលនៃអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសរបស់ខ្លួន ។ ចាប់ពីឆ្នាំ២០០៩រហូតមកដល់ពេលបច្ចុប្បន្ននេះ គ្រូបង្រៀនផ្នែកប្រវត្តិវិទ្យា ភូមិវិទ្យា អក្សរសាស្ត្រខ្មែរនិងសីលធម៌ពលរដ្ឋវិជ្ជាប្រមាណជាងបីពាន់នាក់បានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលជាកម្មវិធីដែលផ្តួចផ្តើមឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ។ នៅក្នុងខែឧសភា ឆ្នាំ២០១១ ក្រសួងអប់រំបានដាក់បញ្ចូលផ្នែកខ្លះនៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទៅក្នុងកម្មវិធីសិក្សាជាផ្លូវការ ។ ជាមួយនឹងបេសកកម្មថ្មីនេះ គ្រូបង្រៀនកំពុងចូលរួមនៅក្នុងការបង្ហាញប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍ប្រកបដោយការពិតឥតលម្អៀងដែលជាជំហានមួយឆ្ពោះទៅការថែរក្សាការចងចាំឧក្រិដ្ឋកម្មនៅក្នុងរបបខ្មែរក្រហម និងដើម្បីកសាងសេចក្តីស្រឡាញ់ការអត់ធ្មត់និងការអត់ឱនឲ្យគ្នា ។ នៅក្នុងការបង្រៀនប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍គ្រូបង្រៀនប្រកាន់ខ្ជាប់នូវគោលការណ៍ក្នុងការដឹកនាំសិស្សឲ្យចាកឆ្ងាយពីគំនិតស្អប់ខ្ពើម ការខឹងសម្បារហិង្សានិងការគុំគួន ។ នៅក្នុងន័យនេះ គ្រូបង្រៀន រួមចំណែកយ៉ាងធំធេងដល់ការផ្សះផ្សាជាតិនិងការកសាងសន្តិភាពជានិរន្តរ៍នៅក្នុងប្រទេសកម្ពុជាតាមរយៈការអប់រំដែលជាយន្តការអហិង្សាជាសកលមួយដែលប្រទេសជាច្រើនបានទទួលយកទៅអនុវត្ត ។ ដោយពិចារណាអំពីគុណតម្លៃនិងតួនាទីមិនអាចកាត់ថ្លៃបានរបស់គ្រូបង្រៀន ខ្ញុំឆ្លៀតយកឱកាសទិវាគ្រូបង្រៀនពិភពលោកថ្ងៃទី៥ ខែតុលា ឆ្នាំ២០១២នេះ ថ្លែងអំណរគុណដល់អតីតនិងគ្រូបង្រៀននាពេលបច្ចុប្បន្នចំពោះការខិតខំប្រឹងប្រែងមិនចេះនឿយហត់របស់ខ្លួនក្នុងការចូលរួមកសាងប្រទេសជាតិនិងការអប់រំប្រកបដោយសុទិដ្ឋិនិយម ។ ជាថ្មីម្តងទៀត គ្រូបង្រៀនគឺពិតជា «វិស្វករនៃចំណេះដឹងនិងសីលធម៌សង្គម» ។

**ឌី ខាំបូលី**

## សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ១៩៧៥-១៩៧៩» ចាប់តាំងពីឆ្នាំ២០០៧មកនិងបានចែកចាយដល់សិស្ស-និស្សិតនិងសាធារណជនទូទាំងប្រទេសជាងមួយនាក់ ។ ជាមួយគ្នានោះដែរ សៀវភៅនេះត្រូវបានបកប្រែជាច្រើនភាសា ហើយអាចរកបានតាមរយៈ

*http://dccam.org/Projects/Genocide/A Hisotry of DK 2007.htm*

# ប្រវត្តិសាស្ត្រគឺសម្រាប់បទពិសោធន៍



ហ៊ឹម ភារុន អាយុ ២៥ឆ្នាំមានស្រុកកំណើតនៅស្រុកស្វាយទាប ខេត្តស្វាយរៀង ។ ភារុនជាកូនទីបីក្នុងចំណោមបងប្អូនប្រុសស្រីប្រាំពីរនាក់ ដោយមានឪពុកម្តាយជាអ្នកធ្វើស្រែចម្ការ ។ សព្វថ្ងៃ គាត់មកភ្នំពេញដើម្បីបន្តថ្នាក់គរុនិស្សិតផ្នែកប្រវត្តិវិទ្យានៅវិទ្យាស្ថានជាតិអប់រំ ។ ការដែលសម្រេចចិត្តជ្រើសរើសយកមុខវិជ្ជាប្រវត្តិវិទ្យានេះ ព្រោះពេលដែលគាត់សិក្សានៅវិទ្យាល័យគឺចូលចិត្តរៀនមុខវិជ្ជានេះ ហើយគិតថាមុខវិជ្ជានេះល្អសម្រាប់ការយល់ដឹងខ្លួនឯងជាពិសេសគឺអាចអប់រំកូនសិស្សដើម្បីឲ្យយល់អំពីប្រវត្តិសាស្ត្ររបស់ខ្លួន ។ លើសពីនេះទៀត កាលណាយើងដឹងអំពីប្រវត្តិសាស្ត្ររបស់ខ្លួនឯង គឺយើងអាចស្រង់យកចំណុចល្អៗ ហើយចំណុចអាក្រក់ចាត់ទុកជាបទពិសោធន៍សម្រាប់ឲ្យយើងជៀសវាង ។

ជាងនេះទៅទៀត ការដែលបានចូលរួមវគ្គបណ្តុះបណ្តាលគរុនិស្សិតស្តីអំពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ( ១៩៧៥-១៩៧៩) នេះ ភារុន យល់ថា ពិតជាសំខាន់ណាស់ ទោះបីជាគាត់ធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលនេះម្តងហើយក៏ដោយ ក៏គាត់នៅតែចូលរួមម្តងទៀត ព្រោះ ភារុន គិតថាពិតជាមានសារសំខាន់ខ្លាំងណាស់ទាក់ទងទៅនឹងរបត់ប្រវត្តិសាស្ត្រហើយជាពិសេសចំពោះយើងដែលជាគ្រូបង្រៀនត្រូវតែយកបទពិសោធន៍ទៅផ្សព្វផ្សាយអប់រំដល់សិស្សានុសិស្ស ។ ភារុន បានបន្តទៀតថា មានមតិមួយចំនួនលើកឡើងថា ហេតុអ្វីយករឿងរ៉ាវនៃរបបខ្មែរក្រហមមកបង្រៀន? ឬក៏រំពុកឡើងវិញធ្វើអ្វី? ព្រោះនាំឲ្យមានការឈឺចាប់ ប៉ុន្តែចំពោះ ភារុន យល់ថាតាមរយៈ ការអប់រំ ឬក៏វគ្គបំណាងនៅក្នុងការអប់រំនៃប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យគឺមិនបានបង្ហាញឲ្យឃើញភាពឈឺចាប់ប៉ុន្មានទេ គ្រាន់តែចង់ឲ្យអ្នកសិក្សាទាំងឡាយយល់ដឹងអំពីប្រវត្តិសាស្ត្រនៃរបបនេះ ដើម្បីទុកជាបទពិសោធន៍ ហើយទាំងនេះក៏ជាការផ្សះផ្សារបួសផ្លូវចិត្តសម្រាប់ជនរងគ្រោះដែរ ។ ហេតុនេះការសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហមគឺពិតជាមានសារសំខាន់ចំពោះក្មេងៗជំនាន់ក្រោយឲ្យបានដឹងថានៅក្នុងរបបខ្មែរក្រហមលំបាកវេទនាយ៉ាងណា ដើម្បីឲ្យអ្នកទាំងនោះជៀសវាងនិងទប់ស្កាត់កុំឲ្យអំពើនេះកើតមានឡើងម្តងទៀត ។

ជាក់ស្តែងរូប ភារុន ផ្ទាល់ កើតមិនទាន់ជំនាន់ខ្មែរក្រហមទេ តែគាត់បានដឹងរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបនោះមួយចំនួនតាមរយៈការនិយាយប្រាប់ពីសំណាក់ឪពុកម្តាយ ។ ស្ថិតក្នុងទឹកមុខស្រពោនបន្តិចពេលដែលរំពុកដល់សម័យខ្មែរក្រហម ភារុន បានរៀបរាប់ពីប្រវត្តិម្តាយរបស់គាត់ខ្លះៗដែលបានឆ្លងកាត់ក្នុងរបបខ្មែរក្រហម ។

នៅក្នុងអំឡុងឆ្នាំ១៩៧៣-១៩៧៤ គ្រួសាររបស់ម្តាយគាត់ដែលមានសមាជិកទាំងអស់ជាងដប់នាក់រស់នៅស្រុកស្វាយទាប ខេត្តស្វាយរៀង ដែលជាតំបន់រំដោះរបស់ខ្មែរក្រហម ហៅថាភូមិភាគបូព៌ា ។ ដោយសារនៅតំបន់រំដោះមានភាពលំបាកមិនសូវសម្បូរសប្បាយ នៅចុងឆ្នាំ១៩៧៤ គ្រួសារម្តាយរបស់ ភារុន បានរត់មកភ្នំពេញ ។ បន្ទាប់ពីខ្មែរក្រហមទទួលបានជ័យជម្នះនៅថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ គ្រួសារម្តាយ ភារុន ត្រូវបានជម្លៀសទៅខេត្តពោធិ៍សាត់ ។ ពេលជម្លៀសម្តាយគាត់មានអាយុទើបតែដប់ឆ្នាំប៉ុណ្ណោះ ។ ម្តាយរបស់គាត់បានប្រាប់ថានៅខាងខេត្តពោធិ៍សាត់គឺមានការលំបាកណាស់ ដោយសារខ្វះទឹកហើយប្រជាជនដែលជម្លៀសទៅភាគច្រើនខ្មែរក្រហមយកទៅរស់នៅតំបន់ភ្នំដោយឲ្យវាយភ្នំយកថ្មនិងរែកថ្ម ។ ទោះបីជានៅកុមារ ក៏ខ្មែរក្រហមចាត់តាំងឲ្យទៅរែកថ្មដែរ ។ ពេលទៅដល់ទីនោះបានមួយរយៈក្រោយមក

អង្គការបានយកអីប្រុសដែលត្រូវជាបងថ្លៃរបស់ម្តាយ ភារុន យកទៅរៀនសូត្រ ប៉ុន្មានថ្ងៃក្រោយមក កងឈ្លបក៏បានមកយកទាំងប្រពន្ធនិងកូនពីរនាក់ទៀត ។ ពេលដែលឃើញកងឈ្លបមកដល់អីស្រីរបស់ ភារុន បានដឹងស្រេចទៅហើយថា នឹងគ្មានថ្ងៃវិលត្រឡប់មករកបងប្អូនវិញទេ ។ គាត់បានត្រឹមតែងាកមកសម្លឹងមុខប្អូនស្រី (ម្តាយ ភារុន) ដោយទឹកភ្នែករលីងរលោងប៉ុណ្ណោះ ។ ទាក់ទងនឹងការហូបចុកនៅពោធិ៍សាត់ ឆ្នាំដំបូងពេលដែលទៅគឺទទួលបានរបបអាហារជាបាយជ្រាយ ប៉ុន្តែដល់ឆ្នាំ១៩៧៨ គឺលែងមានបាយទៀតហើយ មានតែបបររាវៗ ដូច្នេះម្តាយគាត់ត្រូវហូបបបរជាមួយស្លឹកឈើ ។ ចំពោះការធ្វើការងារនៅទីនោះគឺធ្វើការជាទម្ងន់ មិនមានពេលសម្រាកច្រើនទេ ។ ពេលឈឺថ្កាត់ម្តងៗ ក៏គ្មានថ្នាំអ្វីលេបដែរ ក្រៅពីថ្នាំអាចម៍ទន្សាយនោះ ឈឺអ្វីក៏លេបថ្នាំហ្នឹងដែរ ។ ដូច្នេះដើម្បីជាជំងឺម្នាក់ៗមានតែស្វែងរកផ្សំថ្នាំដោយខ្លួនឯងដូចជា សកសំបកឈើមកដាំផឹកជាដើម ។ គ្រួសារម្តាយគាត់រស់នៅខេត្តពោធិ៍សាត់រហូតដល់ថ្ងៃវៀតណាមរំដោះ ។ គាត់បន្តទៀតថា ពេលនៅតាមផ្លូវត្រឡប់មកស្រុកកំណើតវិញគាត់ឆ្លងកាត់ទីក្រុងភ្នំពេញ ពេលនោះមិនទាន់មានមនុស្សច្រើនទេ ហើយមានផ្ទះទំនេរជាច្រើន ប៉ុន្តែមិនបានគិតថាចង់នៅភ្នំពេញទេ គឺបំណងប្រាថ្នាតែមួយគត់របស់ម្តាយគាត់ធ្វើយ៉ាងណាឲ្យបានឆាប់ទៅដល់ស្រុកកំណើត ។ ក្រោយរបបខ្មែរក្រហមបានដួលរលំ សមាជិកគ្រួសាររបស់ម្តាយ ភារុន បានស្លាប់ចំនួនប្រាំនាក់ និងបាត់ខ្លួនចំនួនពីរនាក់ ។

ទោះបីជា ភារុន ជាក្មេងជំនាន់ក្រោយ តែបើនិយាយពីការរើសអើងចំពោះកូនរបស់អតីតកម្មាភិបាលខ្មែរក្រហមក៏ដូចជាកម្មាភិបាលខ្មែរក្រហមផ្ទាល់គឺមិនមានការរើសអើងនោះទេ ។ ភារុន បានផ្តល់ជាទស្សនៈមួយថា អ្នកដែលប្រព្រឹត្តគឺ ឪពុកម្តាយរបស់អ្នកទាំងនោះ ហើយបើនិយាយទៅតាមផ្លូវច្បាប់អ្នកដែលធ្វើខុសគឺត្រូវទទួលខុសដោយខ្លួនឯង ហើយកូនៗទាំងនោះ ក៏ជាអ្នកមិនដឹងអីដែរ ហេតុដូចនេះ យើងមិនអាចរើសអើងចំពោះអ្នកទាំងនោះទេ ។ ម្យ៉ាងវិញទៀត ចំពោះអតីតកម្មាភិបាលទាំងអស់នោះ ភារុន យល់ថារាល់ទង្វើដែលអ្នកទាំងនោះបានប្រព្រឹត្តភាគច្រើនមិនបានធ្វើដោយចិត្តខ្លួនឯងនោះទេ មានន័យថារាល់កម្មាភិបាលខ្មែរក្រហមទាំងអស់មិនមែនសុទ្ធតែអាក្រក់ទេ គឺអ្នកទាំងនោះអាចនឹងមានផលវិបាករបស់ខ្លួន ។

ដូចបានរៀបរាប់ខាងលើ ការសិក្សាពីប្រវត្តិសាស្ត្រគឺពិតជាមានសារសំខាន់ណាស់ ។ យើងរស់នៅសង្គមមួយប្រទេសមួយ គួរតែស្គាល់ពីប្រវត្តិសាស្ត្ររបស់ខ្លួនឲ្យបានច្បាស់លាស់ ហើយត្រូវចេះទាញយកនូវចំណុចល្អៗដែលអាចធ្វើឲ្យប្រទេសរីកចម្រើនទៅមុខនិងសិក្សាពីចំណុចអវិជ្ជមានទាំងឡាយដែលធ្វើឲ្យប្រទេសជួបនូវឱនភាព ហើយចាត់ទុកចំណុចនោះជាបទពិសោធន៍ដើម្បីជាការជៀសវាងកុំឲ្យកើតមានឡើងម្តងទៀត ។ ជាក់ស្តែងរបបខ្មែរក្រហមគឺជាប្រវត្តិសាស្ត្រដ៏ជូរចត់មួយសម្រាប់ប្រទេសកម្ពុជា ហេតុនេះក្មេងជំនាន់ក្រោយក៏ដូចជាអ្នកសិក្សាទាំងឡាយគួរតែសិក្សាឲ្យបានស៊ីជម្រៅពីប្រវត្តិសាស្ត្រមួយនេះតើវាមានផលប៉ះពាល់ឬក៏បណ្តាលឲ្យមានផលវិបាកអ្វីខ្លះសម្រាប់ប្រជាជនក៏ដូចជាប្រទេសជាតិទាំងមូល ។



ហឹម ភារុន នៅក្នុងវគ្គបណ្តុះបណ្តាលស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅវិទ្យាស្ថានជាតិអប់រំ

**ធាវ សារៈមុនិន្ទ**

# គោះត្រលក្នុងសម័យខ្មែរក្រហម


ស៊ឹម នី

ស៊ឹម នី អតីតយោធាកងការពារដែនសមុទ្រនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងធ្លាប់បានចូលរួមសមរភូមិវាយដណ្តើមយកកោះត្រលពីប្រទេសវៀតណាមវិញ។ នី សព្វថ្ងៃមានអាយុ៥៩ឆ្នាំ មានប្រពន្ធឈ្មោះ ម៉ែន សាង ព្រមទាំងមានកូនប្រុសបីនាក់។ នី មានឪពុកឈ្មោះ ហ៊ីង រស់ ម្តាយឈ្មោះ អ៊ុយ នៅ និងមានបងប្អូនប្រាំពីរនាក់។ នី មានស្រុកកំណើតនៅភូមិខ្សាច់លុប ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ។ នី កាលពីនៅកុមារភាពរៀនបានត្រឹមថ្នាក់ទី៨ "ចាស់" នៅសាលាបឋមសិក្សាក្រាំងស្វែង។ នី បានសម្រេចចិត្តឈប់រៀននៅឆ្នាំ១៩៦៨ ដោយសារគ្រួសារមានជីវភាពខ្វះខាត។ ក្រោយពីឈប់រៀន នី បានជួយធ្វើស្រែចម្ការឪពុកម្តាយ និងឡើងត្នោត ដើម្បីដោះស្រាយជីវភាពក្នុងគ្រួសារ។

នៅថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០ កើតមានរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ទាំងមន្ត្រីរាជការ និងប្រជាជនមួយចំនួនធំមិនសប្បាយចិត្តចំពោះរដ្ឋាភិបាលថ្មីទេ តែបែរជាមានទឹកចិត្តស្មោកទៅរកសម្តេចព្រះនរោត្តម សីហនុ ទៅវិញ។ ប្រជាជននៅស្រុកស្រែចម្ការមិនបានហាមកូនចៅមិនឲ្យធ្វើការតស៊ូជាមួយរណសិរ្សរួបរួមជាតិកម្ពុជាទេ ថែមទាំងជំរុញកូនចៅឲ្យចូលព្រៃម៉ាគីថែមទៀត។ នី បានស្ម័គ្រចិត្តចូលព្រៃធ្វើជាយោធាខ្មែរក្រហម នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៧២ រួមទាំងមិត្តភក្តិប្អូននាក់ទៀត។ នី ចូលដំបូងនៅស្រុកបាទីរួចហើយធ្វើសកម្មភាពតាមបណ្តោយផ្លូវជាតិលេខ៣ និងលេខ៤។

នៅឆ្នាំ១៩៧៤ អង្គការជ្រើសរើស នី ឲ្យមកនៅទ័ពភូមិភាគនិរតី កងពលទី២ ដែលមានប្រធានកងពលឈ្មោះ សំ ប៊ិត, វ៉ែន និងលេខាភូមិភាគឈ្មោះ តាម៉ុក។ ពេលឡើងមកកងទ័ពភូមិភាគ នី ធ្វើសកម្មភាពតាមផ្លូវជាតិលេខ២, ៣, ៤ និងលេខ៥ វាយជាមួយទាហាន លន់ នល់ ដោយក្នុងមួយរដូវប្រាំងស្លាប់យោធាខ្មែរក្រហមអស់ជាង១០០នាក់។ នៅពាក់កណ្តាលឆ្នាំ១៩៧៤ យោធាខ្មែរក្រហមទាំងអស់វាយសម្រុកទីក្រុងភ្នំពេញទ្រង់ទ្រាយធំ គឺវាយផ្តាច់ផ្លូវថ្នល់ ផ្តាច់ស្ពាន និងធ្វើសកម្មភាពគ្រប់បែបយ៉ាងដែលអាចធ្វើបានដើម្បីធ្វើយ៉ាងណាកុំឲ្យខាងទាហាន លន់ នល់ ដឹកគ្រឿងសព្វាវុធ ឬស្បៀងអាហារឲ្យកងទ័ពរបស់ខ្លួនបាន។ រីឯខាងខ្មែរក្រហមគ្មានខ្វះខាតទេ ព្រោះមានប្រជាជនជួយផ្តល់ស្បៀងអាហារគ្រប់គ្រាន់។

នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ យោធាជាច្រើនកងពលបានវាយចូលដល់ទីក្រុងភ្នំពេញនៅម៉ោងប្រាំបីព្រឹកដោយគ្មានការតបតពីទាហាន លន់ នល់ ឡើយ។ ពេលនោះប្រជាជនបានចាកចេញពីផ្ទះសម្បែងបណ្តើរៗដើម្បីទៅកាន់ស្រុកស្រែចម្ការ ឬស្រុកកំណើតវិញ។ នី បានសម្រាកនៅទីក្រុងបានមួយយប់ អង្គការដកគាត់មកនៅម្តុំកំបូលខាងលិចទីក្រុងភ្នំពេញ ហើយរយៈពេលបីថ្ងៃក្រោយមកអង្គការដកគាត់ទៅកំពង់សោមបន្តទៀត។ ពេលមកដល់ក្រុងកំពង់សោមមានយោធាខ្មែរក្រហមជាច្រើនត្រូវបានអង្គការជ្រើសរើសចេញមកពីគ្រប់កងពលបង្កើតទៅជាកងពលថ្មីមួយទៀតគឺកងពល១៦៤ដែលមានប្រធានកងពលឈ្មោះ មាស មុត, ឌីម និង ជា គ្រិន។ នៅឆ្នាំ១៩៧៥ របបកម្ពុជាប្រជាធិបតេយ្យមានមោទកភាពខ្លាំងណាស់ថា ខ្លួនមានកម្លាំងរឹងមាំចង់ធ្វើអ្វីក៏បាន។ យោធាខ្មែរក្រហមភាគច្រើនសុទ្ធតែក្មេងៗមិនសូវមានបទពិសោធន៍មិនបានរៀនសូត្រច្បាប់សង្គ្រាមទេ។

ពេលទទួលជ័យជម្នះថ្មីៗ មុនដំបូងខ្មែរក្រហមឲ្យទាហាន លន់ នល់ ជួយបង្រៀនបើកបរកប៉ាល់ ហើយបន្ទាប់ពីចេះបើកហើយ ទាហានលន់នល់ទាំងនោះបាត់ខ្លួនតែម្តង ។ យោធាខ្មែរក្រហមមួយចំនួនឈរជើងនៅក្រុងកំពង់សោម មួយចំនួនទៀតទៅការពារកោះរបស់ខ្មែរជាច្រើនកន្លែង ដូចជាកោះ ប៉ូលូវៃ កោះរុង កោះសេះ កោះថ្មី និង កោះតាង ។ កងទ័ពខ្មែរក្រហមការពារដែនសមុទ្របានឃើញកប៉ាល់មួយយ៉ាងធំឈ្មោះ "ម៉ាយ៉ាហ្គេ" ដែលបើកលើដែនសមុទ្រអន្តរជាតិ តែកងយោធាខ្មែរក្រហមការពារនៅទីនោះថា កប៉ាល់នោះបានបើកបររំលោភលើដែនសមុទ្រខ្មែរ កម្លាំងខ្មែរក្រហមបានបាញ់ស្កាត់កប៉ាល់នោះមិនឲ្យទៅមុខបន្តទៀត រួចហើយនាំយកមកក្រុងកំពង់សោម តែមិនបានចូលដល់ឆ្នេរទេ ព្រោះកប៉ាល់នោះធំ ។

បន្ទាប់ពីទទួលបានព័ត៌មាននោះ វិទ្យុផ្សាយសំឡេងរបស់អាមេរិកបានផ្សាយថា បើខាងខ្មែរក្រហមមិនព្រមដោះលែងកប៉ាល់ម៉ាយ៉ាហ្គេទេ សហរដ្ឋអាមេរិកនឹងធ្វើការវាយប្រហារមកលើប្រទេសកម្ពុជា ។ ពេលនោះ ខ្មែរក្រហមបានដោះស្រាយនិងលែងកប៉ាល់នោះទៅវិញ ប៉ុន្តែយន្តហោះរបស់សហរដ្ឋអាមេរិកនៅតែបន្តទម្លាក់គ្រាប់បែកធ្វើឲ្យខូចខាតកន្លែងមួយចំនួននៅក្រុងកំពង់សោម ។

ក្រោយមកទៀតដោយខ្មែរក្រហមមានភាពក្លាហានចង់ការពារទឹកដី ខ្មែរក្រហមមានគំនិតចង់បានកោះមួយចំនួននៅដែនសមុទ្រដែលបានបាត់បង់ពីមុនមក ។ នៅខែឧសភា ឆ្នាំ១៩៧៥ ថ្នាក់ដឹកនាំជាន់ខ្ពស់ក្នុងសម័យខ្មែរក្រហមមានបំណងវាយយកកោះត្រល់ពីវៀតណាមមកវិញ ព្រោះកោះត្រល់ ជារបស់ខ្មែរតែវៀតណាមបានមករស់នៅជាយូរណាស់មកហើយ ។ ដូចនេះយោធាខ្មែរក្រហមដែលការពារដែនសមុទ្រមាន មាស មុត ជាប្រធានកងពលបានដាក់បញ្ជាកងទ័ពរបស់ខ្លួនចំនួន៣០០នាក់ឲ្យទៅវាយយកកោះត្រល់មកវិញឲ្យបាន តែការគិតរបស់ថ្នាក់លើដូចជាយកជីវិតយោធាទាំងនោះទៅប្រថុយក្នុងភាពគ្រោះថ្នាក់ ។ កម្លាំងខ្មែរក្រហម៣០០នាក់ ដឹកនាំដោយប្រធានវរសេនាតូចឈ្មោះ បូ បានជិះទូកតូចៗជាច្រើនគ្រឿងសំដៅទៅកាន់កោះត្រល់ ខ្លះមានពោង ខ្លះមានប៊ីដុងទឹកសម្រាប់ហែលពេលមានបញ្ហាកើតឡើង ។ យោធាខ្មែរក្រហមទាំងនោះមានកាំភ្លើងគ្រប់ដៃ និងមានកាំភ្លើងធុនធ្ងន់មួយចំនួនទៀត តែមិនបានស្គាល់ភូមិសាស្ត្រច្បាស់លាស់ទេ ព្រោះកោះត្រល់មានទំហំធំនិងមិនដឹងថាកងទ័ពវៀតណាមដាក់កាំភ្លើងការពារត្រង់ណាខ្លះទេ ។

យោធាខ្មែរក្រហមចូលស៊ើបការលើកោះត្រល់បានបីថ្ងៃដោយមិនទាន់ហ៊ានផ្ទុះអាវុធទេ តែសំណាងអាក្រក់ កងទ័ពការពារដែនសមុទ្ររបស់វៀតណាមបានឃើញដានជើងយោធាខ្មែរក្រហមឡើងទៅលើកោះត្រល់ដូចនេះកងទ័ពវៀតណាម ធ្វើការប្រកាសអាសន្នហ៊ុមព័ទ្ធចាប់ទាហានខ្មែរក្រហមបានស្ទើរទាំងអស់នៅសល់តែជាង៣០នាក់ប៉ុណ្ណោះដែលរត់ចុះហែលទឹកត្រឡប់មកវិញបាន ។

នី បានផ្លែដូងទុំឱបហែលទឹកចាកចេញឆ្ងាយរួចគាត់បាញ់ជាសញ្ញាឲ្យយោធាខ្មែរក្រហមមកជួយ ។ ក្រោយមក នី បានដឹងថាកងកម្លាំងខ្មែរក្រហមដែលមានបំណងវាយយកកោះត្រល់នោះត្រូវបានកងទ័ពវៀតណាមចាប់បានទាំងអស់ ។ ក្រោយពីវៀតណាមចាប់បានកងទ័ពខ្មែរក្រហម ប៉ុល ពត បានធ្វើសន្និបាតនៅស្តាតអូឡាំពិកថា កម្ពុជាត្រូវធ្វើការដោះដូរជាមួយប្រទេសវៀតណាមដើម្បីយកកងទ័ពទាំងនោះមកវិញដោយទទួលស្គាល់ព្រំដែន និងលែងមានកងទ័ពកម្ពុជាចូលទៅកោះត្រល់ទៀតហើយ ។ តាំងពីនោះមកយោធាខ្មែរក្រហមបានត្រឹមតែសម្លឹងមើលកោះត្រល់ពីចម្ងាយតែប៉ុណ្ណោះ ។

ផង់ អឹង អាយុ៥៥ឆ្នាំ មានស្រុកកំណើតនៅភូមិចិន ឃុំស្ដេចគង់ ស្រុកទូកមាស ខេត្តកំពត ។ ជំនាន់ខ្មែរក្រហម អឹង មានតួនាទីជាយោធាការពារដែនសមុទ្រតំបន់៣៥ (ខេត្តកំពត) ។ អង្គការបានចាត់តាំង អឹង ឲ្យការពារដែនសមុទ្រជាច្រើនកន្លែងដូចជាកោះសេះ កោះអង្ក្រង កោះពោធិ៍ កោះស្វាយជាដើម លើកលែងតែកោះត្រល់មួយគត់ដែលយោធាខ្មែរក្រហមមិនហ៊ានចូលទៅជិតព្រោះប្រជាជននិងកងទ័ពវៀតណាមបានមករស់នៅជាយូរមកហើយ ។

កងកម្លាំងការពាររាប់រយនាក់របស់ខ្មែរក្រហមបានត្រឹមតែសម្លឹងមើលកោះត្រល់ជារៀងរាល់ថ្ងៃពីចម្ងាយ ។ កាលនោះ អឹង គ្រាន់តែបានដឹងថា កាលពីមុនកោះត្រល់ជារបស់ខ្មែរដែលបានបាត់បង់ទៅ ។

**សុខ ខណ្ណះ**

# បរិស្ថានជាតិ : ដី ទឹក ភ្លៀង ខ្សែភាពយន្តរឿង "ក្បាច់ទឹកទន្លេ"



## មានបញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃសុក្រ

*ពីរដងក្នុងមួយឆ្នាំ ចរន្តលំហូរទឹកនៃបឹងទន្លេសាបធ្វើការផ្លាស់ប្តូរទិសដៅរបស់វា ដែលយើងអាចប្រដូចទៅនឹងលំហូរនៃខ្សែជីវិតរបស់មនុស្សដែលឆ្លងកាត់ការកើត ចាស់ ឈឺ ស្លាប់ ។ ម៉ម កល្យាណី គឺជានាយកផ្នែករូបថតនៅក្នុងខ្សែភាពយន្តឯកសារហូលីវូដ ក្រោមចំណងជើងថា "INSIDE JOB" ដែលខ្សែភាពយន្តនេះទទួលបានពានរង្វាន់អូស្ការហូលីវូដនៅសហរដ្ឋអាមេរិក ។ ម៉ម កល្យាណី បានចំណាយពេលជាងពីរឆ្នាំនៅស្រុកកំណើតរបស់ខ្លួនគឺប្រទេសកម្ពុជាដើម្បីតាមដានខ្សែជីវិតប្រជាជនកម្ពុជាបីរូបដែលរស់នៅក្រោមឥទ្ធិពលនៃការកាប់ឆ្ការព្រៃឈើ ការនេសាទត្រីហួសកម្រិត និងប្រាក់បំណុល ។*

*នៅកណ្តាលព្រៃភ្នំដាច់ស្រយាលនៃភាគឦសានប្រទេសកម្ពុជា សាវ សាមួន រស់នៅជាមួយគ្រួសារក្នុងខ្ទមស្បូវមួយខ្នងសង់នៅលើជម្រាលភ្នំ ដែលព័ទ្ធជុំវិញដោយចម្ការស្វាយចន្ទី វាលស្រែពណ៌ខៀវស្រងាត់ និងព្រៃដ៏ក្រាស់នៃតំបន់ឦសាន ។ សាមួន និងក្រុមគ្រួសារគឺជាជនជាតិភាគតិចមួយក្នុងចំណោមជនជាតិភាគតិចទាំងម្ភៃបួនក្រុមដែលកំពុងមានវត្តមាននៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃ ដែលរស់នៅដោយពឹងផ្អែកលើដី និងធនធានព្រៃឈើដើម្បីចិញ្ចឹមជីវិត ។ នៅជុំវិញខ្លួន សាមួន និងក្រុមគ្រួសារបានឃើញដោយផ្ទាល់ភ្នែកនូវការរុករានទន្ទ្រានដីធ្លីពីសំណាក់ក្រុមហ៊ុនធំៗ ការកាប់ឆ្ការ និងការកាប់បំផ្លាញព្រៃឈើ ។ សាមួន ដឹងខ្លួនឯងថាគាត់លែងខ្លាចសត្វព្រៃកាចសាហាវ និងខ្មោចទៀតហើយ ដែលធ្លាប់តែដើរត្រាច់ចរក្នុងព្រៃដែលជាលំនៅដ្ឋានរបស់ សាមួន ។ ពេលនេះ សាមួន បែរជាមកខ្លាចមនុស្សទៅវិញ ។*

*បឹងទន្លេសាបដែលមានទីតាំងនៅភាគកណ្តាលប្រទេសកម្ពុជាគឺជាជម្រកត្រីនិងជីវចម្រុះគ្រប់ប្រភេទ ។ ភូមិនេសាទនៅលើទន្លេគឺជាទីលំនៅដ្ឋានរបស់ សារី និងគ្រួសារដែលរស់នៅដោយពឹងផ្អែកលើរបរនេសាទដើម្បីចិញ្ចឹមជីវិត ។ ជាកូនច្បងនៅក្នុងគ្រួសារដែលមានបងប្អូនប្រាំមួយនាក់ សារី ត្រូវបង្ខំចិត្តបោះបង់ចោលការសិក្សាក្នុងវ័យ១៤ឆ្នាំដើម្បីជួយរកស៊ីចិញ្ចឹមគ្រួសារ ។ ជីវិតនៅលើផ្ទៃទឹកបានផ្លាស់ប្តូរយ៉ាងឆាប់រហ័សដោយសារតែចំនួនត្រីមានការធ្លាក់ចុះយ៉ាងគំហុក ការដាក់ឧបករណ៍ធំៗដើម្បីចាប់ត្រីនិងកំណើននៃការនេសាទត្រីខុសច្បាប់ ធ្វើឲ្យរបររកត្រីក៏ធ្លាក់ចុះដែរ ។ សារី និងគ្រួសារបានតស៊ូយ៉ាងលំបាកលំបិនដើម្បីរកត្រីសម្រាប់បរិភោគប្រចាំ*

ថ្ងៃ ។ នៅពេលដែល សារី ឈរនៅលើទូករបស់ខ្លួន ហើយក្អែកសម្លឹងទៅរកផ្ទៃទឹកដ៏ធំល្វឹងល្វើយ ដាច់កន្ទុយភ្នែកជាមួយនឹងចិត្តនឹកភ្នក់ឆ្ងល់ថាតើអនាគតរបស់ខ្លួននឹងត្រាច់ចរទៅរកទិសខាងណា ។

ក្នុងភូមិដ៏តូចមួយមិនឆ្ងាយប៉ុន្មានពីរាជធានីភ្នំពេញ ខៀវ ហើយនិងម្តាយកំពុងតែប្រមូលផលស្រូវប្រចាំឆ្នាំ ។ ដើម្បីសម្រេចបានកិច្ចការងារស្រែចម្ការ ខៀវ និងម្តាយបានទៅខ្ចីបុលគេដើម្បីយកលុយទៅទិញដីស្រែ និងក្របីមួយក្បាល ។ ដើម្បីសងបំណុលគេវិញ ខៀវ បានត្រៀមខ្លួនចូលទៅធ្វើការទៅរោងចក្រនៅក្នុងទីក្រុងភ្នំពេញដើម្បីប្រឡូកជាមួយអ្នកជិតខាងរបស់គាត់ផ្សេងទៀតដែលបានធ្វើចំណាកស្រុករួចទៅហើយ ។ ប៉ុន្តែ នៅក្នុងទីក្រុងដ៏មមាញឹកនេះ ខៀវ ស្មុងយល់ឃើញថា ជីវិតរបស់គាត់និងជីវិតរបស់ក្មេងស្រីឯទៀតដែលកំពុងធ្វើការនៅរោងចក្រត្រូវបែងចែកជាពីរ គឺកាតព្វកិច្ចផ្ញើលុយទៅផ្ទះ និងខិតខំសន្សំលុយដើម្បីជួយគ្រួសារនៅផ្ទះឯជនបទ ។ នៅពេលដែល ខៀវ កំពុងរង់ចាំស្រឡាងដើម្បីជិះឆ្លងទៅផ្ទះ គាត់បានបង្ហាញពីវិធីដែលគាត់ និងគ្រួសារអាចរស់រានមានជីវិតបានឆ្ងាយពីទីក្រុង ។









ពិធីសម្ពោធការបញ្ចាំងខ្សែភាពយន្តឯកសារ “ក្បន់ទឹកទន្លេ” នៅសាលមហោស្រពចេនឡា រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១២

រឿង "ក្បង់ទឹកទន្លេ" បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមកដែលផ្តើមចេញពីតំបន់ជនបទចុង កាត់មាត់ញក ព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹកដ៏ស្រស់ត្រកាលទៅកាន់ទីក្រុងភ្នំពេញ ដែលពោរពេញទៅដោយសំណង់អគារ រោងចក្រកាត់ដេរ ។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
លេខ : ១៨៨ វ.វ

ទិដ្ឋាការ

បញ្ចាំង វីដេអូ

រឿង : ក្បង់ទឹកទន្លេ
សន្ទនាភាសា : ខ្មែរ , ប្រព័ន្ធ : DIGITAL , បណ្តាញ : PAL
ប្រភេទ : សម័យ ( ឯកសារ ) , ប្រទេសផលិត : កម្ពុជា
រយៈពេល : ១ម៉ោង២២ នាទី ២៣វិនាទី
ផលិតកម្ម : មជ្ឈមណ្ឌលឯកសារកម្ពុជា
ឆ្លងគណៈកម្មការពិនិត្យ : ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២
កំណត់សម្គាល់ : - គ្មានរូបភាពឃោរឃៅ និង អាសអាភាស
បញ្ជាក់ : ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ មិនទទួលខុសត្រូវចំពោះករណីដែល ម្ចាស់ស្នើសុំ រំលោភសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល ។
គណៈកម្មការពិនិត្យ រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១២
ប្រធាន,
ស៊ិន_ចន្ទសាយ៉ា
គង់_កន្ថារ៉ា

រឿងនេះក៏ឆ្លុះបញ្ចាំងបន្ថែមទៀតនូវរឿងរ៉ាវរបស់ប្រទេសមួយដែលកំពុងតែប្រឈមមុខនឹងភាពប្រទាញប្រទង់គ្នារវាងតំបន់ជនបទនាពេលបច្ចុប្បន្ន និងការគំរាមកំហែងនៃឧស្សាហកម្មនាពេលអនាគត ។ ខ្សែភាពយន្តថតដោយ ម៉ម កល្យាណី ផលិតដោយ ឆាំង យុ និងជំនួយការផលិតដោយ ឡេង រតនៈ ។

"ក្បង់ទឹកទន្លេ" គឺជាខ្សែភាពយន្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានទិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ លេខ១៨៨ វ.វ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១២ ។ ខ្សែភាពយន្តនេះមានចាក់បញ្ចាំងជូនរៀងរាល់ថ្ងៃសុក្រ ពេលវេលាគឺធ្វើតាមសំណើរបស់សាធារណជន ។ ព័ត៌មានបន្ថែមសូមទាក់ទងមក សា ហ្វាទីលី តាមរយៈទូរស័ព្ទ ០២៣ ២១១ ៨៧៥ ឬ ០១២ ៥១១ ៩១៤ ។

មជ្ឈមណ្ឌលឯកសារកម្ពុជា មានអាស័យដ្ឋាន ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ (ខាងកើតវិមានឯករាជ្យចម្ងាយ៥០ម៉ែត្រ) ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**


ទស្សនិកជនចូលរួមទស្សនាការបញ្ចាំងខ្សែយន្តឯកសារ "ក្បង់ទឹកទន្លេ" នៅសាលមហោស្រពចេនឡា រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១២

# ការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរនៅ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## សេចក្តីផ្តើម


អៀង សារី ក្នុងបន្ទប់សវនាការ ។ រូបថត៖ អ.វ.ត.ក

សិទ្ធិនៅស្ងៀមមិនឆ្លើយតប (Right to Remain Silent) គឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិជាមូលដ្ឋានសំខាន់ៗ ផ្សេងទៀតរបស់ជនជាប់ចោទដែលត្រូវបានធានាដើម្បីទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវនិងយុត្តិធម៌ ។ សិទ្ធិនេះត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយនៅក្នុងមជ្ឈដ្ឋានច្បាប់ជាតិ និងអន្តរជាតិ ដូចជា កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ហើយត្រូវបានអនុវត្តនៅតុលាការអន្តរជាតិមួយចំនួនដូចជា (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន) ។

ដូច្នេះវាជាកត្តាសំខាន់ និងចាំបាច់ដែលជនជាប់ចោទត្រូវយល់ដឹងអំពីការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរនៅពេលដំណើរការជំនុំជម្រះក្តីក្នុងរឿងព្រហ្មទណ្ឌមកលើខ្លួន ។ នៅពេលជនសង្ស័យ ឬជនជាប់ចោទសម្រេចជ្រើសរើសយកសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះខ្លួននឹងមិនអាចត្រូវបានបង្ខំឲ្យឆ្លើយតបសំណួររបស់ភាគីណាមួយឡើយ ។ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបញ្ជាក់ថា ជនជាប់ចោទមិនអាចត្រូវបានបង្ខំឲ្យឆ្លើយប្រឆាំងនឹងខ្លួនឯង ឬបង្ខំឲ្យឆ្លើយសារភាពថាមានកំហុសឡើយ ។ បញ្ញត្តិនេះត្រូវបានអង្គជំនុំជម្រះសាលាដំបូងបកស្រាយថា ជនជាប់ចោទមិនអាចត្រូវបានបង្ខំឲ្យឆ្លើយសំណួរដែលត្រូវបានសួរមកលើខ្លួនឡើយ ។ ដូច្នេះជនជាប់ចោទមានសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតបសំណួររបស់ភាគី ។ លើសពីនេះទៀត វិធានផ្ទៃក្នុងរបស់តុលាការបានតម្រូវថា ជនសង្ស័យ និងជនជាប់ចោទត្រូវទទួលបាននូវការជូនដំណឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការនៅស្ងៀមមិនឆ្លើយតបនៅគ្រប់កិច្ចដំណើរការនីតិវិធីទាំងអស់ក្នុងរឿងព្រហ្មទណ្ឌ ។

អត្ថបទនេះនឹងបង្ហាញអំពីជំហររបស់ជនជាប់ចោទនីមួយៗ ក្នុងការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ បន្ទាប់មកនឹងបង្ហាញអំពីមូលដ្ឋានច្បាប់ និងទម្រង់ឬវិសាលភាពនៃការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបហើយចុងក្រោយនឹងលើកឡើងអំពីគុណសម្បត្តិនិងគុណវិបត្តិសម្រាប់ជនជាប់ចោទដែលអនុវត្តសិទ្ធិនេះ ។

### ១) ជំហររបស់ជនជាប់ចោទក្នុងការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតប

ទោះបីជនជាប់ចោទ អៀង សារី, ខៀវ សំផន និង នួន ជា ស្ថិតនៅក្នុងសំណុំរឿង០០២តែមួយ ប៉ុន្តែជំហរក្នុងការប្រើប្រាស់សិទ្ធិនៅស្ងៀមរបស់ជនជាប់ចោទនីមួយៗគឺមានលក្ខណៈខុសៗគ្នា ។ ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបអំពីជំហររបស់ជនជាប់ចោទទាំងបីរូបដែលកំពុងប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ។

### ១.១) ជំហររបស់ជនជាប់ចោទ អៀង សារី

នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១ (បន្ទាប់ពីតំណាងសហ

ព្រះរាជអាជ្ញាស្នើសុំឲ្យមានការបញ្ជាក់អំពីចេតនារបស់ជនជាប់ចោទទាំងបីរូបពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្ម) ជនជាប់ចោទ អៀង សារី បានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអង្គជំនុំជម្រះសាលាដំបូងថា ខ្លួននឹងមិនផ្តល់សក្ខីកម្មឡើយ ពោលគឺរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយសំណួរទាំងអស់របស់ភាគីឬអង្គជំនុំជម្រះដែលមានបំណងសួរក្នុងអំឡុងពេលសវនាការទាំងមូល ។ បន្ថែមលើនេះ អៀង សារី បានផ្ញើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ម្តងទៀតក្នុងអំឡុងពេលសវនាការថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ដោយបានបញ្ជាក់ថា «...ខ្ញុំបាទសូមប្រើប្រាស់សិទ្ធិរបស់ខ្ញុំក្នុងរដ្ឋធម្មនុញ្ញដោយរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយនឹងសំណួរទាំងឡាយនាពេលនេះ ។ សិទ្ធិនេះមានចែងក្នុងមាត្រា៣១ និង៣៨នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ។ ខ្ញុំបាទមានបំណងប្រើប្រាស់សិទ្ធិនេះនៅក្នុងការជំនុំជម្រះទាំងមូល ហើយមិនមានបំណងឆ្លើយតបនឹងសំណួរណាមួយឡើយ» ។

### ១.២) ជំហររបស់ជនជាប់ចោទ ខៀវ សំផន

ចំពោះជនជាប់ចោទ ខៀវ សំផន បន្ទាប់ពីប្រធានអង្គជំនុំជម្រះបង្គាប់ឲ្យបង្ហាញជំហររបស់ខ្លួនឲ្យបានច្បាស់ពាក់ព័ន្ធនឹងការប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតប ខៀវ សំផន បានលើកឡើងថាខ្លួនមិនមានបំណងឆ្លើយតបនឹងសំណួរណាមួយឡើយពាក់ព័ន្ធនឹងអង្គហេតុស្តីពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ដរាបណា សហព្រះរាជអាជ្ញាមិនទាន់បង្ហាញភស្តុតាងពាក់ព័ន្ធនឹងអង្គហេតុនេះ ។ នៅសវនាការថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ ជនជាប់ចោទ ខៀវ សំផន (បញ្ជាក់បន្ថែមតាមរយៈមេធាវីរបស់ខ្លួន) ថា ខ្លួននឹងមិនឆ្លើយសំណួរទាំងអស់ដែលទាក់ទងនឹងអង្គហេតុស្តីពី «ប្រវត្តិសាវតាររបស់ជនជាប់ចោទ» ផងដែរ ។ ជនជាប់ចោទ ខៀវ សំផន មិនបានបង្ហាញជំហររក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរនៅគ្រប់កិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីទាំងមូលដូចជនជាប់ចោទ អៀង សារី ឡើយ ។ ពោលគឺគ្រាន់តែបញ្ជាក់ថា ខ្លួនមិនឆ្លើយតបចំពោះសំណួរពាក់ព័ន្ធអង្គហេតុស្តីពី «ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា» និង «ប្រវត្តិសាវតាររបស់ជនជាប់ចោទម្នាក់ៗ» ដែលត្រូវយកមកដេញដោលនៅក្នុងសវនាការដំណាក់កាលទីមួយតែប៉ុណ្ណោះ ។

### ១.៣) ជំហររបស់ជនជាប់ចោទ នួន ជា

សម្រាប់ជនជាប់ចោទ នួន ជា វិញ នៅអំឡុងពេលកិច្ចដំណើរការសវនាការដំណាក់កាលទីមួយខ្លួនមិនបានរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរឡើយពោលគឺ នួន ជា បានឆ្លើយតបគ្រប់ភាគីទាំងអស់ដែលបានចោទសួរមកលើខ្លួន ។ ប៉ុន្តែមកដល់ពេលនេះ ជនជាប់ចោទ នួន ជា បានរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ បន្ទាប់ពីអង្គជំនុំជម្រះប្រកាសបញ្ចប់សវនាការដំណាក់កាលទី១ ហើយបន្តដេញដោលលើអង្គហេតុដែលត្រូវជំនុំជម្រះនៅក្នុងដំណាក់កាលទី២ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលប្រព័ន្ធទំនាក់ទំនងការងារនិងតួនាទីជនជាប់ចោទម្នាក់ៗនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជនជាប់ចោទ នួន ជា បញ្ជាក់ជូនអង្គជំនុំជម្រះថា ប្រសិនបើអង្គជំនុំជម្រះមិនធ្វើការពិភាក្សាបន្ថែមលើអង្គហេតុពាក់ព័ន្ធនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជានិងមិនដោះស្រាយនូវសំណើមួយចំនួនដែលខ្លួនបានស្នើសុំនោះ ខ្លួននឹងរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបរាល់សំណួរទាំងអស់ដែលនឹងត្រូវចោទសួរមកលើខ្លួននៅក្នុងកិច្ចដំណើរការសវនាការដំណាក់កាលទីពីរនេះ ។

រហូតមកដល់ពេលនេះ សំណុំរឿង០០២ដែលកំពុងដំណើរការនៅអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺមិនមានជនជាប់ចោទណាម្នាក់ឆ្លើយតបនឹងសំណួរដែលភាគីមានបំណងចោទសួរឡើយ ពោលគឺជនជាប់ចោទទាំងអស់បានប្រើប្រាស់សិទ្ធិនៅស្ងៀម មិនឆ្លើយតបសំណួរ ។

## ២) មូលដ្ឋានច្បាប់និងការបកស្រាយពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប

### ២.១) មូលដ្ឋានច្បាប់ដែលត្រូវយកមកអនុវត្ត

មូលដ្ឋានច្បាប់ក្នុងការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបត្រូវបានលើកឡើងនៅពេលដែលជនជាប់ចោទ អៀង សារី ជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូងថា ខ្លួននឹងមិនផ្តល់សក្ខីកម្មឬឆ្លើយតបសំណួរណាមួយដែលត្រូវបានចោទសួរដោយភាគីក្នុងអំឡុងពេលកិច្ចដំណើរការសវនាការឡើយ ។ ក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី បានលើកយកបទបញ្ញត្តិមួយចំនួនដែលអនុញ្ញាតឲ្យជនជាប់ចោទអាចប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ បទបញ្ញត្តិទាំងនោះរួមមាន៖

ទី១) រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ៣១ ។ មាត្រានេះចែងថា “ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ” ។

ទី២) កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រង់មាត្រា១២(២) និងមាត្រា៣៣ថ្មីនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មាត្រាទាំងពីរនេះបានចែងស្រដៀងគ្នាដោយតម្រូវឲ្យអង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនឲ្យស្របតាមបទដ្ឋានអន្តរជាតិដូចដែលមានចែងក្នុងមាត្រា១៤ និង១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដើម្បីធានាឲ្យបានការកាត់ក្តីប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌ ។

ទី៣) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ត្រង់មាត្រា១៤(៣)(ឆ) និង មាត្រា៣៥(ឆ) ថ្មីនៃច្បាប់បង្កើតអង្គជំនុំជម្រះ ដែលមាត្រាទាំងពីរនេះចែងដូចគ្នាថា ជនជាប់ចោទមានសិទ្ធិ “មិនត្រូវបានគេបង្ខំឲ្យឆ្លើយប្រឆាំងនឹងខ្លួនឯង ឬបង្ខំឲ្យឆ្លើយសារភាពថាមានកំហុស” ។

ទី៤) វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រង់វិធាន២១(១)(ឃ) ។ វិធាននេះចែងថា “ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និងមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធីត្រូវបានផ្តល់ព័ត៌មានអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប” ។

យោងតាមមូលដ្ឋានច្បាប់ដូចបានរៀបរាប់នេះ ជនជាប់ចោទ អៀង សារី អះអាងថាខ្លួនមានសិទ្ធិពេញលេញក្នុងការមិនផ្តល់សក្ខីកម្ម ឬរក្សាភាពស្ងៀមស្ងាត់មិនឆ្លើយតបនឹងសំណួរនៅគ្រប់កិច្ចដំណើរការនីតិវិធីរបស់តុលាការ ។

គួរបញ្ជាក់ថា មូលដ្ឋានច្បាប់ដែលបានលើកឡើងដោយមេធាវីការពារក្តីជនជាប់ចោទ អៀង សារី ពាក់ព័ន្ធនឹងការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបគឺមិនត្រូវបានជំទាស់ដោយភាគីណាមួយឡើយ ពោលគឺសិទ្ធិនេះត្រូវបានទទួលស្គាល់យ៉ាងពេញលេញពីសំណាក់សហព្រះរាជអាជ្ញាជាតិ អន្តរជាតិ និងអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សហព្រះរាជអាជ្ញាបានបង្ហាញជំហរយ៉ាងច្បាស់ថា ជនជាប់ចោទមានសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរដោយអនុលោមតាមវិធាន២១(១)(ឃ) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ច្បាស់ជាងនេះទៅទៀត សហព្រះរាជអាជ្ញាបញ្ជាក់ថា ខ្លួននឹងមិនជំទាស់ចំពោះការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរឡើយ ។

ដូចគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានជំទាស់ ឬបដិសេធអំពីមូលដ្ឋានច្បាប់ដែលទាក់ទងនឹងសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទដែលត្រូវបានលើកឡើងដោយមេធាវីការពារក្តីឡើយ ។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ជនជាប់ចោទមានសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរដោយយោងទៅមាត្រា៣៥(ឆ) ថ្មីនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

## ២.២) ទម្រង់និងអានុភាពនៃការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ

បន្ថែមលើការយល់ដឹងអំពីមូលដ្ឋានច្បាប់ផ្សេងៗ ដែលត្រូវយកមកអនុវត្ត ការដឹងអំពីទម្រង់និងអានុភាពនៃការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរក៏ជាកត្តាសំខាន់ដើម្បីធានាថាសិទ្ធិនេះត្រូវបានអនុវត្តពេញលេញ ។

### ក) ទម្រង់នៃការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ

ការបកស្រាយអំពីទម្រង់ ឬវិសាលភាពនៃការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺកើតឡើងបន្ទាប់ពីលោកចៅក្រម ហ្សង់ម៉ាកឡាវើញ ដាក់ឯកសារភស្តុតាងនៅចំពោះមុខភាគី ហើយលោកបានព្យាយាមសួរជនជាប់ចោទ ខៀវ សំផន ដើម្បីឲ្យបញ្ជាក់អំពី

ភាពត្រឹមត្រូវនៃឯកសារទាំងនោះ ។ ក្នុងការដាក់ឯកសារទាំងនោះ លោកចៅក្រមបានអានខ្លឹមសារខ្លីៗ ហើយស្នើឲ្យជនជាប់ចោទ ខៀវ សំផន ធ្វើអត្ថាធិប្បាយ ធ្វើការកត់សម្គាល់ផ្លាស់ប្តូរយោបល់ បញ្ចេញប្រតិកម្មធ្វើការបញ្ជាក់ ឬពន្យល់បន្ថែម...ទៅលើខ្លឹមសារដែលលោកបានអាន ។ ប្រភេទនៃសំណើទាំងនេះត្រូវបានគង់ សំអុន មេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន ធ្វើការជំទាស់យ៉ាងខ្លាំងដោយលើកឡើងថា កូនក្តីរបស់ខ្លួនកំពុងប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរ ។ ការព្យាយាមចោទសំណួរម្តងហើយម្តងទៀតឬស្នើឲ្យផ្តល់យោបល់ឬធ្វើអត្ថាធិប្បាយទៅលើភ័ស្តុតាង ឬបញ្ហាណាមួយគឺធ្វើឲ្យប៉ះពាល់ដល់ជនជាប់ចោទក្នុងការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតប ។ លោកមេធាវីបានបន្ថែមថា «ការស្នើឲ្យ ខៀវ សំផន ផ្តល់យោបល់ ឬក៏ធ្វើអត្ថាធិប្បាយនេះគឺគ្រាន់តែជាការផ្លាស់ប្តូររបៀបសួរប៉ុណ្ណោះ ការតាំងសំណួរហ្នឹងធ្វើគ្រាន់តែមិនឲ្យចេញជាសំណួរគឺឲ្យទៅជាប្រយោគធម្មតាដើម្បីឲ្យ ខៀវ សំផន ឆ្លើយតប ។ អ៊ីចឹងបានន័យថា សិទ្ធិក្នុងការមិនឆ្លើយហ្នឹងមិនត្រូវបានអនុវត្តទេ នៅពេលនេះគឺដូចក្នាដដែល ។ បានន័យថា ខៀវ សំផន ត្រូវតែឆ្លើយតប ។ អ៊ីចឹងការធ្វើដដែលៗបែបនេះវាបង្ហាញថា យើងកំពុងតែបង្ខំ ខៀវ សំផន ឆ្លើយតប» ។

ពាក់ព័ន្ធបញ្ហានេះដែរ ក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី បានលើកឡើងថា «សំណើឲ្យធ្វើការបញ្ជាក់ផ្តល់យោបល់ ឬឆ្លើយតបទៅនឹងសំណួរ ឬឯកសារនានាគឺជាសំណើសុំឲ្យនិយាយ ពីព្រោះជនជាប់ចោទមិនអាចបញ្ជាក់ ផ្តល់យោបល់ ឬឆ្លើយតបដោយមិននិយាយបានឡើយ ។ នៅពេលណាជនជាប់ចោទបានបញ្ជាក់យ៉ាងច្បាស់លាស់ក្នុងការប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះ សំណើសុំឲ្យធ្វើការបញ្ជាក់ផ្តល់យោបល់ ឬឆ្លើយតបទៅនឹងសំណួរឬឯកសារ គឺជាការបំពានដល់សិទ្ធិជាសារវន្តរបស់ជនជាប់ចោទដែលជាសិទ្ធិទទួលបានការការពារពីរដ្ឋធម្មនុញ្ញក្នុងការនៅស្ងៀមមិនឆ្លើយតប និងសិទ្ធិមិនដាក់ពិរុទ្ធភាពមកលើខ្លួនឯង» ។

គួរបញ្ជាក់ថា ការបកស្រាយអំពីទម្រង់ ឬវិសាលភាពនៃការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរដោយក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន និង អៀង សារី គឺមិនត្រូវបាន



អៀង សារី និងក្រុមការពារក្តីរបស់ខ្លួនក្នុងបន្ទប់សវនាការ ។ រូបភាព មេធាវី ម៉ៃឃើល ការណាវ៉ាស ។ រូបថត ៖ (អ.វ.ត.ក)

អង្គជំនុំជម្រះសាលាដំបូង ឬសហព្រះរាជអាជ្ញាធ្វើការជំទាស់ ឬបដិសេធឡើយ ។ ពោលគឺអង្គជំនុំជម្រះបានបង្ហាញជំហរយល់ស្របតាមការបកស្រាយរបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ ។ ជាក់ស្តែង អង្គជំនុំជម្រះបានសម្រេចទទួលយកសំណើរបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន ដោយសុំឲ្យចៅក្រមហ្វង់ម៉ាក ឡាវីញ បញ្ឈប់ការសួរដេញដោលជនជាប់ចោទតាមរយៈការប្រើវិធីសាស្ត្រដូចបានរៀបរាប់ខាងលើនេះ ។

## ១) អានុភាពនៃការប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតប

សំណួរសួរថា នៅពេលជនជាប់ចោទប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ តើអង្គជំនុំជម្រះទាញសេចក្តីសន្និដ្ឋានជាអវិជ្ជមានចំពោះជនជាប់ចោទដែរឬទេ?

### ១.១) អំណះអំណាងរបស់ក្រុមមេធាវីការពារក្តី

ក្រុមមេធាវីការពារក្តី អៀង សារី អះអាងថា «នៅពេលជនជាប់ចោទប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតប នោះគេមិនអាចទាញសេចក្តីសន្និដ្ឋានដោយអវិជ្ជមានពីការនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទឡើយ ។ សិទ្ធិរបស់ជនជាប់ចោទក្នុងការនៅស្ងៀមមិនឆ្លើយតបមិនអាចមានន័យពេញលេញឡើយនៅពេលការប្រើសិទ្ធិនេះនាំឲ្យមានការស្តីបន្ទោស ។ ការទាញសេចក្តីសន្និដ្ឋានជាអវិជ្ជមាននៅពេលជនជាប់ចោទប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបគឺជាការបំពានដល់សច្ចធារណ៍នៃនិរទោសភាពគ្មានទោស និងផ្ទេរបន្ទុកស្វែងរកភស្តុតាងពីការិយាល័យសហព្រះរាជអាជ្ញាទៅជាបន្ទុករបស់មេធាវីការពារក្តី» ។ ក្រុមមេធាវីការពារក្តីបន្ថែមទៀតថា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាវិធានផ្ទៃក្នុងកិច្ចព្រមព្រៀងនិងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានចែងពីលទ្ធភាពដែលអាចទាញសេចក្តីសន្និដ្ឋានជាអវិជ្ជមានចំពោះជនជាប់ចោទដែលប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយសំណួរឡើយ ។ ផ្ទុយមកវិញបញ្ហានេះបានកំណត់នៅក្នុងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលបានកំណត់ថា ជនជាប់ចោទមានសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរហើយការនៅស្ងៀមស្ងាត់នេះមិនត្រូវយកមកពិចារណាក្នុងការកំណត់ថា ជនជាប់ចោទនោះមានពិរុទ្ធភាពឬគ្មានពិរុទ្ធភាពឡើយ ។ មានការសម្រេចស្រដៀងគ្នារបស់តុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីក្នុងរឿងក្តី Celebici និង Delalic ដោយបានសម្រេចថា «...លក្ខន្តិកៈនិងវិធានមានចែងពីការហាមឃាត់ដាច់ខាតប្រឆាំងនឹងការចាត់ទុកការនៅស្ងៀមមិនឆ្លើយតប ជាកត្តាមួយក្នុងការកំណត់ពី ពិរុទ្ធភាពឬភាពគ្មានទោស» ។

គួររំឭកថា សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ ហើយដែលមិនអាចយកមកវិនិច្ឆ័យពីភាពមានឬគ្មានពិរុទ្ធភាពរបស់ជនជាប់ចោទគឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិទាំង៩ដែលជនជាប់ចោទត្រូវតែមានសិទ្ធិដែលត្រូវបានធានាក្នុងកម្រិតអប្បបរមា ដើម្បីទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

### ១.២) សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

ផ្ទុយពីការលើកឡើងរបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី អង្គជំនុំជម្រះសាលាដំបូងអះអាងថា តាមយុត្តិសាស្ត្រអន្តរជាតិដែលពាក់ព័ន្ធបង្ហាញថា ការដែលជនជាប់ចោទសម្រេចជ្រើសរើសដោយខ្លួនឯងក្នុងការនៅស្ងៀមមិនឆ្លើយតបសំណួរនោះអាចត្រូវបានប្រើក្នុងការទាញចេញជាសេចក្តីសន្និដ្ឋានផ្ទុយ ។ គួរបញ្ជាក់ថា ការអះអាងនៅក្នុងសេចក្តីសម្រេចដោយផ្ទាល់មាត់នេះ អង្គជំនុំជម្រះមិនបានលើកយករឿងក្តីជាក់លាក់ឬយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិណាមួយមកបង្ហាញឡើយ ។

ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះបញ្ជាក់ថា ក្នុងការវិនិច្ឆ័យអំពីកំហុសរបស់ជនជាប់ចោទខ្លួននឹងមិនផ្អែកទាំងស្រុងលើការទាញសេចក្តីសន្និដ្ឋានផ្ទុយចេញពីការរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរឡើយ ។ ពោលគឺអង្គជំនុំជម្រះនឹងពិចារណាលើភស្តុតាងទាំងអស់ដែលបានដាក់ចំពោះមុខខ្លួន រួមទាំងសក្ខីកម្មនិងរបៀបដែលជនជាប់ចោទផ្តល់សក្ខីកម្ម ។ តាមអត្ថន័យនៃសេចក្តីសម្រេចនេះបញ្ជាក់ឲ្យឃើញថា នៅពេលដែលជនសង្ស័យឬជនជាប់ចោទរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរនោះអង្គជំនុំជម្រះនៅតែអាចមានលទ្ធភាពទាញសេចក្តីសន្និដ្ឋានជាអវិជ្ជមានក្នុងកម្រិតណាមួយ ដើម្បីវិនិច្ឆ័យអំពីកំហុសរបស់ជនសង្ស័យឬជនជាប់ចោទបាន ។ ជាក់ស្តែង អង្គជំនុំជម្រះបញ្ជាក់ថា «...នៅ

ពេលដែលជនជាប់ចោទសម្រេចជ្រើសរើសដោយខ្លួនឯងនូវសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងការផ្តល់សក្ខីកម្ម នោះអង្គជំនុំជម្រះអាចនឹងកត់សម្គាល់អំពីបញ្ហានេះនៅពេលវាយតម្លៃអំពីភាពគួរឲ្យជឿជាក់បានរបស់គាត់» ។

### ៣) គុណសម្បត្តិ និងគុណវិបត្តិនៃការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប

មានសំណួរជាច្រើនត្រូវបានចោទសួរឡើងជុំវិញការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួររបស់ជនជាប់ចោទក្នុងសំណុំរឿង០០២ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សំណួរមួយចំនួនក្នុងចំណោមសំណួរទាំងនោះរួមមានៈ តើមានផលប្រយោជន៍និងផលវិបាកអ្វីខ្លះនៅពេលជនសង្ស័យ ឬជនជាប់ចោទសម្រេចប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ? តើកិច្ចដំណើរការនីតិវិធីរបស់តុលាការនឹងប្រព្រឹត្តទៅដោយរបៀបណា? តើជនជាប់ចោទអាចការពារខ្លួនដោយរបៀបណា?

បញ្ហាទាំងនេះត្រូវបានស្រាយបំភ្លឺតាមរយៈការអនុវត្តជាក់ស្តែងនៅក្នុងកិច្ចដំណើរការជំនុំជម្រះក្តីលើសំណុំរឿង០០២នេះ ។ មានផលប្រយោជន៍ជាច្រើនសម្រាប់ជនជាប់ចោទដែលកើតចេញពីការសម្រេចចិត្តប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ ។ ទី១) រហូតមកដល់ពេលនេះ គ្មានជនជាប់ចោទណាម្នាក់ត្រូវបានភាគីឬអង្គជំនុំជម្រះបង្ខំឲ្យសារភាពកំហុសឬឆ្លើយតបសំណួរណាមួយដែលដាក់បន្ទុកលើខ្លួនឯងឡើយ ។ គួរបញ្ជាក់ថាជាច្រើនលើកច្រើនសារ ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើឲ្យជនជាប់ចោទផ្តល់សក្ខីកម្មអំពីអង្គហេតុដែលបានកើតនៅក្នុងរបបខ្មែរក្រហម ដើម្បីឲ្យប្រជាជនកម្ពុជានិងសាធារណៈយល់ដឹងអំពីមូលហេតុនៃអំពើឧក្រិដ្ឋកម្មដែលបានកើតនៅក្នុងរបបនេះ ។ ប៉ុន្តែសំណើទាំងនេះមិនត្រូវបានពិចារណាឡើយ បន្ទាប់ពីមេធាវីការពារក្តីជនជាប់ចោទបង្ហាញជំហរថា កូនក្តីរបស់ខ្លួនកំពុងប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ ។ ទី២) ពង្រឹងនូវតួនាទីរបស់សហព្រះរាជអាជ្ញាក្នុងការអនុវត្តកាតព្វកិច្ចបង្ហាញភស្តុតាងដើម្បីបញ្ជាក់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។ ទី៣) ពង្រឹងតួនាទីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលមានភារកិច្ចចាត់វិធានការស៊ើបសួរ ដើម្បីឈានទៅរកការបង្ហាញការពិតនៃរឿងក្តី ។ ទី៤) ជនជាប់ចោទនៅតែអាចស្នើសុំធ្វើអត្ថាធិប្បាយទៅលើឯកសារភស្តុតាងណាមួយដែលត្រូវបានដាក់ចំពោះមុខខ្លួន ។ ជាក់ស្តែងអង្គជំនុំជម្រះសាលាដំបូងនៅតែទុកលទ្ធភាពឲ្យជនជាប់ចោទធ្វើអត្ថាធិប្បាយលើភស្តុតាងណាមួយ ដែលយល់ថាមានប្រយោជន៍សម្រាប់ខ្លួនទោះបីខ្លួនកំពុងតែប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបក៏ដោយ ។ គួរបញ្ជាក់បន្ថែមថា ទោះបីជនជាប់ចោទរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ ប៉ុន្តែជនជាប់ចោទនៅតែមានសិទ្ធិណែនាំមេធាវីរបស់ខ្លួននៅគ្រប់កិច្ចដំណើរការនីតិវិធីទាំងអស់ ។ មានន័យថា ក្នុងករណីមានភស្តុតាងណាមួយឬសក្ខីកម្មរបស់សាក្សីណាម្នាក់ដាក់បន្ទុកមកលើខ្លួននោះជនជាប់ចោទមានសិទ្ធិណែនាំមេធាវីរបស់ខ្លួនដើម្បីធ្វើការជំទាស់ឬបដិសេធចោល ។ ជាក់ស្តែង គឺការអនុវត្តរបស់ជនជាប់ចោទ អៀង សារី ។ ទោះបីជនជាប់ចោទរូបនេះរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរទាំងអស់ ប៉ុន្តែក្នុងកិច្ចដំណើរការសវនាការជនជាប់ចោទនៅតែធ្វើការណែនាំមេធាវីរបស់ខ្លួនជាប្រចាំដើម្បីតទល់ទៅនឹងសាក្សីណាដែលនឹងផ្តល់សក្ខីកម្មដាក់ទាក់ទងនឹងក្រសួងការបរទេសដែលអាចដាក់បន្ទុកមកលើខ្លួន ។

ប៉ុន្តែទន្ទឹមគ្នានេះដែរ ក៏អាចមានផលអវិជ្ជមានមួយចំនួនសម្រាប់ជនសង្ស័យឬជនជាប់ចោទដែលប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរនេះ ។ ពោលគឺពាក់ព័ន្ធនឹងតម្លៃឬទម្ងន់នៃភស្តុតាងដែលជនសង្ស័យឬជនជាប់ចោទនោះបានផ្តល់ ។ ត្រង់ចំណុចនេះ សហព្រះរាជអាជ្ញាធ្លាប់បានដាក់សំណើសុំទៅអង្គជំនុំជម្រះសាលាដំបូងឲ្យជូនដំណឹងទៅជនជាប់ចោទ ខៀវ សំផន ថាក្នុងករណីជនជាប់ចោទប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ នោះចម្លើយទាំងឡាយណាដែលជនជាប់ចោទរូបនេះបានផ្តល់នៅចំពោះមុខអង្គជំនុំជម្រះនឹងមិនទំនងផ្តល់តម្លៃជាភស្តុតាងសំខាន់ៗឡើយ ។ ប៉ុន្តែរហូតមកដល់ពេលនេះ បញ្ហាតម្លៃ ឬទម្ងន់នៃភស្តុតាងដែលផ្តល់ដោយជនជាប់ចោទដែលប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបនៅមិនទាន់មានភាពច្បាស់លាស់នៅឡើយព្រោះអង្គជំនុំជម្រះមិនបានចេញសេចក្តីសម្រេចជាក់លាក់ណាមួយអំពីបញ្ហានេះឡើយ ។ ជាងនេះទៅទៀត វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏មិនបានចែងអំពីបញ្ហានេះដែរ ។ **ចាន់ ប្រាថ្នា**

# អ្វីទៅជាសំណុំរឿង០០២/០១?

នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចមួយដោយធ្វើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ឲ្យទៅជាផ្នែកតូចៗ ដែលអនុញ្ញាតឲ្យខ្លួនអាចជ្រើសរើសយកអង្គហេតុ ឬបទចោទប្រកាន់ត្រង់ផ្នែកណាមួយក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីយកមកបើកសវនាការ ។ ផ្នែកដំបូងដែលអង្គជំនុំជម្រះយកមកបើកសវនាការនោះត្រូវបានកំណត់ថាជាសំណុំរឿង០០២/០១ (អានថា សូន្យសូន្យពីរស្លាស់សូន្យមួយ) ។ ក្នុងសំណុំរឿង០០២/០១ នេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចលើកយកការចោទប្រកាន់លើអង្គហេតុមួយចំនួនដើម្បីបើកសវនាការ ។ ការចោទប្រកាន់លើអង្គហេតុទាំងនោះរួមមានៈ

ក) រចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

ខ) តួនាទីរបស់ជនជាប់ចោទម្នាក់ៗ នៅមុនពេលមានការបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ និងនៅពេលជនជាប់ចោទម្នាក់បានទទួលការចាត់តាំងនូវតួនាទីទាំងនោះ ។

គ) តួនាទីរបស់ជនជាប់ចោទម្នាក់ៗក្នុងជួររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ការទទួលខុសត្រូវរបស់ពួកគេតាមការចាត់តាំងក្របខណ្ឌនៃសិទ្ធិអំណាចរបស់ពួកគេ និងខ្សែបណ្តាញទាក់ទងនៅក្នុងរយៈកាលដែលពាក់ព័ន្ធ និងយុត្តាធិការតាមពេលវេលារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ឃ) គោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យស្តីពីបញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។

ង) ការចោទប្រកាន់លើអង្គហេតុ ដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន នៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ ។

ច) ការសម្លាប់អតីតទាហាន លន់ នល់ និងមន្ត្រីរដ្ឋការនៅទួលពោធិជ្រៃ ។

សូមបញ្ជាក់ថា ការចោទប្រកាន់លើអង្គហេតុទាក់ទងនឹងការសម្លាប់អតីតទាហាន លន់ នល់ និងមន្ត្រីរដ្ឋការនៅទួលពោធិជ្រៃ គឺទើបតែត្រូវបានអង្គជំនុំជម្រះសាលាដំបូងសម្រេចដាក់បញ្ចូលទៅក្នុងសំណុំរឿង០០២/០១ នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២ ថ្មីៗនេះ បន្ទាប់ពីមានសំណើពីសហព្រះរាជអាជ្ញាស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះលើសំណុំរឿង ០០២/០១ ។

នៅក្នុងសំណុំរឿង០០២/០១ អង្គជំនុំជម្រះសាលាដំបូងនឹងលើកយកបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ (លើកលែងដោយហេតុផលសាសនា) ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ មកធ្វើការវិនិច្ឆ័យ ។ រីឯបទចោទទាក់ទងនឹងបទប្រល័យពូជសាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ត្រូវបានទុកមួយអន្លើសម្រាប់ដំណាក់កាលបន្ទាប់នៃកិច្ចដំណើរការនីតិវិធី ។

នៅក្នុងសវនាការលើសំណុំរឿង០០២/០១ ចំនួនសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវកម្រិតត្រឹមតែបុគ្គលទាំងឡាយដែលអង្គជំនុំជម្រះយល់ឃើញថា មានជាប់ពាក់ព័ន្ធនឹងអង្គហេតុ នៅដំណាក់កាលដំបូងនេះតែប៉ុណ្ណោះ ។

សូមបញ្ជាក់ថា រហូតមកដល់ពេលនេះ អង្គជំនុំជម្រះបាននឹងកំពុងបើកសវនាការជំនុំជម្រះទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជននៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ និងការសម្លាប់អតីតទាហាន លន់ នល់ និងមន្ត្រីរដ្ឋការនៅទួលពោធិជ្រៃ ។ ចំពោះអង្គហេតុផ្សេងៗទៀត អង្គជំនុំជម្រះបញ្ចប់ការស្តាប់សក្ខីកម្មសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីរួចស្រេចហើយ

បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបើកសវនាការជំនុំជម្រះក្តីលើសំណុំរឿង០០២/០១រួចរាល់ អង្គជំនុំជម្រះនឹងចេញសាលក្រមសម្រេចលើការចោទប្រកាន់ដូចបានរៀបរាប់ខាងលើដោយផ្តន្ទាទោសសមស្របមួយ ប្រសិនបើអង្គជំនុំជម្រះរកឃើញថាជនជាប់ចោទពិតជាមានពិរុទ្ធភាពមែន ។ **លឹម ច័យផត្ក**

# ការចងក្រងឯកសារក្រោយពីអំពើឃោរឃៅកើតឡើង

## *សេចក្តីផ្តើម*

*កាលពីខែមីនា ឆ្នាំ២០១១កន្លងទៅ ក្រុមតវ៉ាប្រឆាំងរបស់ប្រទេសអេហ្ស៊ីបបានលុកលុយចូលអតីតមន្ទីរប៉ូលីសសម្ងាត់នៅរដ្ឋធានីគែរ នៃប្រទេសអេហ្ស៊ីប ដើម្បីរឹបអូស គ្រប់គ្រង និងរក្សាឯកសារអំពីការរំលោភបំពានក្រោមរបបលោកប្រធានាធិបតី ហូស នីមូបារ៉ាក់ ដែលក្រុមតវ៉ាទាំងនោះព្រួយបារម្ភថា ភ្នាក់ងារសន្តិសុខបំផ្លាញឯកសារទាំងនោះចោល ។ ប៉ុន្មានថ្ងៃបន្ទាប់មក ក្រុមអ្នកតវ៉ាចាប់ផ្តើមបង្ហោះឯកសារលើទំព័រ* Twitter *និង* Facebook *ដែលហៅថា ការធ្លាយឯកសារសន្តិសុខជាតិ ។ នាដើមខែមិថុនា អ្នកកាសែត និងអ្នកសង្កេតការណ៍មកពីអង្គការឃ្លាំមើលសិទ្ធិមនុស្សបានចូលការិយាល័យដែលគេបោះបង់ចោលរបស់ភ្នាក់ងារស៊ើបអង្កេតប្រទេសលីប៊ី ហើយក៏រកឃើញឯកសារសម្ងាត់ដែលលាក់ទុកមួយចំនួន ។ ឯកសារមួយចំនួនត្រូវបានផ្សព្វផ្សាយជាសាធារណៈភ្លាមៗ រួមមានឯកសារឆ្លើយឆ្លងរបស់ភ្នាក់ងារសម្ងាត់លីប៊ី និងសមភាគីអង់គ្លេសនិងអាមេរិករបស់ខ្លួនជុំវិញការប្រព្រឹត្តរបស់ជនសង្ស័យមួអាម៉ា ហ្កាដាហ្វី ។ ខណៈដែលដំណើរជ្រួលច្របល់របស់ចលនាបដិវត្តន៍រដូវផ្ការីកនៅតំបន់អារ៉ាប់កំពុងតែបន្តទៅមុខគំហើញថ្មីៗថែមទៀតទំនងជាអាចរកឃើញ ។ ឯកសារទាំងនោះមានអំណាចពេញលេញក្នុងការឆ្លុះបញ្ចាំងពីការងារនៃរបបដែលត្រូវបានផ្តួលរំលំ ទំនាក់ទំនងការបរទេស និងការរំលោភបំពានដែលរបបនេះបានធ្វើ ។ ទោះបីជាយ៉ាងនេះក៏ដោយ ដំណើរការចែកចាយឯកសារទាំងនោះដែលរួមចំណែកចំពោះការទទួលខុសត្រូវខាងផ្លូវច្បាប់និងការពិតជាប្រវត្តិសាស្រ្តនៅតែជារឿងស្រពេចស្រពិល ។ ការរំលោភបំពានទៅលើកិច្ចការប្រមូលឯកសារនៅក្នុងអំឡុងពេលនិងក្រោយពីសម័យអន្តរកាលបានចោទជាសំណួរដ៏ពិបាកខាងផ្លូវច្បាប់និងសុជីវធម៌ ។ តើនរណាគួរតែប្រមូលរៀបចំ និងចែកចាយឯកសារទាំងនោះ? នៅក្នុងពិភពមួយដែលធនធានមានការខ្វះខាត តើការធ្វើឲ្យមានតុល្យភាពរវាងការរៀបចំរក្សា និងការចែកចាយឯកសារគួរតែត្រូវធ្វើយ៉ាងដូចម្តេច? តើការប្រើប្រាស់ឯកសារនោះអាចបង្កជម្លោះតាមរបៀបណា?*

*ចម្លើយចំពោះសំណួរទាំងនោះផ្អែកលើបរិបទទាំងមូល ។ ច្បាប់បានផ្តល់នូវសេចក្តីណែនាំ ប៉ុន្តែសេចក្តីណែនាំនៅមានកម្រិតជាពិសេសអំឡុងពេលសម័យអន្តរកាលដ៏ស្រពេចស្រពិលបន្ទាប់ពីសង្រ្គាម និងការរំលោភបំពានដ៏ធ្ងន់ធ្ងរ ។ នយោបាយ និងការស្វែងរកផលប្រយោជន៍របស់បក្ខពួកតែងតែជាចំណុចរសើបដោយរួមចំណែកទៅនឹងអ្វីដែលអាចកើតឡើងជាក់ស្តែង និងចំពោះអ្វីដែលសង្គមព្យាយាមស្តារប្រទេសពីជម្លោះ ។ លោកឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបានសង្កត់ធ្ងន់ថា ក្រោយអំពើរំលោភបំពានទ្រង់ទ្រាយធំ "ការប្រមូលឯកសារគឺជាកិច្ចការនយោបាយ" ទោះបីជាការប្រមូលឯកសារមិនពាក់ព័ន្ធរឿងនយោបាយ វាក៏មានឥទ្ធិពលពីផ្នែកនយោបាយយ៉ាងខ្លាំងដែរ ។ ការប្រមូលឯកសារជាប្រវត្តិសាស្រ្តដែលផ្តោតលើការរំលោភសិទ្ធិមនុស្សមិនខុសអ្វីពីដំណើរការទាក់ទងខាងនយោបាយដែលផ្អែកលើកម្លាំង ព្រមទាំងភាពខ្លាំងនិងស្ថេរភាពរបស់របបគ្រប់គ្រងថ្មី ។ ទោះបីជាយ៉ាងនេះក៏ដោយ កិច្ចខំប្រឹងប្រែងនៃការប្រមូលឯកសារគួរតែផ្អែកលើគោលការណ៍មូលដ្ឋានជាក់លាក់ដែលផ្តល់នូវតម្រុយខាងសុជីវធម៌ដល់អ្នកជាប់ពាក់ព័ន្ធ និងមធ្យោបាយនៃការវាយតម្លៃកិច្ចខំប្រឹងប្រែងពីមជ្ឈដ្ឋានខាងក្រៅ ។ ឯកសារនេះនិយាយយោងតាំទ្រដល់យុទ្ធសាស្រ្តជាមូលដ្ឋានចំពោះការប្រមូលឯកសារក្នុងដំណើរស្វែងរកការពិតបន្ទាប់ពីការរំលោភបំពានដ៏ធ្ងន់ធ្ងរ ។ យុទ្ធសាស្រ្តជាមូលដ្ឋានគឺជាយុទ្ធសាស្រ្តមួយ ដែលគូសបញ្ជាក់ដោយគោលដំហរដ៏សំខាន់ក្នុងការបង្កើតមូលដ្ឋានរឹងមាំរបស់ឯកសារដែលគួរឲ្យជឿនិងមិនលម្អៀង ។ គោលការណ៍នេះមានឥទ្ធិពលយ៉ាងខ្លាំង ហើយជួនកាលប្រឆាំងទៅនឹងបទដ្ឋានផ្សេងៗ ។*

*ទីមួយ យុទ្ធសាស្រ្តជាមូលដ្ឋានចំពោះការប្រមូលឯកសារលើកឡើងថា ឯកសារគួរតែត្រូវប្រមូល និងរៀបចំដោយអ្នកមាន*

ឆន្ទៈខ្ពស់ និងសមត្ថភាពធ្វើការងារនោះដោយភាពជឿជាក់ និងប្រសិទ្ធភាព ។ ការប្រមូលឯកសារមិនមែនជាការប្រមូលឯកសារថ្នាក់ជាតិជានិច្ចកាលនោះទេ ជាពិសេសអំឡុងពេលសម័យអន្តរកាលដូច្នេះហើយ វាមានការចាំបាច់ដែលត្រូវថ្លឹងថ្លែងបញ្ហាស្តីពីអធិបតេយ្យភាព និងសមត្ថភាពស្ថាប័នក្នុងស្រុកដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកជំនាញនិងជំនួយបរទេស ។ ទីពីរ យុទ្ធសាស្រ្តជាមូលដ្ឋានទាមទារឲ្យមានការសង្កត់ធ្ងន់លើរបៀបប្រមូលឯកសារដែលមានលក្ខណៈមិនលម្អៀង និងហ្មត់ចត់ ។ ដំណើរការប្រមូលឯកសារនោះត្រូវការពេលវេលា និងធនធាន ហើយទំនងជាបង្កសតិអារម្មណ៍ដល់អ្នកដែលស្វែងយល់ពីព័ត៌មានជាក់លាក់ទាក់ទិននឹងការរំលោភសិទ្ធិមនុស្ស ។ ការវិវឌ្ឍខាងបច្ចេកវិទ្យាឌីជីថលបានជួយសម្រួលដល់ដំណើរការប្រមូលនិងរក្សាឯកសារ ។ ទីបី យុទ្ធសាស្រ្តជាមូលដ្ឋានមានសារសំខាន់ចំពោះការបង្ហាញ និងការពង្រឹងសុជីវធម៌ស្តីពីប្រភេទព័ត៌មានដែលអាចត្រូវបោះពុម្ពផ្សាយ ហើយព័ត៌មានទាំងនោះអាចត្រូវសួរដេញដោលដោយរបៀបណា ។ តម្លាភាព និងការផ្សព្វផ្សាយព័ត៌មានគឺជាគោលបំណងដ៏ចម្បងនៃការប្រមូលព័ត៌មាន ក៏ប៉ុន្តែគោលបំណងទាំងនោះមិនដាច់ចេញពីគ្នាទេ ។ នៅពេលដែលដំណើរការប្រមូលឯកសារបានផ្សព្វផ្សាយគំហើញរបស់ខ្លួន យុទ្ធសាស្រ្តជាមូលដ្ឋានទាមទារឲ្យមានការពន្យល់ដ៏លម្អិតពីការពិតដែលមិនលម្អៀងដែលជាធម្មតាមានន័យថា ការដាក់បញ្ចូលបទពិសោធន៍ និងទស្សនវិស័យរបស់អ្នកជាប់ពាក់ព័ន្ធ និងការទទួលយកនូវលទ្ធផលផ្សេងៗ ។

យុទ្ធសាស្រ្តនេះ នឹងមិនទាក់ទាញមនុស្សគ្រប់គ្នាទាំងអស់ទេ ។ ជាធម្មតា វាទាមទារឲ្យមានការអត់ធ្មត់ចំពោះការទទួលព័ត៌មានខ្លីៗពីសង្គមមួយដែលការរំលោភបំពានធ្ងន់ធ្ងរបានកើតឡើង ។ វាក៏អាស្រ័យផងដែរទៅលើឆន្ទៈរបស់ក្រុមសកម្មជន និងអ្នកតែងច្បាប់ដែលមើលឃើញប្រយោជន៍នៃប្រវត្តិសាស្រ្តដែលមិនលម្អៀងផ្សេងទៅវិញ ផលប្រយោជន៍បុគ្គល និងវិចារណញ្ញាណប្រហែលជាជះឥទ្ធិពលដល់រឿងនេះ ។ ឯកសារនេះបានលើកឡើងថា ការផ្តោតលើមូលដ្ឋានរឹងមាំគឺជារឿងដ៏សំខាន់ ហើយវាពង្រឹងជំនឿខាងឯកសារដែលប្រើជាភ័ស្តុតាងសម្រាប់តុលាការនិងការស្វែងរកការពិត ។ ក្រៅពីការទទួលខុសត្រូវជាផ្លូវការ យុទ្ធសាស្រ្តនេះបានផ្តល់នូវគោលគំនិតអប់រំនិងការចងចាំ ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះមានសារសំខាន់ហួសពីការទទួលខុសត្រូវរបស់ឧក្រិដ្ឋជននិងដំណើរការផ្សះផ្សានិងការស្វែងរកការពិតចំពោះការពង្រីកវិសាលភាពនៃការបកស្រាយសិទ្ធិជាមូលដ្ឋាន និងលក្ខណៈរបស់សង្គមយុត្តិធម៌ ។

ដើម្បីបង្កើតទឡ្ហីករណ៍សម្រាប់យុទ្ធសាស្រ្តជាមូលដ្ឋាន អត្ថបទនេះនឹងលើកឡើងជាឧទាហរណ៍ពីប្រទេសមួយចំនួនដូចជា ប្រទេសកម្ពុជា ប្រទេសហ្គាតេម៉ាឡា ប្រទេសអ៊ីរ៉ាក់ ប្រទេសប៉ារ៉ាហ្គាយ ប្រទេសស៊ែប៊ី និងប្រទេសមួយចំនួនផ្សេងទៀត ។ ផ្នែកទីមួយ ពន្យល់អំពីកម្លាំងជំរុញខាងផ្លូវច្បាប់ក្នុងការភ្ជាប់ការប្រមូលឯកសារទៅនឹងការការពារនិងការលើកស្ទួយសិទ្ធិមនុស្ស ។ ផ្នែកទីពីរបានពន្យល់ពិភាក្សាថាតើការប្រមូលឯកសារត្រូវធ្វើឡើងយ៉ាងដូចម្តេច? ហើយផ្នែកនេះក៏បានពន្យល់ពីសិទ្ធិ និងការទទួលខុសត្រូវរបស់ទីរក្សាតម្កល់ឯកសារ អង្គការមិនមែនរដ្ឋាភិបាល និងរដ្ឋាភិបាលបរទេសក្នុងសម័យអន្តរកាល ។ ផ្នែកទីបី បានវិភាគលើសារសំខាន់នៃវិធីសាស្រ្តរក្សា និងរៀបចំឯកសារនៅទីតម្កល់ឯកសារស្តីពីសិទ្ធិមនុស្ស ហើយក៏បានគិតគូរពីសារសំខាន់រវាងយុទ្ធសាស្រ្តជាមូលដ្ឋាន និងផលប្រយោជន៍នៃការផ្សព្វផ្សាយឯកសារជាមុនដែរ ។ ផ្នែកទីបួន ពិភាក្សាពីនីតិវិធីនិងការប្រឈមនៃការថ្លឹងថ្លែងលើសេចក្តីត្រូវការក្នុងការផ្សព្វផ្សាយព័ត៌មានស្តីពីការលើកស្ទួយការពិត និងការទទួលខុសត្រូវប្រឆាំងទៅនឹងផលប្រយោជន៍នៃការគាំទ្រឯកជនភាព និងសន្តិសុខជាតិ ។

## ១) កម្លាំងជំរុញផ្លូវច្បាប់

ការផ្តល់ហេតុផលផ្លូវច្បាប់ចំពោះការលើកស្ទួយ និងការពារទីតម្កល់ឯកសារស្តីពីសិទ្ធិមនុស្ស ផ្អែកទាំងស្រុងលើទស្សនៈនៃសិទ្ធិក្នុងការដឹងពូនិងកាតព្វកិច្ចក្នុងការកត់ត្រា ។ សិទ្ធិក្នុងការដឹងពូផ្អែកលើហេតុផលដែលថា បុគ្គលម្នាក់ៗមានសិទ្ធិដឹងពូការពិតពីទុក្ខវេទនារបស់ខ្លួននិងអ្នកជាទីស្រឡាញ់ ។ កំណត់ត្រាអំពីការរងទុក្ខវេទនារបស់មនុស្សបានក្លាយជាផ្នែកមួយនៃបេតិកភណ្ឌជាតិ ។ ទីតម្កល់ឯកសារមានសារសំខាន់ក្នុងការស្វែងរកការទទួលខុសត្រូវ និងការដឹងពីអតីតភាព ហើយនិងជួយកាត់បន្ថយការរំលោភសិទ្ធិមនុស្សនាពេលអនាគត ។ សិទ្ធិក្នុងការដឹងពូស្តែងឲ្យចេញនូវលទ្ធផលមួយចំនួនដូចជា កាតព្វកិច្ចក្នុងការកត់ត្រានិងការរក្សាព័ត៌មានទាក់ទិននឹងការរំលោភសិទ្ធិមនុស្ស និងការធ្វើឲ្យប្រាកដនូវការចង់បានព័ត៌មាន

ពីសំណាក់តុលាការ គណៈកម្មាធិការនិងសាធារណជន ។ ទោះបីជាទីតម្កល់ឯកសារពិពណ៌នាយ៉ាងល្អិតល្អន់ពីការប្រព្រឹត្តយង់ឃ្នងរបស់រដ្ឋាភិបាល និងអ្នកកាន់អំណាចអស់ពេលច្រើនសតវត្សរ៍កន្លងមកក្តី ក៏ទំនាក់ទំនងរវាងទីតម្កល់ឯកសារសំខាន់ និងសិទ្ធិមនុស្សបានទាក់ទាញចំណាប់អារម្មណ៍ពីមជ្ឈដ្ឋានអន្តរជាតិយ៉ាងខ្លាំងក្នុងអំឡុងពេលពីរសតវត្សរ៍កន្លងមកនេះ ដោយសារការដួលរលំនៃអត្តាធិបតេយ្យកុម្មុយនីស្តនៅអឺរ៉ុប ភាពផ្តាច់ការខាងយោធានៅអាមេរិកខាងត្បូង របបជិះជាន់របស់ក្រុមស្បែកសនៅប្រទេសអាហ្វ្រិកខាងត្បូង និងរដ្ឋាភិបាលដែលរំលោភបំពាននៅបណ្តាប្រទេសផ្សេងទៀត ។

បទដ្ឋានដែលទាក់ទងនឹងការប្រមូលឯកសារស្តីពីអំពើឃោរឃៅជារឿយៗទាក់ទាញយ៉ាងខ្លាំងដល់ប្រព័ន្ធច្បាប់ជាតិ ប៉ុន្តែការបង្កើតច្បាប់ស្តីពីអំពើយង់ឃ្នងនេះ ផ្សារភ្ជាប់ទៅនឹងចលនាសិទ្ធិមនុស្សអន្តរជាតិ ។ ក្រៅពីកិច្ចប្រជុំសង្គមស៊ីវិល និងក្រុមការងារជាច្រើនស្តីពីបញ្ហានេះ ក៏មានអង្គភាពរបស់អង្គការសហប្រជាជាតិមួយចំនួនដូចជា អង្គការយូណេស្កូ និងគណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានធ្វើសេចក្តីរាយការណ៍ជាច្រើនស្តីពីកិច្ចខិតខំប្រឹងប្រែងចងក្រងឯកសារនៃការរំលោភបំពានរបស់រដ្ឋាភិបាលពីអតីតកាល ។ អង្គភាពក្នុងតំបន់ក៏បានចេញសេចក្តីថ្លែងការណ៍ដែលជាប់ពាក់ព័ន្ធរឿងនេះមួយចំនួនដែរ ហើយតុលាការសិទ្ធិមនុស្សអន្តរអាមេរិកបានចេញសេចក្តីសម្រេចជាចំណុចរបត់លើកម្មវត្ថុនោះដែរ ។ ការវិវឌ្ឍផ្សេងៗដែលនឹងយកមកបកស្រាយខាងក្រោមនេះមានឥទ្ធិពលលើការពង្រឹង និងពង្រីកបទដ្ឋានអន្តរជាតិដែលទាក់ទងនឹងការចងចាំនៃការរំលោភបំពានពីអតីតកាលដែលត្រូវចងក្រងជាឯកសារប្រវត្តិសាស្ត្រ ។

## ក) សិទ្ធិស្វែងរកការពិត

បន្ទាប់ពីមានការរំលោភសិទ្ធិគោលការណ៍ជាមូលដ្ឋាន និងគ្រឹះដែលអាចពន្យល់ហេតុផលនៃការបង្កើតនិងការរក្សាឯកសាររបស់ទីតម្កល់ឯកសារបានគឺថា មនុស្សមានសិទ្ធិស្វែងរកការពិតពីការរំលោភបំពានទាំងនោះ ។ សិទ្ធិនេះទាក់ទងយ៉ាងស្អិតទៅនឹងទស្សនៈនៃសេរីភាពសារព័ត៌មាន ។ ទាំងសេចក្តីប្រកាសសិទ្ធិមនុស្សជាសាកល និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយមិនបាននិយាយសំដៅផ្ទាល់ទៅរកទីតម្កល់ឯកសារសាធារណៈ ឬទីតម្កល់ឯកសារនោះទេ ប៉ុន្តែស្ថាប័នទាំងពីរនេះដាក់បទបញ្ញត្តិដែលអះអាងថា សិទ្ធិក្នុងការស្វែងរកនិងទទួលព័ត៌មានជាផ្នែកមួយនៃសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ បានដាក់បញ្ចូលការកម្រិតព្រំដែន ទោះបីជាការអនុវត្តសិទ្ធិត្រូវអនុលោមតាមការដាក់កំហិតមួយចំនួន ប៉ុន្តែការអនុវត្តសិទ្ធិទាំងនោះ ត្រូវស្ថិតក្រោមច្បាប់ ហើយមានសារសំខាន់ចំពោះ ៖

១) ការគោរពសិទ្ធិ និងកិត្តិយសរបស់អ្នកដទៃ

២) ការការពារសន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ឬសុខុមាលភាព ឬសីលធម៌សាធារណៈ ។

បទដ្ឋាននៃសេរីភាពព័ត៌មាននិងសេរីភាពបញ្ចេញមតិ ដែលជាប់ពាក់ព័ន្ធត្រូវបានថ្លឹងថ្លែងទៅនឹងផលប្រយោជន៍សាធារណៈ ដូចជា សិទ្ធិទទួលបានឯកជនភាព និងផលប្រយោជន៍ក្នុងការរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ។ ជាសំខាន់ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយមិនបានបញ្ជាក់ច្បាស់ពីវិសាលភាពនៃកាតព្វកិច្ចតបរបស់រដ្ឋាភិបាលក្នុងការរក្សា និងផ្សព្វផ្សាយព័ត៌មានទេ ។ ចាប់តាំងពីពេលការដាក់ចេញរបស់កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយចូលជាធរមានរួចមក រដ្ឋាភិបាលសហរដ្ឋអាមេរិកបានអនុម័តច្បាប់ស្តីពីសេរីភាពសារព័ត៌មានក្នុងឆ្នាំ១៩៦៦ ។ ប្រទេសស៊ុយអែដក៏មានច្បាប់ស្តីពីសេរីភាពសារព័ត៌មាននេះដែរ ។ ចុងទសវត្សរ៍៧០ និងដើមទសវត្សរ៍៨០ ប្រទេសមួយចំនួនដូចជា កាណាដា ម៉ិចស៊ិចកូ អូស្ត្រាលី និងញូហ្សេលែនក៏បង្កើតច្បាប់នេះដែរ ។

ទោះបីជាយ៉ាងនេះក៏ដោយ ទីតម្កល់ឯកសារ និងការធ្វើកំណត់ត្រារបស់ប្រទេសទាំងនោះមានលក្ខណៈខុសប្លែកគ្នា ។ រដ្ឋាភិបាលមួយចំនួនបន្តលើកឡើងពីការព្រួយបារម្ភខាងសន្តិសុខ ដើម្បីពន្យល់ហេតុផលពីគោលនយោបាយដាក់កំហិតតឹងរ៉ឹងស្តីពីឯកសារនៃការរំលោភបំពានពីអតីតកាល ។

គំនិតនៃសិទ្ធិទទួលបានការពិតកើតឡើងក្នុងទសវត្សរ៍៨០ បន្ទាប់ពីមានការបាត់ខ្លួនជាបន្តបន្ទាប់ ជាពិសេសនៅតំបន់អាមេរិកខាងត្បូង ។ ក្រុមអ្នកឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិរួមមាន ក្រុមឃ្លាំមើលសិទ្ធិមនុស្សស្តីពីការបាត់ខ្លួនរបស់ការិយាល័យនៃគណៈ

កម្មាធិការកំពូលឃ្លាំមើលសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និងគណៈកម្មាធិការសិទ្ធិមនុស្សអន្តរអាមេរិកស្តីពីការឃ្លាំមើលសិទ្ធិមនុស្សបានពោលអះអាងពីសិទ្ធិស្វែងរកការពិតអំពីបុគ្គលបាត់ខ្លួន ។ ក្រុមអ្នកឃ្លាំមើលសិទ្ធិទាំងនោះបានចង្អុលបង្ហាញពីមាត្រា៣២នៃច្បាប់ប្រូតូកូលបំពេញបន្ថែមនៅឆ្នាំ១៩៧៧ លើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ដែលកំណត់សិទ្ធិរបស់ក្រុមគ្រួសារក្នុងការដឹងឮពីជោគវាសនារបស់សាច់ញាតិរបស់ខ្លួនក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធ ។

សិទ្ធិស្វែងរកការពិតបានក្លាយជាបទដ្ឋានចាប់តាំងពីពេលនោះមក ។ ការកកើតឡើងរបស់រដ្ឋាភិបាលប្រជាធិបតេយ្យជាច្រើនលើពិភពលោកបានធ្វើឲ្យសម្បូរឯកសារដែលចងក្រងជាប្រវត្តិសាស្ត្រដែលប្រជាជនអាចស្វែងរកព័ត៌មានដែលបានកើតឡើងពីអតីតកាល ។ រដ្ឋាភិបាលថ្មីជានិច្ចកាលមិនមានការលើកទឹកចិត្តខាងនយោបាយក្នុងការបំពេញនូវបំណងស្វែងរកព័ត៌មានទេ ។ ក្នុងសម័យអន្តរកាល មន្ត្រីរបស់រដ្ឋាភិបាលចាស់បន្តកាន់តំណែងសំខាន់ៗក្នុងរដ្ឋាភិបាល ។ ចំពោះប្រទេសដទៃទៀត មន្ត្រីរដ្ឋាភិបាលចាស់ត្រូវបានបណ្តេញចេញ ប៉ុន្តែមន្ត្រីទាំងនោះបានរក្សាអាវុធ និងប្រាក់កាសដើម្បីរុករួនផ្នែកសន្តិសុខនិងស្ថេរភាពរបស់ប្រទេសងើបឡើងជាថ្មី ។

ក្នុងបរិបទនេះ ក្រុមអ្នកគាំទ្រចំពោះការចងក្រងឯកសារបានពង្រីកភាពជាដៃគូជាមួយអន្តរជាតិ និងបានធ្វើការជាមួយភ្នាក់ងារអង្គការសហប្រជាជាតិដើម្បីបង្កើតច្បាប់និងគោលនយោបាយការពារឯកសារនៃរបបជិះជាន់ក្នុងសម័យអន្តរកាល ។ ក្នុងឆ្នាំ១៩៩៤-៩៥ អង្គការយូណេស្កូបានធ្វើការសិក្សាលើកម្មវត្ថុនេះជាមួយក្រុមប្រឹក្សាអន្តរជាតិស្តីពីទីតម្កល់ឯកសារប្រវត្តិសាស្ត្រ ។ ក្នុងឆ្នាំ១៩៩៥ អនុគណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិសម្រាប់បង្ការការរើសអើង និងការការពារជនជាតិភាគតិចរបស់គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានធ្វើសេចក្តីរាយការណ៍ពីឯកសាររបស់មេធាវីបារាំងម្នាក់ឈ្មោះលូវីស ចុតនេត ស្តីពីការលើកស្ទួយការទទួលខុសត្រូវនៃការរំលោភសិទ្ធិមនុស្សរួមបញ្ចូលទាំងការប្រើប្រាស់ទីតម្កល់ឯកសារជាប្រវត្តិសាស្ត្រ ។ មេធាវី ចុតនេត បានដាក់ជូនឯកសារនោះនៅឆ្នាំ១៩៩៧ ហើយបានគូសបញ្ជាក់គោលការណ៍គន្លឹះមួយចំនួន ។

ទាំងរបាយការណ៍ក្រុមប្រឹក្សាអន្តរជាតិស្តីពីទីតម្កល់ឯកសារប្រវត្តិសាស្ត្ររបស់អង្គការយូណេស្កូនិងមេធាវី ចុតនេត បានពោលអះអាងពីការកកើតឡើងនៃសិទ្ធិស្វែងរកការពិតដែលមិនអាចដកហូតបាន ។ មេធាវី ចុតនេត បានពោលអះអាងថា បន្ទាប់ពីការរីករាលដាលនៃការរំលោភបំពានៈ

*មនុស្សគ្រប់រូបមានសិទ្ធិស្វែងរកការពិតពីអតីតកាលដែលមិនអាចដកហូតបានស្តីពីលក្ខខណ្ឌ និងហេតុផលនៃឧក្រិដ្ឋកម្មយង់ឃ្នងតាមរយៈការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនិងមានលក្ខណៈទ្រង់ទ្រាយធំ ។ ការអនុវត្តសិទ្ធិស្វែងរកការពិតដោយពេញលេញ និងមានប្រសិទ្ធភាពមានសារៈសំខាន់ដល់ការជៀសផុតពីការកកើតឡើងវិញនៃការរំលោភបំពាននាពេលអនាគត ។*

ដូច្នេះហើយ មេធាវី ចុតនេត បានបង្ហាញថា សិទ្ធិស្វែងរកការពិតគឺជាសិទ្ធិបុគ្គលឬសិទ្ធិជាក្រុម ឬសិទ្ធិករណីយកិច្ច ។ មេធាវី ចុតនេត បានលើកឡើងថា សិទ្ធិនេះកើតឡើងស្របជាមួយសិទ្ធិទទួលបានយុត្តិធម៌និងការជួសជុលសំណង ហើយលោកមេធាវីក៏បានគាំទ្រការបង្កើតឲ្យមានការសួរចម្លើយដើម្បីលើកស្ទួយនូវសិទ្ធិទាំងពីរ ។ ប៉ុន្តែគាត់បានសង្កត់ធ្ងន់ថា សិទ្ធិទទួលការដឹងឮកើតឡើងដោយឯករាជ្យពីដំណើរការទទួលខុសត្រូវជាផ្លូវការៈ

*ដោយមិនចាំបាច់ពិចារណាលើដំណើរការនីតិវិធីណាមួយនោះទេ ជនរងគ្រោះ គ្រួសារជនរងគ្រោះ និងសាច់ញាតិមានសិទ្ធិដឹងឮការពិតដោយគ្មានការបង្អាប់ចំពោះស្ថានភាពដែលការរំលោភបំពានកើតឡើង និងជោគវាសនារបស់ជនរងគ្រោះក្នុងករណីមានការស្លាប់ និងការបាត់ខ្លួន ។*

មេធាវីបានបន្ថែមទៀតថា “ចំណេះដឹងខាងប្រវត្តិសាស្ត្រពីរបបសង្កត់សង្កិនរបស់មនុស្ស គឺជាផ្នែកមួយនៃបេតិកភណ្ឌមនុស្សជាតិ” ។ បន្ទាប់ពីនោះមក មេធាវីអន្តរជាតិម្នាក់ទៀតឈ្មោះ ដាយ អេន អូរេនលីចច័រ បានធ្វើទំនើបកម្មគោលការណ៍របស់មេធាវី ចុតនេត ហើយបានដាក់សេចក្តីកែសម្រួលថ្មីក្នុងឆ្នាំ២០០៥ ដោយឈរលើទស្សនៈស្នូលដូចគ្នានៃសិទ្ធិដឹងឮ ។

ទាំងរបាយការណ៍ដើមរបស់មេធាវី ចុតនេត និងគោលការណ៍ ចុតនេត-អូរេនលីចច័រ មិនបានបង្កើតច្បាប់រួមទេ ។ ប៉ុន្តែ

របាយការណ៍ និងគោលការណ៍នោះមានឥទ្ធិពលដល់សេចក្ដីថ្លែងការណ៍នៅគណៈកម្មាធិការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនិងវេទិកាអន្តរជាតិដទៃស្ដីពីទំនាក់ទំនងរវាងការងារប្រមូលឯកសារនិងសិទ្ធិមនុស្ស ។ របាយការណ៍របស់ក្រុមប្រឹក្សាអន្តរជាតិស្ដីពីទីតម្កល់ឯកសារប្រវត្តិសាស្ត្ររបស់អង្គការយូណេស្កូដែលកែសម្រួលរៀបចំដោយលោក អង់តូនីញ៉ូ ហ្គុងហ្សាឡេស ឃ្វីនតានា ក្នុងឆ្នាំ២០០៩ មានកម្មវត្ថុដូចគ្នាដែលដកស្រង់គោលការណ៍ដោយបានបន្ថែមសេចក្ដីលម្អិតនិងការពិភាក្សា ។

ចាប់តាំងពីពាក់កណ្ដាលទសវត្សរ៍៩០ ប្រទេសជាច្រើនបានទទួលស្គាល់ច្បាប់សិទ្ធិទទួលបានព័ត៌មានយ៉ាងហោចណាស់ក៏សិទ្ធិទទួលដឹងព្រដែរ ។ ប្រទេសជាង៨៥នាពេលបច្ចុប្បន្នមានច្បាប់សេរីភាព ទទួលបានព័ត៌មាន រួមបញ្ចូលទាំងប្រទេសកំពុងអភិវឌ្ឍនិងប្រទេសដែលទើបតែងើបពីសង្គ្រាម និងរបបសង្កត់សង្កិនជិះជាន់ផ្សេងទៀត ។ ប្រទេសមួយចំនួនបានចាត់វិធានការជាក់លាក់ដើម្បីរក្សាឯកសារប្រវត្តិសាស្ត្រទាក់ទងនឹងការរំលោភសិទ្ធិមនុស្សនិងការផ្សព្វផ្សាយឯកសារទាំងនោះ ។ ប្រទេសស្លូវ៉ាគី បានអនុម័តច្បាប់ឆ្នាំ២០០២ដោយបង្កើតឲ្យមានស្ថាប័នចងចាំរបស់ជាតិដែលស្គាល់ថាជាកាតព្វកិច្ចរបស់រដ្ឋាភិបាលក្នុងការលាតត្រដាងនូវសកម្មភាពរបស់រដ្ឋអំណាចជិះជាន់ ហើយថាក្នុងនាមរដ្ឋាភិបាលគ្មានសកម្មភាពមិនស្របច្បាប់ណាមួយប្រឆាំងនឹងប្រជាពលរដ្ឋរបស់ខ្លួនត្រូវការពារនិងបំភ្លេចនោះទេ ។ ប្រទេសប៉េរូបានអនុម័តច្បាប់តម្លាភាពនិងការទទួលបានព័ត៌មានសាធារណៈក្នុងឆ្នាំ២០០៣ដោយចែងថា “គ្រប់បុគ្គលទាំងអស់មានសិទ្ធិស្នើសុំនិងទទួលព័ត៌មានពីស្ថាប័នណាមួយនៃរដ្ឋបាលសាធារណៈ” ។ ក្នុងឆ្នាំ២០០៣ ប្រទេសហុងគ្រីបានអនុម័តច្បាប់បង្កើតឲ្យមានទីតម្កល់ឯកសារប្រវត្តិសាស្ត្ររបស់សន្តិសុខជាតិហុងគ្រីដើម្បីធានាសិទ្ធិរបស់អ្នករស់រានមានជីវិតចំពោះព័ត៌មានអំពីការរំលោភបំពានរបស់រដ្ឋាភិបាលក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់កុម្មុយនីស្ត ។ ប្រទេសអាហ្សង់ទីនបានបង្កើតទីតម្កល់ឯកសារប្រវត្តិសាស្ត្រចងចាំរបស់ជាតិក្នុងឆ្នាំ២០០៣ តាមរយៈបទបញ្ជារបស់ប្រធានាធិបតីដើម្បីការពារសិទ្ធិស្វែងរកការពិតអំពីការរំលោភបំពានដែលប្រព្រឹត្តដោយភាពផ្ដាច់ការយោធារបស់ប្រទេសនេះ ។

ក្នុងកម្រិតតំបន់ ក្រុមប្រឹក្សានៃប្រទេសអឺរ៉ុបបានអនុម័តសំណើជាបន្តបន្ទាប់ និងធ្វើសេចក្ដីថ្លែងការណ៍លើសិទ្ធិសេរីភាពសារព័ត៌មាននិងកាតព្វកិច្ចរបស់រដ្ឋាភិបាលក្នុងការផ្សព្វផ្សាយព័ត៌មានតាមកម្រិតសមហេតុផល ។ ក្នុងខែមិថុនា ឆ្នាំ២០០៦ តុលាការសិទ្ធិមនុស្សអន្តរអាមេរិកបានចេញសេចក្ដីសម្រេចស្ដីពីគោលការណ៍នៃសិទ្ធិស្វែងរកការពិត ។ ក្នុងករណីរបស់ ម៉ាហ្វែល ក្លូដ រ៉េយ៍ នៅប្រទេសឈីលី អនុសញ្ញាអាមេរិកស្ដីពីសិទ្ធិមនុស្សបង្កើតសិទ្ធិបុគ្គលក្នុងការទទួលបានព័ត៌មានដែលគ្រប់គ្រងដោយរដ្ឋ ។ មាត្រា១៣នៃអនុសញ្ញាអាមេរិកបានចែងដូចខាងក្រោម៖

១) មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពបញ្ចេញមតិ និងគំនិត ។ សិទ្ធិនេះរួមមានសេរីភាពស្វែងរក ទទួល និងផ្ដល់ព័ត៌មាន ឬគំនិតយោបល់ដោយផ្ទាល់មាត់ជាលាយលក្ខណ៍អក្សរជាទម្រង់បោះពុម្ពផ្សាយ និងទម្រង់សិល្បៈ ។

២) ការអនុវត្តសិទ្ធិដែលបានចែងក្នុងកថាខណ្ឌខាងលើមិនចាំបាច់ត្រូវអនុលោមតាមការត្រួតពិនិត្យការបោះពុម្ពផ្សាយជាមុននោះទេ ប៉ុន្តែត្រូវអនុលោមតាមវិធានទទួលខុសត្រូវជាបន្តបន្ទាប់ដែលបង្កើតឡើងដោយច្បាប់ដើម្បីធានាភាពចាំបាច់ដូចជា៖

- ការគោរពសិទ្ធិ និងកិត្តិយសរបស់អ្នកដទៃ ។
- ការការពារសន្តិសុខជាតិ សណ្ដាប់ធ្នាប់សាធារណៈ ឬសុខុមាលភាពសង្គមនិងសីលធម៌ ។

៣) សិទ្ធិបញ្ចេញមតិមិនត្រូវបានដាក់កំហិតដោយមធ្យោបាយប្រយោលដូចជា៖ ការរំលោភបំពានរបស់រដ្ឋាភិបាល ឬការគ្រប់គ្រងរបស់ឯកជនលើទំព័រសារព័ត៌មាន ប្រេកង់ផ្សព្វផ្សាយរបស់វិទ្យុ ឬឧបករណ៍ផ្សព្វផ្សាយព័ត៌មាន ឬមធ្យោបាយណាមួយដែលបង្កការលំបាកដល់ទំនាក់ទំនង ។

តុលាការបានតម្រូវថា អនុសញ្ញាអាមេរិកនិងអង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិដូចជា សេចក្ដីប្រកាសសិទ្ធិមនុស្សជាសាកលនិងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ បានបង្កើតសិទ្ធិជាវិជ្ជមានក្នុងការស្វែងរកនិងទទួលព័ត៌មាន ហើយមាត្រា១៣បានការពារសិទ្ធិគ្រប់បុគ្គលទាំងអស់ក្នុងការស្នើសុំព័ត៌មានដែលគ្រប់គ្រងដោយរដ្ឋ ប៉ុន្តែត្រូវអនុលោមតាមលក្ខខណ្ឌដូចជា៖

ទាក់ទងនឹងករណីពិតមួយ តុលាការរកឃើញថា តាមរយៈ

*ការចែងសិទ្ធិស្វែងរក និងទទួលព័ត៌មាន មាត្រា១៣នៃអនុសញ្ញាបានការពារសិទ្ធិគ្រប់បុគ្គលទាំងអស់ក្នុងការស្នើសុំព័ត៌មានដែលគ្រប់គ្រងដោយរដ្ឋ ដែលអនុញ្ញាតជាពិសេសដោយលក្ខខណ្ឌនៅក្នុងអនុសញ្ញានោះ ។ ដូច្នេះ មាត្រានេះការពារសិទ្ធិបុគ្គលក្នុងការទទួលព័ត៌មាននិងកាតព្វកិច្ចជាវិជ្ជមានរបស់រដ្ឋក្នុងការផ្តល់ព័ត៌មានទាំងនោះ ដែលបុគ្គលអាចទទួលបានព័ត៌មាន ឬចម្លើយរួមដែលមានការស្វែងរកហេតុផល ។ សម្រាប់ហេតុផលខ្លះដែលអនុញ្ញាតដោយអនុសញ្ញា រដ្ឋត្រូវបានអនុញ្ញាតឲ្យដាក់កំហិតលើការទទួលព័ត៌មានក្នុងករណីពិសេស ។ ព័ត៌មានគួរតែផ្តល់ដោយមិនចាំបាច់បង្ហាញចំណាប់អារម្មណ៍ដោយផ្ទាល់និងបុគ្គលដែលជាប់ពាក់ព័ន្ធ ដើម្បីទទួលព័ត៌មានលើកលែងតែករណីដែលលក្ខខណ្ឌផ្លូវច្បាប់ត្រូវអនុវត្ត ។*

ករណីរបស់ ហ្គូម លុនដ៍ នៅប្រទេសប្រេស៊ីលក្នុងខែធ្នូ ឆ្នាំ២០១០ តុលាការអន្តរសិទ្ធិមនុស្សអន្តរអាមេរិកបានសម្រេចថារដ្ឋាភិបាលប្រេស៊ីលគាំទ្រសិទ្ធិទទួលស្វែងរកការពិត ដោយប្រកាន់ខ្ជាប់ថារដ្ឋាភិបាលនេះត្រូវផ្តល់កំណត់ហេតុសាធារណៈ ដែលជាប់ពាក់ព័ន្ធទាំងអស់ទៅគ្រួសាររបស់ក្រុមជីវពលដែលបានបាត់ខ្លួនដោយសារកងកម្លាំងរក្សាសន្តិសុខកាលពីទសវត្សរ៍៧០ ។ ក្នុងកថាខណ្ឌមួយ ដែលគួរកត់សំគាល់ តុលាការបានពោលអះអាងថា ៖

*ក្នុងករណីរំលោភសិទ្ធិមនុស្ស រដ្ឋអំណាចរដ្ឋាភិបាលមិនអាចលាក់កំបាំងព័ត៌មានក្រោមយន្តការដូចជា ការរក្សាការសម្ងាត់របស់រដ្ឋ ការលាក់កំបាំងព័ត៌មាន ឬដោយសារផលប្រយោជន៍សាធារណៈ ឬសន្តិសុខជាតិ ក្នុងការគេចវេះផ្តល់ព័ត៌មានដែលទាមទារដោយសមត្ថកិច្ចរដ្ឋបាល ឬសមត្ថកិច្ចតុលាការដែលទទួលបន្ទុកស៊ើបអង្កេតនោះទេ ។ ក្រៅពីនេះ ពេលដែលការស៊ើបអង្កេតទាក់ទងនឹងបទល្មើសដាក់ទោសទណ្ឌ សេចក្តីសម្រេចដើម្បីដាក់កម្រិតព័ត៌មានថាជាការរក្សាការសម្ងាត់ និងការបដិសេធមិនឲ្យផ្សព្វផ្សាយព័ត៌មានមិនត្រូវផ្អែកលើអង្គភាពរដ្ឋាភិបាល ដែលសមាជិករបស់ខ្លួនជាប់ពាក់ព័ន្ធការប្រព្រឹត្តអំពើឧក្រិដ្ឋ ។*

អង្គភាពរបស់អង្គការសហប្រជាជាតិក៏បានយល់ច្បាស់ដែរអំពីសិទ្ធិស្វែងរកការពិត ។ ក្នុងឆ្នាំ២០០៥ គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានអនុម័តសេចក្តីសម្រេច ២០០៥/៦៦ ដោយទទួលស្គាល់សារសំខាន់នៃការគោរពនិងការធានាឲ្យមានសិទ្ធិស្វែងរកការពិតដើម្បីបញ្ចប់ការរួចទោស និងដើម្បីលើកស្ទួយនិងការពារសិទ្ធិមនុស្ស ។ សេចក្តីសម្រេច ២០០៥/៦៦បានតម្រូវឲ្យការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិធ្វើការសិក្សាពី "មូលដ្ឋាន វិសាលភាព និងខ្លឹមសារសិទ្ធិនេះក្រោមច្បាប់អន្តរជាតិ ព្រមទាំងការអនុវត្តសិទ្ធិដ៏មានប្រសិទ្ធភាព" ។ ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានធ្វើរបាយការណ៍នៅឆ្នាំបន្ទាប់ដោយរកឃើញថា សិទ្ធិស្វែងរកការពិតដែលមិនអាចដកហូតបានគឺជាសិទ្ធិបុគ្គលនិងជាក្រុម ។ របាយការណ៍នេះផ្អែកលើគំហើញរបស់ខ្លួនលើប្រភពជាច្រើន រួមមាន អនុសញ្ញាក្រុងហ្សឺណែវ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងករណីច្បាប់ជាតិ និងអន្តរជាតិ និងលិខិតុបករណ៍ច្បាប់ ដែលបង្កើតឲ្យមានគណៈកម្មាធិការស្វែងរកការពិត និងសំណើជាច្រើនអនេក និងលិខិតុបករណ៍ផ្សេងៗដែលកើតចេញពីអង្គភាពឃ្លាំមើលសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ហើយនិងស្ថាប័នក្នុងតំបន់ និងអន្តរជាតិ ។ ក្រោយពីជំនួសតំណែងគណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានអនុម័តសំណើរបស់ខ្លួនស្តីពីសិទ្ធិស្វែងរកការពិតក្នុងឆ្នាំ២០០៨ ដែលលើកឡើងជាថ្មីនូវបទបញ្ញត្តិនៃសេចក្តីសម្រេច២០០៥/៦៦ ។

ក្នុងឆ្នាំ២០១០ កតិកាសញ្ញាអន្តរជាតិដើម្បីការការពារមនុស្សពីការបាត់ខ្លួនបានចូលជាធរមាន ។ អនុសញ្ញានេះអះអាងពី "សិទ្ធិរបស់ជនរងគ្រោះក្នុងការស្វែងរកការពិតអំពីស្ថានភាពនៃការបាត់ខ្លួន និងជោគវាសនារបស់អ្នកបាត់ខ្លួន និងសេរីភាពស្វែងរកទទួល និងផ្តល់ព័ត៌មាន" ។ កថាខណ្ឌខាងលើបានចែងដូចគ្នាទៅនឹងការចែងរបស់សេចក្តីប្រកាសសិទ្ធិមនុស្សជាសាកល និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដោយភ្ជាប់ទស្សនៈសេរីភាពសារព័ត៌មាន ។ អនុសញ្ញានេះ ក៏បានបញ្ជាក់អំពីថាតើព័ត៌មានប្រភេទណាដែលជំរុញដល់ការស្វែងរកការពិតដោយតម្រូវឲ្យរដ្ឋផ្តល់ សាច់ញាតិ ឬក្រុមប្រឹក្សាច្បាប់អំពីព័ត៌មានថាតើ

នរណាបញ្ជាលើករណីបាត់ខ្លួន ឬការបាត់ខ្លួនកើតឡើងនៅឯណា ឬពេលណា? ឬទីតាំងរបស់អ្នកបាត់ខ្លួន និងសេចក្តីលម្អិតពីសុខភាព ការដោះលែងនិងការស្លាប់ ប្រសិនបើមានការស្នើសុំ ។ អនុសញ្ញាមានករណីលើកលែងពិសេសចំពោះឯកជនភាព និងសន្តិសុខ ប៉ុន្តែអនុសញ្ញានេះនៅតែធានាសិទ្ធិរបស់អ្នកបាត់ខ្លួន ។ អនុសញ្ញានេះទទួលបានប្រទេសជាហត្ថលេខីជាង៩០ ។ នេះគឺជាការស្តែងជាលាយលក្ខណ៍អក្សរនូវសិទ្ធិស្វែងរកការពិតដែលផ្អែកលើសន្ធិសញ្ញា ។ កំណត់ត្រាជាផ្លូវការទាក់ទងនឹងការរំលោភសិទ្ធិមនុស្សត្រូវគេហាមឃាត់ក្នុងប្រទេសជាច្រើន ទាំងអំឡុងពេលឯកសារត្រូវចាត់ទុកជាការសម្ងាត់ និងដោយសាររបបមួយដែលមិនចង់ផ្សព្វផ្សាយឯកសារសោះ ។ វាដូចជាការពោលបំផ្លើសដែលថា សិទ្ធិស្វែងរកការពិតត្រូវទទួលស្គាល់ជាសកល ។ ទោះបីជាយ៉ាងនេះក៏ដោយ វាបានលើកឡើងក្នុងសេចក្តីថ្លែងការណ៍របស់សិទ្ធិមនុស្សអន្តរជាតិ ហើយមានឥទ្ធិពលដល់ប្រទេសលោកខាងលិចនិងប្រទេសប្រជាធិបតេយ្យនៅអឺរ៉ុបកណ្តាលខាងកើត និងអាមេរិកខាងត្បូង ។ ការអនុវត្តរបស់រដ្ឋក្នុងវង្វង់ច្បាប់សេរីភាពសារព័ត៌មានគឺជាសេចក្តីថ្លែងនិងការសម្រេចចិត្តនៃអង្គភាពក្នុងតំបន់ដែលគូសបញ្ជាក់ពីការកកើតឡើងនៃសិទ្ធិស្វែងរកការពិតក្រោមទម្លាប់ច្បាប់អន្តរជាតិ ។

## ១) កាតព្វកិច្ចចងក្រងឯកសារ

សិទ្ធិស្វែងរកការពិតលើកឡើងថា សាធារណជនគួរតែអាចទទួលបានព័ត៌មានអំពីការរំលោភសិទ្ធិមនុស្សរបស់រដ្ឋ ប៉ុន្តែដើម្បីឲ្យវាកាន់តែប្រសើរ ព័ត៌មានអំពីការរំលោភបំពានរបស់រដ្ឋពីអតីតកាល គួរតែអាចរកបាន ។ ដូច្នេះហើយសិទ្ធិនេះលើកឡើងថា រដ្ឋមានកាតព្វកិច្ចតបក្នុងការកត់ត្រានិងរក្សាឯកសារប្រវត្តិសាស្ត្ររួមមាន ឯកសារបោះពុម្ពផ្សាយ ខ្សែភាពយន្ត រូបថត និងព័ត៌មានផ្សេងៗ ។ របាយការណ៍របស់មេធាវី ចុតនេត និងគោលការណ៍កែសម្រួល ចុតនេត-អូរេនលីចច័រ មានឥទ្ធិពល ដល់ការកសាងទំនាក់ទំនងនេះ ។ គោលការណ៍នោះអះអាងថា រដ្ឋមានកាតព្វកិច្ច “រក្សាឯកសារប្រវត្តិសាស្ត្រនិងភ័ស្តុតាងទាក់ទងនឹងការរំលោភសិទ្ធិមនុស្ស និងច្បាប់មនុស្សជាតិ ហើយរដ្ឋត្រូវគាំទ្រការយល់ដឹងពីការរំលោភបំពាន” ។ គោលការណ៍នោះផ្តោតលើអំណាចរបស់ទីតម្កល់ឯកសារលើដំណើរការទទួលខុសត្រូវ និងការរក្សាការចងចាំប្រវត្តិសាស្ត្រដោយប្រឆាំងនឹងការលើកឡើងរបស់អ្នកសេរីនិយមនិងអ្នកអវិជ្ជមាននិយម ។ គោលការណ៍ ចុតនេត-អូរេនលីចច័របានផ្តល់អនុសាសន៍មួយចំនួនស្តីពីរបៀបគ្រប់គ្រងឯកសារប្រវត្តិសាស្ត្រដើម្បីជួយដល់ការចងចាំនិងការស្វែងរកយុត្តិធម៌ ។ ចំពោះរបាយការណ៍ទៅគណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅឆ្នាំបន្ទាប់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានអះអាងថា “ការទទួលបានព័ត៌មាន ជាពិសេសការទទួលបានឯកសារប្រវត្តិសាស្ត្រមានសារៈសំខាន់ដល់ការអនុវត្តសិទ្ធិស្វែងរកការពិត” ។ បន្ទាប់មកក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានស្នើសុំថាការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិគួរតែធ្វើការសិក្សាស្តីពីការអនុវត្តសិទ្ធិស្វែងរកការពិត រួមមានជាពិសេសការអនុវត្តទាក់ទងការប្រមូលនិងការកត់ត្រាឯកសាររំលោភបំពានសិទ្ធិមនុស្សក្នុងន័យការការពារឯកសារនិងកំណត់ត្រា ។

ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានដាក់ជូនរបាយការណ៍របស់ខ្លួនក្នុងឆ្នាំ២០០៩ ដោយគូសបញ្ជាក់ពីតួនាទីរបស់ទីតម្កល់ឯកសារក្នុងការអនុវត្តសិទ្ធិស្វែងរកការពិតនិងកាតព្វកិច្ចរបស់រដ្ឋក្នុងការរក្សាកំណត់ត្រារបស់រដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ការទទួលយកឯកសារមិនផ្លូវការពាក់ព័ន្ធការបង្កើតច្បាប់គ្រប់គ្រងឯកជនភាព និងការទទួលព័ត៌មាន និងការបង្កើតយន្តការការពារនិងគ្រប់គ្រងឯកសារឲ្យមានប្រសិទ្ធភាព ។

ក្នុងករណីរបស់ ម៉ាហ្វែល ក្លូដ រ៉េយ៍ នៅប្រទេសឈីលី តុលាការសិទ្ធិមនុស្សអន្តរអាមេរិកបានចង្អុលបង្ហាញសេចក្តីប្រកាសជាច្រើនរបស់អង្គភាពក្នុងតំបន់អាមេរិក រួមមានសេចក្តីប្រកាសនូវ៉ៅ លីអន ឆ្នាំ២០០៤ ។ ប្រមុខរដ្ឋដែលចូលរួមកិច្ចប្រជុំតំបន់អាមេរិកបាន “សន្យាផ្តល់ក្របខ័ណ្ឌច្បាប់ រចនាសម្ព័ន្ធលក្ខខណ្ឌដែលធានាសិទ្ធិទទួលព័ត៌មានរបស់ប្រជាពលរដ្ឋ” ដោយទទួលស្គាល់ថា “ការទទួលព័ត៌មានដែលគ្រប់គ្រងដោយរដ្ឋត្រូវអនុលោមតាមបទដ្ឋានគតិយុត្តិនិងរដ្ឋធម្មនុញ្ញរួមមានបទដ្ឋានស្តីពីឯកជនភាពនិងការលាក់ការសម្ងាត់ដែលជាលក្ខខណ្ឌដ៏សំខាន់សម្រាប់ប្រជាពលរដ្ឋ ។

**(នៅមានត)**

**ឆន ឆរឆីរអារី**

# ស៊ីវ ធួន : ដំណើរឆ្លងកាត់របបខ្មែរក្រហម



ស៊ីវ ធួន ថតនៅឆ្នាំ១៩៨៤

**(តពីលេខមុន)**

## កងកុមាររបស់អង្គការ

បើកាលណាគេធ្វើដំណើរតាមផ្លូវជាតិពីជប់ទៅកើត យើងឃើញភូមិមួយដែលស្ថិតនៅខាងជើងផ្លូវជាតិដែលមានស្រែជម្រៅ ហើយហួសវាលស្រែបន្តិចមានដើមត្នោតដុះជាជួរ និងដើមឫស្សីដុះចាក់ស្រេះគ្នាពណ៌ខៀវស្រងាត់ ក្លាយជារនាំងធម្មជាតិមួយដែលបិទបាំងមិនឲ្យយើងឃើញដំបូលផ្ទះដោយស្រួលឡើយ ភូមិនោះហៅភូមិទេពប្រសា ។ យើងដើរហួសពីភូមិទេពប្រសាឆ្ងងស្ពានមួយ ហើយយើងធ្វើដំណើរមួយស្របក់ទៀតទើបទៅដល់ភូមិមួយទៀតឈ្មោះភូមិរហាល ដែលមានផ្ទះនៅអមសងខាងផ្លូវជាតិ ជាភូមិដែលសំបូរទៅដោយផ្ទះដំបូលប្រក់ស្លឹក ព្រោះផ្ទះក្បឿងធំៗត្រូវខ្មែរក្រហមរុះរើ យកទៅធ្វើជារោងបាយ ឬហៅថា រោងសហករណ៍ ប៉ុន្តែខ្មែរក្រហមនៅរក្សាទុកផ្ទះបិតមួយចំនួន (ផ្ទះបុរាណ) ដែលគេយល់ថាអាចទុកឲ្យកងកុមារពី៥០ ទៅ ៦០នាក់រស់នៅ ដែលគេហៅម្យ៉ាងទៀតថា (មណ្ឌល) ។ នៅមុខផ្ទះប្រភេទនេះ ច្រើនតែមានដើមឈើធំៗចោលម្លប់ត្រឈឹងត្រឈៃ គឺជាថ្នាក់រៀន ដែលគ្រូបង្រៀនតែព្យញ្ជនៈ និង ស្រៈបន្តិចបន្តួចប៉ុណ្ណោះដល់កុមារ ។ ថ្នាក់រៀនភាគច្រើនចាប់ផ្ដើមពីម៉ោងប្រាំពីរកន្លះ ហើយចេញនៅម៉ោងដប់ ថ្នាក់រៀនក៏មានសកម្មភាពផ្សេងៗ ដូចជា ឲ្យកុមាររៀន ច្រៀងចម្រៀងបដិវត្តន៍ ដូចជា បទ “យើងខ្ញុំកុមារស្រឡាញ់អង្គការឥតព្រំដែន” និងផ្សព្វផ្សាយពីមនោគមវិជ្ជាខ្មែរក្រហមជាដើម ។

បន្ទាប់ពីច្រៀងចម្រៀងបដិវត្តន៍រួច គ្រូក៏បំបែកជួរកុមារឲ្យចូលព្រៃល្បោះនៅក្បែរភូមិដើម្បីកាប់ដើមទន្រ្ទានខែត្រមកលាយជាមួយដីដំបូកធ្វើជី ជួនកាលទៀតគេឲ្យកងកុមារដើររើសអាចម៍គោនៅតាមវាលស្រែមកធ្វើជាជីដែរ ។ កងកុមារមានរបបអាហារស្គួចស្គើង និងមានសម្បុរស្លេកស្លាំង ហើយជួនកាលមានកុមារមួយចំនួនកើតជំងឺហើមទៀតផង ។ កុមារទាំងនោះ ស្ថិតនៅក្នុងវ័យដែលត្រូវទទួលការថ្នាក់ថ្នមពីឪពុកម្ដាយ និងរស់នៅជាមួយឪពុកម្ដាយ ប៉ុន្តែត្រូវអង្គការឲ្យទៅរស់នៅក្នុងជំរំប្រមូលផ្ដុំ ហើយឲ្យស្គាល់តែអង្គការជាឪពុកម្ដាយប៉ុណ្ណោះ ។ មនោគមវិជ្ជាខ្មែរក្រហមនេះបានធ្វើឲ្យកុមារភ្លេចឪពុកម្ដាយដែលជាអ្នកមានគុណ ។ ក្មេងៗដែលជាកូនអង្គការទាំងនោះ ពុំដែលទទួលពាក្យផ្អែមល្ហែមទេ គឺមានតែពាក្យលត់ដំ និងបេ្ដជ្ញាគោរពអង្គការ ។ ជួនកាលកុមារខ្លះ ត្រូវរងទារុណកម្មដល់ស្លាប់ ដោយគ្រាន់តែបេះត្របែកមួយផ្លែ ឬយកដំឡូងជ្វាឆៅមួយមើមរបស់អង្គការ ។

## ភូមិព្រៃមាន់

យើងដើរញាប់ជើងរហូតឆ្លងផុតភូមិរហាល យើងពុំឃើញមានភូមិណាទៀតទេ នៅទីនោះគឺជាវាលល្ហល្ហេវដែលលាត

សន្ទឹងដោយវាលស្រូវទុំពណ៌លឿងឆ្អៅ ខ្លះឈរខ្លះដួលរាបដល់ដីមានសណ្ឋាន ដូចសក់ដែលគេសិតទាំងនៅសើម ។ នៅក្បែរថ្នល់ជាតិសម្បូរទៅដោយថ្លុក ត្រពាំង ដែលមានត្រីផ្ទៀក ដូចបាយពុះដួនកាលត្រីរ័ស់ដែលម្តងៗនៅក្នុងទឹកពណ៌ថ្លាខ្យង ។ យើងឃើញមាត់ត្រីច្រើនបែបនោះ នាំឲ្យយើងនឹកឃើញបាយស្រួយជាមួយសម្លរម្ជូរ ឬត្រីអាំងជាមួយបុកក្រសាំង ឬក៏ត្រីរ័ស់ ឬត្រីក្រាញ់ស្ងោរជ្រក់ ប៉ុន្តែនេះគ្រាន់តែជាការស្រមៃនៅក្នុងអារម្មណ៍ដែលកំពុងតានតឹងនៅក្នុងរបបគុកឥតជញ្ជាំងប៉ុណ្ណោះ ។

ពេលដែលដំណើរកាន់តែរំកិលទៅមុខហួសភូមិរហាលនៅក្រោមកម្តៅថ្ងៃនារដូវប្រូតកាត់ យើងមានការហេវហត់ យើងក៏ដាក់បង្ហិច អង្គុយនៅក្បែរផ្លូវជាតិដោយរកម្លប់ជ្រកពុំឃើញព្រោះកំណាត់ផ្លូវនោះ ជាវាលស្រឡះពុំមានដើមឈើសូម្បីតែមួយដើម ។ រំពេចនោះយើងចុះទៅក្នុងប្រឡាយដើម្បីសម្លឹងមើលកន្លែងដែលមានទឹកថ្លា ខ្ញុំឱនក្រេបទឹកដូចសត្វគោដែលដោះពីនឹមដោយគ្រាន់តែយកដៃវែកគុម្ពស្រងែ និងស្មៅបាយដំណើបដែលមានស្មៃរុំព័ទ្ធ ។ លុះផឹកឆ្អែតហើយ យើងក៏លុបមុខដើម្បីឲ្យត្រជាក់ភ្នែក ។ យើងសម្លឹងមើលទៅទិសខាងកើតនៅឯនាយ យើងឃើញចំណុចពណ៌ប្រផេះដូចផ្សែង ដែលមិនអាចសន្និដ្ឋានបានថា ជាភូមិ ឬជាជួរព្រៃតាមដងស្ទឹងនៅឡើយ ។ ពួកយើងទាំងបីនាក់ខំស្រូតដំណើរទាំងទន់ជង្គង់ទៅមុខទៀត ពេលនោះមិត្ត អ៊ិន និង មិត្ត វ៉ាន់ ទាំងពីរនាក់សុទ្ធសឹងជាអ្នកមានដើមកំណើតនៅកម្ពុជាក្រោម មិត្តសុវណ្ណ ជានិស្សិតនិយាយភាសាខ្មែរច្បាស់ជាងមិត្តអ៊ិន ដែលជាអ្នកធ្វើការនៅស្ថានទូតសហរដ្ឋអាមេរិក ។ នៅក្នុងទសវត្សរ៍៦០ ខ្មែរកម្ពុជាក្រោមដែលឆ្លងពីស្រុកយួនមករស់នៅស្រុកខ្មែរភាគច្រើនជាព្រះសង្ឃ ដូចជា មិត្ត អ៊ិន ជាដើម ។ មួយសន្ទុះក្រោយមកចំណុចផ្សែងលេចរូបរាងកាន់តែច្បាស់ម្តងបន្តិចៗ ទើបយើងកំណត់ភិនភាគបានគឺជាជួរព្រៃ ដែលមានពណ៌ខៀវចាស់ ។

យើងក៏ខំប្រឹងធ្វើដំណើរបន្តទៅទៀតដើម្បីឆាប់ទៅដល់ភូមិព្រៃមាន់ តាមការពិតយើងមិនស្គាល់ទីតាំងភូមិនោះច្បាស់លាស់ទេ ប៉ុន្តែនៅពេលចេញពីសហករណ៍ព្រះនេត្រព្រះ គេប្រាប់ថាភូមិដែលយើងទៅនោះ នៅខាងកើតភូមិរហាល តាមបណ្តោយផ្លូវជាតិលេខ៦ ។ យើងក៏សន្និដ្ឋានថា ភូមិនេះហើយជាភូមិព្រៃមាន់តែម្តង ។ នៅចម្ងាយតែ៥០០ម៉ែត្រទៀតយើងនឹងទៅដល់ភូមិនោះ ។ យើងចង់ទៅដល់ឲ្យបានឆាប់ព្រោះមានការហេវហត់ខ្លាំង ។ លុះរំកិលកាន់តែជិត នៅសល់ចម្ងាយប្រហែល១០០ម៉ែត្រខាងមុខ យើងឃើញដើមស្វាយ និងដើមចេកដុះព័ទ្ធជុំវិញផ្ទះដែលមានដំបូលប្រក់ស័ង្កសីរាងទ្រវែងដូចផ្ទះកម្មករនៅជួរខាងក្រោយភូមិ ។ រំពេចនោះ យើងទៅដល់ចំពីមុខភូមិព្រៃមាន់ ដែលស្ថិតនៅខាងត្បូងផ្លូវជាតិលេខ៦ចំមាត់ច្រកចូលទៅស្រុកភ្នំស្រុកតាមផ្លូវលំដែលក្រាលក្រួសក្រហម ។ ភូមិនេះ នៅអែបជាប់នឹងផ្លូវដែលខាងមុខមានដើមស្វាយធំៗបែកមែកសាខាមានម្លប់ត្រឈឹងត្រឈៃគ្របពីលើផ្ទះមួយខ្នង និងរោងបាយរួមមួយ ។

## បាយមួយពេលយ៉ាងឆ្ងាញ់

ពេលយើងដើរចូលទៅក្នុងភូមិនោះស្រាប់តែមានមនុស្សអ៊ូអរលោយឡំ និងសំឡេងក្មេងៗរត់លេង ប្រសេកប្រសាច និងឃើញមានមនុស្សល្បាក់ពី៣០ឆ្នាំ ដល់៥០ ឬ៦០ឆ្នាំ កំពុងអង្គុយសម្រាកក្រោយពីបាយថ្ងៃត្រង់ ហើយខ្លះជក់បារី ខ្លះអង្គុយជជែកគ្នា ។ ប៉ុន្តែនៅចន្លោះហ្វូងមនុស្សទាំងនោះ យើងឃើញមនុស្សម្នាក់ល្បាក់៥០ឆ្នាំ ស្លៀកសារុងសូត្រ ពាក់អាវយឺតសដៃខ្លី សម្បុរស្រអែម សំឡេងគ្រលរ កម្ពស់១.៦០ម៉ែត្រ ទឹកមុខថ្លាពោរពេញដោយមនោសញ្ចេតនា ប៉ុន្តែមានខ្សែភ្នែកមុត ច្រមុះស្រួច បង់កក្រមា និស្ស័យដូចគណៈកម្មាធិការវត្តពីសង្គមចាស់ ។ គ្រាន់តែឃើញឫកពារអាចឲ្យដឹងថា បុរសវ័យចំណាស់នោះ ជាអ្នកក្តាប់អង្គភាពជាងនេះទាំងមូល ។

យើងទាំងបីនាក់ក៏ដើរឱនដោយបន្ទន់ដងខ្លួន ហើយបោះសម្តីទៅកាន់គាត់ថា យើងទាំងបីនាក់មកពីអង្គភាពចល័ត តាវ៉ាល់ត្រូវអង្គការចាត់ឲ្យចូលនៅក្នុងអង្គភាពជាង ។ គ្រាន់តែឮមកពីអង្គភាពចល័ត តាវ៉ាល់ គាត់ក៏ងក់ក្បាលព្រមទទួល ហើយក៏សួរថាតើមិត្តទាំងអស់គ្នាហូបបាយហើយឬនៅ យើងក៏ឆ្លើយព្រមគ្នាថាមិនទាន់ហូប ទើបគាត់ប្រាប់ តាក្រង ដែលជាចុងភៅឲ្យរៀបចំបាយមួយចានពង្រីខ្សៀន និងសម្លមួយចានគោមនោះដាក់នៅលើតុគឺសម្លម្ជូរព្រលិតលាយជាមួយត្រីកញ្ចុះ និងកូនត្រីក្រាញ់ ។

កាលនោះយើងហូបយ៉ាងឆ្ងាញ់ដោយផ្តោតអារម្មណ៍ទៅរកសម័យសង្គមចាស់ ដូចជា យើងនៅក្នុងហាងមួយ ព្រោះ

ឃើញអ្វីៗនៅក្នុងរោងបាយមានការរៀបចំស្អាតបាត និងមានសណ្ដាប់ធ្នាប់ ។ តាក្រង ជាមេចុងភៅ ដក់បារីស្លឹកសង្កែ មិនសូវពាក់អាវ ស្លៀកតែក្រមា ជួនកាលទៀត ស្លៀកតែខោខ្លី ខ្លួនកោងបន្តិច មានញើសហូរសស្រាក់ពេញទាំងខ្លួននៅពេលដាំស្ល្មង១ ។ តាក្រង ជាអ្នកបួស ត្រូវផ្សឹកនៅពេលដែលខ្មែរក្រហមចូលដល់ទីក្រុងភ្នំពេញ មានស្រុកកំណើតនៅអរិយក្សត្រ ពុំមានកូនប្រពន្ធទេ ។ ទឹកមុខ និង សម្ដីមានសុជីវធម៌ធ្វើឲ្យអង្គភាពទាំងមូលចូលចិត្តគាត់ ។ ចំណែក តាម៉ុង ជាមេអង្គភាព គាត់រស់នៅភូមិព្រៃមាន់ជាមួយប្រពន្ធកូនទាំងអស់ដោយសុខដុមរមនាពុំមានទុក្ខព្រួយ ព្រោះគាត់ជាអ្នកក្ដាប់អង្គភាពជាងទូទាំងតំបន់៥ ទាំងជាងដែក ជាងបេតុង (ស្ពាន) និងជាងឈើ ។ អ្វីៗនៅក្នុងអង្គភាពទុកដូចជាសម្បត្តិរបស់គាត់ ចាប់ពីផ្ទះសម្បែង គោរអំពៃ ជ្រូក មាន់ទា ចម្ការដំឡូង ព្រមទាំងជង្រុកស្រូវ ។

## ភាសាអ្នកតំបន់៥

មនុស្សនៅតំបន់៥ គឺមានភាសាដើនដូចអ្នកសៀមរាប ហើយមានពាក្យស័ព្ទមួយចំនួនខុសពីអ្នករស់នៅតាមខេត្ត នៅផ្នែកខាងក្រោម ដូចជា កំពង់ស្ពឺ កំពត តាកែវ ស្វាយរៀង ព្រៃវែង ។ បានសេចក្ដីថា និយាយដូចអ្នកខេត្តសៀមរាប កំពង់ធំ ហើយក៏ដូចខេត្តកំពង់ចាម នៅស្រុកមេមត់ នៅម្ដុំភូមិជា, ដាំខ្សង, ដាំត្រៀក និងភូមិមេកងជាដើម ។ ចំណែកអ្នកស្រុកនៅស្រែះ ហៅផ្លែត្របែកថាផ្លែល្ហួត ។ ចប ហៅ ជ្រនីក ។ កំសៀវ ហៅ តាកោ ។ អៀនប្រៀន ហៅ អៀល ។ ខ្ទឹម ហៅ រអៀក ។ អស់កម្លាំង ហៅថា សោ ។ គូថ ហៅថា ត្រពោក ហើយប្រសិនបើអ្នកណានិយាយអាសអាភាស គេថាអ្នកនោះនិយាយតាឡូកជាដើម ។

ខ្ញុំចំណាយពេលជាងបីខែដើម្បីស្ដាប់ឲ្យយល់ភាសាអ្នកស្រុកនោះ ។ ចំពោះសម្លេងដែលមានខ្យល់ឃោសៈ គេអានចំអក្សរល្អណាស់ ដូចជាឈ្មោះមនុស្ស មិត្តរឿត, ឈឿត ចេញសំឡេងច្បាស់មិនអាចច្រឡំនិងខ្យល់អឃោសៈបានទេ ។ តាម៉ុង មេអង្គភាពមានដើមកំណើតនៅស្រុកភ្នំស្រុក គាត់ជាមេជាងនៅសម័យសង្គមចាស់ ពិសេសគាត់ដើរម៉ៅការសំណង់ធំៗដូចជា កុដិព្រះវិហារ ឬផ្ទះធំស្កឹមស្កៃ របស់ពួកថៅកែ ឬអ្នកមាន ។

## អង្គភាព តាម៉ុង

ក្រុមជាងនៅក្នុងអង្គភាព តាម៉ុង មានជាងប្រហែល៦០នាក់ ព្រមទាំងប្រពន្ធកូនដែលរស់ក្នុងបន្ទប់ខណ្ឌចែកគ្នាជាគ្រួសារ ដែលមានប្រពន្ធកូនផង ទាំងអស់ប្រហែល១៥០នាក់ជាកម្លាំងសម្រាប់បង្កបង្កើនផលនៅលើដីស្រែនៅជុំវិញភូមិចម្ងាយរហូតដល់ជិតមួយគីឡូម៉ែត្រ លាតសន្ធឹងលើផ្ទៃដីរាបស្មើបហិកតា ។ អង្គភាពនេះធ្វើស្រែ និងចម្ការដំឡូងមីដើម្បីផ្គត់ផ្គង់សមរភូមិមុខ ពីព្រោះមានអង្គភាពជាងមួយចំនួនទៀតកំពុងជាប់ដៃធ្វើស្ពាននៅតាមទំនប់ត្រពាំងថ្ម ទំនប់ស្ពានស្រែងជាដើម ។ អង្គភាពនេះ ជាអង្គភាពស្វយ័តដែលធ្វើខ្លួនឯងសម្រាប់ផ្គត់ផ្គង់ខ្លួនឯង មិនយកស្បៀងពីក្រៅ (មិនដែលបើកអង្ករពីស្វាយស៊ីសុផុន) ។ ប៉ុន្តែក្រោយមករហូតដល់ឆ្នាំ១៩៧៨ អ្នកនៅព្រៃមាន់បាននិយាយថា ហូបបាយមិនឆ្អែត ក៏នាំគ្នាលួចស្ទុះស្វែងរកបន្លែ និងក្ដាមខ្យងមកស្ល ។ មួយខែក្រោយមក ក្មេងៗក៏ចាប់ផ្ដើមយំនៅពេលកណ្ដាលយប់ ដោយសារការស្រេកឃ្លានព្រោះហូបមិនឆ្អែត ។ ប្រជាជនតែងនិយាយចំអកថា រាត្រីនៅព្រៃមាន់ ព្រោះតែធុញទ្រាន់នឹងសម្លេងក្មេងយំធ្វើឲ្យរំខានដំណេកនៅកណ្ដាលយប់ស្ងាត់ ដោយជួនកាលបណ្ដាលមកពីឈឺពោះមកពីវាបរិភោគបន្លែផ្ដេសផ្ដាសច្រើនពេក ។ ចាប់តាំងពីពេលនោះ ការអត់ឃ្លានខ្លាំងបានបង្ខំឲ្យមនុស្សហ៊ានចេញទៅរកអាហារ បំពានលើពាក្យស្លោកថា អង្គការភ្នែកម្នាស់ មានន័យថា អ្នកណាធ្វើអ្វីដែលផ្ទុយ និងបដិវត្តន៍ អង្គការដឹងទាំងអស់ ហើយបើកាលណាអង្គការដឹងហើយ យើងនឹងត្រូវបានចោទថាខ្មាំង ហើយយកទៅសម្លាប់ចោល ។

## លួចផ្ទោះរបង

នៅឆ្នាំ១៩៧៨ ផលស្រូវបានល្អតែកន្លែងណាដែលមានដីខ្ពស់សម្រាប់ស្រែសន្ទូង កន្លែង ទំនាបទឹកអូសយកអស់ (រលួយខូច) ចំណែកដីទំនាបវិញ បានផលល្អសម្រាប់កន្លែងណាដែលគេធ្វើស្រូវពង្រោះព្រោះស្រូវបានពន្លឺងដើមមុនរដូវទឹកឡើង ។ ខ្មែរក្រហមទុកដីចោលទំនេរច្រើន ដោយសារការខ្វះមធ្យោបាយអូសទាញ និងកម្លាំងដកស្ទូង ព្រោះប្រជាជន ត្រូវស្លាប់ដោយជំងឺ និងការកាប់សម្លាប់អស់មួយចំនួនធំ ចំណែកអ្នកនៅរស់មានកម្លាំងខ្សោយដោយអាហារមិនគ្រប់គ្រាន់ ។

ដោយសារការស្រេកឃ្លាន ជារៀងរាល់យប់ ខ្ញុំលួចផ្ទោះ

របង ប្រមាថនឹងវិន័យអង្គការប្រដាប់ដោយសំណាញ់ចាស់ជាមួយមិត្ត ម៉ុន លួចទៅបង់ត្រីនៅវេលាយប់ស្ងាត់ស្ងើរវៀងរាល់យប់ ។ សំណាញ់មិត្ត ម៉ុន រហែករយ៉ៃ ប៉ុន្តែបង់បានត្រីច្រើន ពីព្រោះនៅជុំវិញព្រៃមាន់ សំបូរត្រីណាស់ ។ នៅពេលបង់ត្រីបាន យើងពុំមានអ្វីដាក់ យើងកាច់កត្រី រួចយើងរុំនឹងក្រមា ។ ចម្លែកណាស់នៅព្រៃមាន់ សូម្បីតែក្នុងស្រែក៏យើងប្រទះឃើញត្រីទន្លេ ដូចជា ត្រីស្លាតធំៗព្រមទាំង ត្រីកែស ដែលត្រីអស់នេះនៅកន្លែងដទៃ គេមិនឃើញមាននៅតាមស្រែព្រោះជាពពួកត្រីទន្លេ ។ ត្រីដែលបានមក យើងស្ងោរដោយគ្មានបង់ស្លឹកគ្រៃ មានអំបិលបន្តិចបន្តួចក៏នាំគ្នាហូប ជួនកាលទៀតក៏ដុត ហើយនាំគ្នាកាយចេញពីផេះទៅហូបនៅតាមផ្លូវទៅត្រពាំងទឹកខាងក្រោយភូមិ ។

ចំពោះកន្លែងបង់សំណាញ់វិញ យើងបានចេញពីភូមិដើរតាមផ្លូវជាតិមកខាងលិចភូមិប្រហែលមួយគីឡូម៉ែត្រ ដើម្បីកុំឲ្យគេដឹង ម្យ៉ាងទៀតមិត្ត ម៉ុន មានត្រចៀកថ្លង់យើងនិយាយជាមួយគាត់ត្រូវតែនិយាយឲ្យឮៗ នេះជាមូលហេតុដែលយើងត្រូវទៅឲ្យឆ្ងាយពីភូមិ ។ មិត្ត ម៉ុន ក្លាយជាជាងកាត់សក់នៅផ្សារដើមថ្កូវ នៅក្រោយថ្ងៃរំដោះ ៧ មករា ។

## លាក់ការណ៍សម្ងាត់

ការចេញទៅបង់ត្រីរាល់យប់ ហើយចេះតែបានសុខរហូត ពុំមាននរណាដឹងនោះ ធ្វើឲ្យយើងពិចារណាថា អង្គការភ្នែកម្នាស់ ធម្មតាផ្លែម្នាស់មានភ្នែកច្រើន ប៉ុន្តែពុំមានប្រស្រីដូចភ្នែកមនុស្សទេ ។ តាមពិតអង្គការដឹងថា អ្នកនេះឬអ្នកនោះធ្វើខុសដោយសារមានមនុស្សដែលប្រណែនគ្នា ឬមនុស្សដែលដឹង ឬឃើញសកម្មភាពអ្នកប្រព្រឹត្តទៅប្រាប់កម្មាភិបាលខ្មែរក្រហមទើបខ្មែរក្រហមដឹង តែបើអ្នក១៧មេសាចេះស្រឡាញ់គ្នាកុំយករឿងទៅប្រាប់ទេ នោះខ្មែរក្រហម ឬអង្គការ មិនដឹងឡើយ ។ នៅក្នុងក្រុមជាមួយគ្នា ខ្ញុំតែងតែនិយាយប្រាប់មិត្តក្នុងក្រុមថា សូមឯងកុំក្រឡាស់អណ្តាតរបស់ឯង រាយការណ៍អាក្រក់ពីអ្នក១៧ មេសា ដូចគ្នា ព្រោះទឹកមាត់ដ៏ស្អុយរបស់ឯងអាចធ្វើឲ្យជីវិតរបស់មនុស្សម្នាក់ស្លាប់បាន ងាយជាងជីវិតសត្វមាន់ទៅទៀត ។ ដោយយល់ និងមានធម៌សាមគ្គី មនុស្សនៅក្នុងក្រុមយើងបានរស់មកដល់សព្វថ្ងៃ សូម្បីអ្នកកម្ពុជាក្រោមពីរនាក់ខ្ញុំចេះតែប្រាប់ថា ឯងនិយាយមិនច្បាស់ គេកំពុងរកឃ្លូនឯងកុំខស្សព្វហ៍ឡើងមានយោបល់ប្រយ័ត្នបាត់ខ្លួន ។

នៅព្រៃមាន់នៅឆ្នាំ១៩៧៨ ដោយសារទឹកឡើងមានទំហំធំពេក ប្រជាជននៅតំបន់៥ជាប់នឹងមាត់ស្ទឹងមង្គលបូរី ដូចជាភូមិស្រមោច និងដូនប្រែង ជាដើម ត្រូវជម្លៀសមកភូមិព្រៃមាន់ ដោយបង្កើតជាសហករណ៍មួយដាច់ដោយឡែក ។ ប្រជាជនមកដល់ថ្មីនេះ ពុំមានអ្វីហូបសោះ កំពុងឈឺហើម ហើយព្រាត់ប្រាសបាត់ប្តីឬប្រពន្ធ កូននិងឪពុកម្តាយដោយជំងឺ ឬដោយខ្មែរក្រហមសម្លាប់ ។ ខ្ញុំនៅចាំបានថា ពេលនោះមានស្ត្រីម្នាក់ បានស្លាប់គួរឲ្យអាណិតអាសូរបំផុតនៅពេលសម្រាលកូនដែលខ្មែរយើងហៅថាក្រឡាភ្លើង ដោយពុំមានម្ហូបអាហារ និងថ្នាំសង្កូវ ។

## ប្រថុយជីវិតព្រោះនឹកបងប្អូន

នៅរដូវចូលឆ្នាំ១៩៧៨ ដោយសារតែនឹកបងប្អូននៅសហករណ៍នៅភូមិប៉ោយក្កៀង ខ្ញុំក៏បានសុំ អ៊ឹម៉ុង ទៅលេងភូមិ ខ្ញុំបានស្នើគាត់ពីរដងគាត់នៅតែមិនព្រមអនុញ្ញាតឲ្យខ្ញុំមក ប៉ុន្តែដោយសារនឹកបងប្អូនខ្លាំងពេក ខ្ញុំមកដោយចិត្តឯង ដោយដើរកាត់ពីព្រៃមាន់ ទៅភូមិអូរអណ្តូងជាភូមិដែលគេបោះបង់ចោលនៅកណ្តាលវាលស្រែ ដែលពុំមានមនុស្សម្នាដើរឆ្លងកាត់ លើកលែងតែរដូវដកស្ទូង និងច្រូតកាត់ប៉ុណ្ណោះ ។ ទៅដល់ភូមិអូរអណ្តូងយើងមើលឃើញភ្នំព្រះនេត្រព្រះយ៉ាងជិតបង្កើយ ដែលមានចម្ងាយផ្លូវប្រហែលប្រាំមួយគីឡូម៉ែត្រ ។ ខ្ញុំស្នាក់នៅភូមិប៉ោយក្កៀងដែលមានប្រធានភូមិឈ្មោះ ពុកឈួង ហើយភូមិប៉ោយក្កៀង និងភូមិដើងវត្ត ទាំងពីរភូមិនេះបង្កើតជាសហករណ៍តែមួយ ។ ក្រោយមក ពុកឈួង ត្រូវនារី និរតីឈ្មោះ សែ ចាប់យកទៅសម្លាប់ចោល ។ ខ្ញុំស្នាក់នៅភូមិអស់រយៈពេលបួនថ្ងៃទើបខ្ញុំត្រឡប់ទៅព្រៃមាន់វិញដោយពុំបានគិតទៅដល់ជីវិតទេ ព្រោះខ្ញុំយល់ថា តាម៉ុង ជួនកាលគាត់ដើរតួជាឪពុក ជួនកាលគាត់ដើរតួជាចៅហ្វាយនាយដ៏ល្អម្នាក់ច្រើនជាងតួនាទីជាកម្មាភិបាល ។

## ផ្លាស់ទៅកងថ្មី

ខ្ញុំបានចេញដំណើរពីភូមិប៉ោយក្កៀងនៅម៉ោងប្រហែល ៧ព្រឹកតាមផ្លូវកាត់ដដែល ខ្ញុំជៀសវាងធ្វើដំណើរតាមផ្លូវជាតិ ព្រោះវាឆ្ងាយ ហើយអាចជួបឧបសគ្គដូចជាគេសួររកសំបុត្រស្នាម ជាដើម ។ ខ្ញុំទៅដល់ព្រៃមាន់នៅម៉ោង១០ព្រឹក ពេលនោះ តាម៉ុង

និងប្រពន្ធនៅជុំគ្នា ពេលនោះខ្ញុំប្រាប់គាត់ថា ខ្ញុំមកវិញ តាម៉ុង សួរថា ហេតុអ្វីបានមិត្តឯងដើរសេរី ខ្ញុំក៏តបវិញថា ខ្ញុំបានសុំច្បាប់លោកពូ (ខ្ញុំប្រើពាក្យពូ) ចំនួនពីរដង លោកពូមិនព្រមឲ្យ ខ្ញុំនឹកបងប្អូនពេកក៏ដាច់ចិត្តទៅ ។ គ្រាន់តែនិយាយចប់ តាម៉ុង និយាយថាមិត្តឯងត្រូវរៀបចំខ្លួនឲ្យហើយ ថ្ងៃស្អែកមានអាត្រាក់ទៅស្ពានស្រែងមិត្តឯងត្រូវទៅជាមួយគេ ។

ក្រោយពីស្តាប់សម្តី តាម៉ុង ហើយ ខ្ញុំពុំមានការសោកស្តាយអ្វីពីកំហុស ឬឈឺចាប់ពីទណ្ឌកម្មអ្វីនោះឡើយ ពីព្រោះខ្ញុំគិតថា ខ្ញុំទៅឆ្ងាយរឹតតែធ្វើឲ្យខ្ញុំស្គាល់ភូមិសាស្ត្រតំបន់នេះកាន់តែច្រើន ។ វិសាលភាពខាងទឹកដី និងផលិតផលកសិកម្មជាពិសេសគឺអង្ករ និងក្រូចដ៏មានរស់ជាតិ ញ៉ាំងឲ្យខេត្តបាត់ដំបង ជាខេត្តមួយដ៏ល្បីឈ្មោះចាប់តាំងពីសម័យអាណានិគមមកម៉្លេះ ។ លើសពីនេះអ្វីដែលដក់នៅក្នុងអារម្មណ៍ខ្ញុំគឺការសិក្សារឿងប្រលោមលោកកាលពីនៅវ័យយុវជនគឺ ផ្កាស្រពោន និង កុលាបប៉ៃលិនរឹតតែធ្វើឲ្យខ្ញុំស្រឡាញ់ទឹកដីខេត្តបាត់ដំបង ជាងខេត្តណាៗទាំងអស់ ។ ជាមួយនឹងភាពផ្អែមល្ហែម បាត់ដំបងក៏មានរឿងជូរចត់ដែរ ។ បាត់ដំបងជាខេត្តស្ថិតនៅក្រោមអាណានិគមរបស់សៀម ។ បន្ទាប់មក ខ្ញុំក៏នឹកឃើញទៅដល់រឿងខទ្មាមកម្មនៅសំឡូតដែលជាប្រជ្រួលដ៏អាក្រក់បំផុតនៃកំណើតខ្មែរក្រហម នៅភ្នំវ៉ាយចាប ។

លុះស្អែក ឡើងវេលាម៉ោង៩ព្រឹក ខ្ញុំក៏ឡើងជិះលើរ៉ឺម៉កត្រាក់ទ័រឆ្ពោះទៅស្ពានស្រែងតាមផ្លូវក្រាលគ្រួសក្រហម ដោយឆ្លងកាត់តាមគបីដើម ទំនប់រំចេក ដែលនៅសងខាងផ្លូវលាតសន្ធឹងទៅដោយវាលស្រែពង្រោះដុតកន្ទុយក្អែក ពុំមានឃើញភូមិ ឬផ្ទះមានតែការដ្ឋានរបស់ខ្មែរក្រហមតែពីរបីប៉ុណ្ណោះ ។ លុះទៅដល់ភ្នំស្រុកយើងឃើញផ្ទះធំៗ មានទាំងផ្ទះកន្តាំង និងផ្ទះបុរាណនៅលាយឡំគ្នាតម្រៀបជាជួរនៅតាមផ្លូវខ្វាត់ខ្វែងហាក់ដូចជាទីក្រុងមួយដែលផុសចេញនៅកណ្តាលទីជនបទ ។ បន្ទាប់មក ត្រាក់ទ័រ ក៏បត់ទៅទិសខាងកើត ចាក់ទៅភូមិត្រពាំងប្រិយ, គោកសេះ សំដៅទៅស្ពានធំតាមបណ្តោយទំនប់ ទើបទៅដល់ភូមិរោគ ដែលនៅខាងស្តាំដៃជាកន្លែងដែលអគ្គភាពដាងបោះទីតាំងនៅចុងភូមិខាងកើត ក្រោមការក្តោបក្តាប់របស់មេកងឈ្មោះ ញាណ ផ្លាស់មកពីស្រុកថ្មពួក ។ ញាណ មានស្រុកកំណើតនៅខេត្តតាកែវ រាងទាបទ្រនាប់ សម្បុរសណ្តែកបាយ ច្រមុះកោងបន្តិច និយាយសម្តីមិនសូវច្បាស់ ។ ដាងនៅភូមិរោគ ចែកជាបីផ្នែកគឺ ដាងដែក ដាងបេតុង និងដាងឈើ (សម្រាប់រៀបពុម្ព) ដាងអស់ទាំងនេះគេយកទៅប្រើនៅពេលដែលចាប់សាងសង់ទ្វារទឹក ឬស្ពាន នៅពេលដែលទំនប់ថ្មីត្រូវគេកសាងឡើងដើម្បីធ្វើជាអាងស្តុកទឹក ដើម្បីបើកទឹកបញ្ចេញនៅពេលដែលគេខ្វះទឹកធ្វើស្រែនៅផ្នែកខាងក្រោម ។

## ទ្វារទឹកទំនប់

នៅរដូវដើមឆ្នាំ១៩៧៧ នៅពេលដែលកិច្ចការទំនប់ត្រូវបញ្ចប់នៅតំបន់៥ នៅមានការងារមួយទៀតដែលមិនទាន់ហើយគឺបញ្ហាទ្វារទឹកនៅតាមទំនប់នីមួយៗយ៉ាងហោចណាស់ក៏មានទ្វារទឹកចំនួនបីកន្លែងដែរ ដែលត្រូវធ្វើ ។ ទ្វារទឹកភាគច្រើនធ្វើមិនហើយដោយមិនបានចាក់ថ្មីម ឬចាក់ពិតានសម្រាប់ឲ្យអ្នកដំណើរងាយស្រួលក្នុងការឆ្លងកាត់ ។ ប៉ុល ពត ធ្វើទ្វារទឹកជាលក្ខណៈសន្សំសំចៃបំផុត កន្លែងខ្លះជាទំនាប ឬជាអូរគេមិនបានប្រើទ្វារទឹក តែបែជាចាក់ដីបំពេញវិញដូចជា នៅអូររន្ទះបាញ់ និងស្ពានស្រែងជាដើម ។ ភាគច្រើននៃទ្វារទឹកច្រើនតែធ្វើនៅទីខ្ពស់ទៅវិញ ។ កាលណាពិចារណាដល់រឿងនេះ ខ្ញុំនៅតែឆ្ងល់គិតមិនយល់ថា ប៉ុល ពត ធ្វើស្ពានដើម្បីអ្វី បើមនុស្សធ្វើដំណើរទៅមកតាមទំនប់ពិបាកព្រោះដីស្អិតនៅរដូវវស្សា លុះទៅដល់ស្ពានត្រូវឆ្លងមិនរួចព្រោះឥតពិតាន ហើយទោះបីចង់វាង ក៏វាងមិនរួចទៀត ព្រោះខាងក្រោមមានទឹកជ្រៅ ។

នៅរដូវវស្សា ទឹកពេញប្រៀបក្នុងអាង ខ្មែរក្រហមតែងតែបញ្ជាឲ្យបើកទឹកចោល ព្រោះខ្លាចបាក់ទំនប់ ។ នៅពេលដែលបើកទឹកចោលនោះហើយ ខ្សែទឹកបុកខ្លាំងធ្វើឲ្យញ័ររញ្ជួយសសរជួរមុខដែលមានរាងដូចមុខកប៉ាល់ មួយដើមៗមានទំហំបួន៤តឹកបួនជ្រុង ។ ធារទឹកដែលធ្លាក់ពីព្រៃជួរភ្នំដងរែក បានហូរសម្រុកតាមច្រកស្ពានដែលមានមុខតែប្រាំបីម៉ែត្រ មានកម្ពស់ទឹករហូតដល់បួនម៉ែត្រ ពេលដែលទឹកកំពុងហូរនោះ បើសិនយើងយកដៃទៅស្ទាបក្បាលសសរស្ពានដែលផុតពីទឹកប្រហែលពីរតឹក យើងអាចដឹងថា សសរនៅចំកណ្តាលប៉ុន្មានដើមនោះកំពុងតែញ័រ ហើយឡើងក្តៅខណ្ឌៗ ហាក់ដូចជាមិនអាចទប់នឹងកម្លាំងទឹកបានឡើយ ។

## រដូវទឹកឡើង

ខ្ញុំនៅចាំថា នៅពេលដែលរដូវទឹកជន់ពួកជាងអស់ការងារធ្វើ យើងនាំគ្នាអង្គុយមើលខ្សែទឹកទាំងភ័យខ្លាច ព្រោះកាលណាបាក់ទំនប់យើងច្បាស់ត្រូវស្លាប់ដោយលង់ទឹក ព្រោះនៅម្តុំជិតនោះ ពុំមានដីទួលណាដែលអាចពុំនាក់អាស្រ័យបាន ពេលនោះធារទឹកល្ហូល្ហេវដាច់កន្ទុយភ្នែកស្ទើរតែក្លាយជាសមុទ្រ មានតែដើមត្នោតដែលអាចឈរបង្អួតនៅកណ្តាលទឹកបាន ក្រៅពីនោះ ព្រៃកម្ពោធដែលខ្ពស់ៗ ឃើញតែចុងរលាបនៅប៉ប្រះទឹក ។ កម្លាំងទឹកហូរចោលទៅឆ្ងាយ បង្កើតបានជាខ្សែទឹកវិលសងត្រឡប់ថយក្រោយជារង្វង់ជាគូថខ្យងនៅចំកណ្តាល ប្រៀបដូចទៅនឹងទឹកទន្លេមេគង្គនៅចំពីមុខភូមិ ផាឡាបរិវ៉ាត់ ដែរ ។ ពេលយើងកំពុងអង្គុយឱនមើលខ្សែទឹក ស្រាប់តែហ្វូងត្រីសណ្តាយបោះពួយពីលើក្បាលយើង ទាំងហែលបណ្តោយខ្លួន បោះពួយទម្លាក់ខ្លួនតាមខ្សែទឹកហូរយើងបានគ្រាន់តែល្អមើលហើយនឹកស្តាយ ព្រោះគ្រាន់តែឃើញមិនបានហូប ។ កន្លះខែគត់ដែលយើងជាប់នៅលើទំនប់ពុំមានអ្វីហូប អង្ករត្រូវផ្តាច់ សូម្បីតែដំឡូងមីមួយមើមក៏គ្មានផង យើងនាំគ្នាប្រថុយប្រថានយកទូកតូចមួយឆ្លងទៅមាត់ស្ទឹងស្ពានស្រែង ដោយសម្លឹងឃើញដើមចេក ក៏នាំគ្នាកាប់គល់ចេកមកចិតជាបន្ទះៗព្រមទាំងកាច់ខសដូចជា មែកត្របែក ឬកន្ទួតមក ធ្វើជាអុសសោរឬដុតគល់ចេក ។ ពេលហូបចូលដល់ពោះពេលណា យើងក៏រមួលពោះដេកមិនលក់ ចេញចូលស្តោះទឹកមាត់ពុំដាច់ ។

## ហ្វូងត្រីផ្ទោង

លុះព្រឹកឡើង យើងបានចាត់ឲ្យមិត្តម្នាក់ដែលស្គាល់អ្នកភូមិរោគឲ្យទៅសុំអំបិលព្រោះយើងគិតថា រមួលពោះបណ្តាលមកពីយើងហូបគល់ចេកពុំមានអំបិល ។ ព្រឹកនោះថ្ងៃរះល្អ ហើយមានជំនោរខ្យល់បក់មកត្រសៀកៗ នេះជាដំណឹងនៃរដូវកក្តិកនឹងមកដល់នៅពេលឆាប់ៗខាងមុខនេះ ពេលនោះ ទឹកស្រកបន្តិចយើងឃើញហ្វូងត្រីផ្ទោងហែលរេរា បញ្ចេញខ្នង និងជំពុះ ទាំងហ្វូងៗនៅមុខទ្វារទឹក ។ ពេលនោះ យើងមានអារម្មណ៍អផងព្រួយផង ព្រោះយើងគិតថានឹងស្លាប់ដោយសារដាច់ពោះមិនខាន ប៉ុន្តែឥឡូវទេព្តាហាក់ជាជួយយើងឲ្យមានជីវិតឡើងវិញហើយ ។

យើងក៏នាំគ្នាយកបង្កី ស្រាយខ្សែចេញធ្វើជាឈ្នាងចូកពីលើទ្វារទឹកយ៉ាងរហ័ស ដើម្បីកុំឲ្យត្រីលិចទៅក្នុងទឹកទាន់ ។ មិត្តយើងយកបង្កីពីរចូកជំណាលគ្នា ដោយក្នុងមួយបង្កីរយើងចូកបានត្រីផ្ទោងប្រហែលជិតកន្លះគីឡូក្រាម ប៉ុន្តែដោយអំណាចឃ្លាន យើងចង់បានឲ្យច្រើនជាងនេះ ។ យើងអង្គុយមួយស្របក់ធំ ទើបត្រីងើបឡើងម្តងទៀតព្រោះវាផ្អើល លើកនេះយើងជញ្ជាត់មួយឈ្នាងបានតែត្រីពីរឬបីប៉ុណ្ណោះ ។ យ៉ាងហោចណាស់ យើងក៏បានត្រីប្រហែល២គីឡូដែរ យកមកស្ងោរនឹងឆ្នាំងចាស់មួយគ្មានគំរបរួចបង់អំបិលគ្រួសចូលប្រហែល៤-១០គ្រាប់ លុះឆ្អិនហើយយើងក៏លើកចុះមក នាំគ្នាអង្គុយព័ទ្ធវង់ ហើយហូបសម្លដោយពុំមានបាយ ។ ទោះជាយ៉ាងណានៅពេល នោះពេលហូបសម្លរួចយើងហាក់ដូចជាមានកម្លាំងព្រើស មិនសូវស្រវាំងភ្នែក និងហឹងត្រចៀកដែលបណ្តាលមកពីជំងឺខ្វះជីវជាតិដូចពេលមុន ។ ពេលនោះ យើងហាក់ដូចជារស់នៅកណ្តាលកោះមួយដែលពុំមានមនុស្សទៅដល់ គេទុកពួកយើងឲ្យស្លាប់ដោយអត់បាយឬលង់ទឹក ។

## ចង្វាក់មរណៈ

នៅចុងឆ្នាំ១៩៧៨ ប្រជាជនទាំងថ្មីទាំងចាស់នៅភូមិស្ពានស្រែងត្រូវដាច់បាយ ហើយកើតជំងឺហើម ក្នុងមួយថ្ងៃមានប្រជាជនស្លាប់គួរឲ្យអណោចអធម ។ ជួនកាលតាចាស់ធ្វើបង្កីកំពុងតែអង្គុយធ្វើបង្កីរំពាក់ ស្រាប់តែប្រកាច់ដួលតូងដាច់ខ្យល់ស្លាប់មួយរំពេច មានខ្លះទៀតពីព្រឹកដើរបេះបោចបន្លែព្រៃ លុះដល់ថ្ងៃបន្តិចក៏ដាច់ខ្យល់ស្លាប់ព្រមៗគ្នា ។

នៅសម័យ ប៉ុល ពត គេចំណាំមើលអ្នកកើតជំងឺហើមច្រើនតែហើមចាប់ពីខ្នងជើងទៅមុន រួចបានចាប់ហើមមុខ ក្រោយមកអ្នកជំងឺហើមនោះមានអាការហត់ ដកដង្ហើមញាប់ ជួនកាលមានទាំងក្អកថែមទៀត ។ មនុស្សស្លាប់ច្រើននៅពេលយប់ រហូតដល់ម៉ោង១០ព្រឹក ទើបអ្នកសែងខ្មោចចាប់ ផ្តើមដើរត្រួតពិនិត្យហើយរាប់ចំនួនឲ្យដឹងច្បាស់ដើម្បីរាយការណ៍ប្រាប់ប្រធានភូមិមុននឹងប្រមូលសែងខ្មោចទៅកប់ដោយដាក់លើចង្អេរមួយត្បាញពីឫស្សីដែលគេហៅថា ទ្រាស ។ អ្នកកប់ខ្មោចមានគ្នា៦នាក់ ដោយបួននាក់ ជាអ្នកសែង និងពីរនាក់ផ្សេងទៀតជាអ្នកជីករណ្តៅ ។ ទោះបីជាប្រធានសហករណ៍បញ្ជាឲ្យកាប់រណ្តៅឲ្យបានជ្រៅយ៉ាងណាក៏ដោយ ក៏គេនៅតែពិបាកនឹងសម្រេចបានតាមជម្រៅដែលគេចង់បាន ព្រោះពុំមានកម្លាំងនឹងកាប់ ។ របបហូប បបរមួយវែក

មានគ្រាប់អង្ករប្រហែល៨ទៅ១០គ្រាប់ ។ ពេលបើករបបបបរពីសហករណ៍មក យើងមិនទាន់ហូបទេ គឺយើងត្រូវដើរបេះស្លឹកឈើព្រៃមកលាយជាមួយរួចហើយទើបដាក់បបរម្តងទៀតដើម្បីឲ្យបានច្រើន ហូបឲ្យបានតឹងពោះ ។

ទោះបីជាមនុស្សស្លាប់ច្រើនយ៉ាងនេះក៏ដោយ ក៏បបរនៅតែរាវដដែលមិនដែលស្គាល់ពាក្យថាបាយម្តងណាឡើយ ។ គេបានហូបបាយនៅរដូវច្រូតកាត់ប្រហែលរយៈពេល២០ថ្ងៃប៉ុណ្ណោះ រួចចុះមក បបរប៉ាក់ ឬបបរខាប់ ប្រហែល៤-១០ថ្ងៃ។ នេះហើយដែលអ្នកភូមិលើកដៃបែរបន់ថា សូមឲ្យនៅត្រឹមបបរប៉ាក់កុំឲ្យដល់បបររាវ ខ្ញុំរាងចាលហើយ វាធ្វើឲ្យហេវណាស់ ឃ្លានណាស់! សូមទេព្តា ជួយផង! ប៉ុន្តែខួបនៃរបបរាវ បានវិលមកដល់ចំរដូវវស្សាវិញដដែល នៅពេលការងារដកស្ទូង ត្រូវបង្ខំឲ្យសម្រុកតាមទិសអង្គការ ។ គ្មាននរណាបានដឹងថា ប៉ុល ពត ដោះដូរជាមួយចិនដើម្បីយកគ្រឿងចក្រកសិកម្ម ឬសម្ភារយោធាក្នុងមួយឆ្នាំៗ បើគិតជាស្រូវប៉ុន្មានលានតោនទេ បានជានៅរដូវបោកបែនយើងឃើញឡានចិនពណ៌ត្រីអីបើកស្វែងស្វាត់ពីភូមិមួយទៅភូមិមួយ ដឹកជញ្ជូនស្រូវគ្មានសល់មួយគ្រាប់ឡើយ ។ នៅរដូវអត់ ទើបប្រធានសហករណ៍ដើរស្នើពីកន្លែងផ្សេងមកបបរ ។ មានពេលខ្លះម៉ោង១១ ឬ១២ ទៅហើយ មើលទៅរោងចុងភៅមិនទាន់មានផ្សែងចង្ក្រានហុយនៅឡើយ ព្រោះតែមិនទាន់មានអង្ករ នេះជាលក្ខណៈទូទៅនៅតាមសហករណ៍ទូទាំងពេញតំបន់៥ ។

## ស្លាប់ដោយអត់អាហារ

នៅពេលថ្ងៃខ្ពស់ណាស់ទៅហើយជិតដល់ម៉ោងបបរ អ្នកសែងខ្មោចដើរប្រមូលខ្មោចយកទៅកប់ ព្រោះគេគិតតាមចំណាំកាលណាទុកឲ្យថ្ងៃខ្ពស់នោះ គេមិនពិបាកដើរប្រមូលតគាក់តគុប ព្រោះកាលណាថ្ងៃរះខ្ពស់ ចាប់ពីម៉ោង១០ទៅ មិនសូវមានស្លាប់ច្រើនដូចពេលព្រឹក ទើបគេចាប់ផ្តើមប្រមូលខ្មោចយកទៅកប់ ។ គេដើរជញ្ជូនម្តងមួយៗ លុះគ្រាតែអស់ ជួនកាលក្នុងមួយព្រឹកមានរហូតដល់១០នាក់ ។ អ្នកស្លាប់នៅពេលនោះ ភាគច្រើនជាស្ត្រី ព្រោះបុរសភាគច្រើនបានស្លាប់អស់ទៅហើយដោយសារមិនអាចទ្រាំទ្រនឹងរបបអាហារមិនគ្រប់គ្រាន់ និងដោយសារអង្គការចោទប្រកាន់ពីកំហុសបន្តិចបន្តួចដោយមិនសូវមានការលើកលែងដូចស្ត្រី ។ ចំណែកអ្នកដែលស្លាប់ពីឆ្នាំ១៩៧៧ ទៅឆ្នាំ១៩៧៨ ភាគច្រើនក៏មិនសូវមានក្មេងដែរ ព្រោះក្មេងៗភាគច្រើនបានស្លាប់ដោយសារការអត់ឃ្លាន ឬមិនមានទឹកដោះម្តាយបៅ ដោយសារម្តាយស្លាប់ចោលបាត់ទៅហើយ ។ គ្រាន់តែខ្មោច៤-១០នាក់ត្រូវប្រើពេលដល់ទៅពីរឬបីម៉ោង ព្រោះក្រុមគាត់គ្មានកម្លាំងសែង ហើយជើងនិងដៃគាត់ចេញសរសៃរវាម ឃើញតែឆ្អឹង និងដំណើរដើរពាន់ជើង ទំរាំយកខ្មោចចេញផុតពីភូមិ ត្រូវឈប់ប្រហែលប្រាំមួយទៅប្រាំពីរដង លុះទៅដល់មាត់រណ្តៅក៏ទម្លាក់សាកសព ហើយអង្គុយដង្ហក់មួយសន្ទុះទើបនាំគ្នាទៅយកសាកសពមកទៀត ។ ទីបំផុត អ្នកកប់ខ្មោចត្រូវគេយកទៅកប់ដូចតែគ្នា ។

នៅពេលនោះ ចំនួនប្រជាជននៅតាមសហករណ៍កាន់តែខ្សោយៗទៅ នៅសល់តែពួកឈ្លប និងក្រុមគ្រួសារប្រធានភូមិ និងបងប្អូនសាច់ញាតិរបស់គេ ព្រោះគេបានកេងប្រវ័ញ្ចរបបសហករណ៍ដើម្បីដាំបាយហូបជារៀងរាល់ពេល ពួកគេមានសាច់ឈាមល្អកម្លាំងពលំមាំមួន ប៉ុន្តែមិនដែលទៅធ្វើការតាមមុខព្រួញណាមួយទេ ពេលខ្លះគេមើលពុកម៉ែដកស្ទូង ប៉ុន្តែសម្លៀកបំពាក់ខ្មៅក្រិប មិនឃើញប្រឡាក់ភក់ ព្រោះគេឈរបញ្ជាតែពីលើភ្លឺស្រែ ។

## ទឹកជន់លិចស្រូវ

នៅរដូវច្រូតឆ្នាំ១៩៧៨ ប្រជាជននៅក្នុងសហករណ៍ដែលមួយភូមិមានគ្នាប្រហែលពី២៥-៣០នាក់ ។ នៅសហករណ៍ភ្នំស្រុកត្រូវគេជម្លៀសឲ្យចេញក្រៅភូមិ ដោយមានបង្ហេចនៅដេកហាលវាល ខាងក្រៅភូមិតាមដួរព្រៃប្រហែលបីគីឡូពីភូមិ ។ នៅពេលដែលសួរថា ហេតុអ្វីបានជាមិត្តដេកនៅក្រៅភូមិ គាត់ឆ្លើយថាអង្គការឲ្យគាត់មកទីនោះដើម្បីជីកស្រះ និងច្រូតស្រូវ ។ នៅរដូវវស្សាឆ្នាំ១៩៧៨ ពេលដែលសន្ទូងកំពុងបែកគុម្ព និងស្រូវពង្រោះកំពុងពេញល្អ ស្រាប់តែមានទឹកជំនន់អាក្រក់ក្រៃ ធ្វើឲ្យសន្ទូងរលួយខ្ទេចខ្ទី ទឹកលិចយូរពេកសន្ទូងស្អុយដើមក៏ខូចអស់ទៅ ។ នៅកន្លែងខ្លះជាស្រែខ្ពស់ សន្ទូងដែលនៅសល់ពីទឹកអូស ខំប្រឹងយ៉ាងត្រដាបត្រដួសបញ្ចេញខ្នែងទាំងអស់សង្ឃឹមបង្កើតបានដើមស្រូវឆ្នាៗ ដូចសរសៃអំបោះ មានផ្លែគួខ្ទីៗត្រង់នេះមួយសរសៃ ត្រង់នោះមួយសរសៃដែលមើលគួរឲ្យធុញ និងអស់សង្ឃឹមពីទិន្នផលដ៏ខ្សត់ខ្សោយ ធៀបទៅនឹងការអត់ឃ្លានដែលអូសបន្លាយ

តាំងពីឆ្នាំ១៩៧៥ មកដល់ឆ្នាំ១៩៧៨ ពិតជាមានទំហំធំធេងណាស់ វាបានយកជីវិតមនុស្សរាប់សែននាក់ទៅហើយ ។

ប៉ុន្តែ តាមការពិត ប៉ុល ពត មានគម្រោងជម្លៀសប្រជាជននៅក្នុងតំបន់៥ ឡើងទៅភ្នំកូនខ្វែង មុននឹងទៅដល់ជួរភ្នំដងរែកដែលជាជម្រកចុងក្រោយបន្ទាប់ពីបរាជ័យចំពោះការវាយលុករបស់កងទ័ពវៀតណាម ។ ខ្ញុំចេះតែឆ្ងល់ទៀតថា ហេតុអ្វីនៅក្នុងចំណោមអ្នកដែលអង្គុយនៅក្បែរព្រៃទាំងនោះ មិនឃើញមានឈ្លបឬប្រធានសហករណ៍? ព្រោះកងឈ្លបនិងប្រធានសហករណ៍នៅឯភូមិខំប្រឹងរៀបចំរទេះ ប្រមូលអង្ករ ដែលគេលាក់ទុក ឬស្រូវជង្រុកសម្រាប់ទុកធ្វើជាស្បៀងនៅតាមផ្លូវនាំគ្នាគិតចាប់មាន់ទាលើកពាងស្កររៀបចំដាក់រទេះ ស្រេចបាច់ហើយក៏កាប់មាន់ទា និងជ្រូកខ្លះហើយ ហូបត្រហេបត្រហប រួចបររទេះចេញ ។ ប្រជាជនខ្លះឆ្ងល់សួរថា តើមិត្តទៅណា? គេក៏ឆ្លើយថា ទៅមុខព្រួញថ្មី មានអ្នកខ្លះសុំគេទៅ ខ្មែរក្រហមឆ្លើយថា កុំទៅអីមិត្តនៅទីនេះសប្បាយជាង ។

## ព័ត៌មានគួរឲ្យសង្ស័យ

ដំណឹងពីកងទ័ពវៀតណាមចូលមក គ្មាននរណាដឹងទាំងអស់ ស្រាប់តែព្រឹកមួយដែលខ្ញុំ និង អង្គភាពជាងមួយចំនួនកំពុងធ្វើការនៅលើទំនប់ត្រង់នេះមួយក្រុម ត្រង់នោះមួយក្រុម នៅខាងកើតមន្ទីរសេដ្ឋកិច្ចស្ពានធំ ដើម្បីជួសជុលទំនប់ដែលត្រូវខូចខាតដោយសារទឹកភ្លៀងហូរច្រោះ ។ នៅវេលាម៉ោង ប្រហែល៨ព្រឹក យើងឮសូរកាំភ្លើងធំ និងកាំភ្លើងដៃ លាន់ដូចលាចផ្ទុះនៅម្តុំកំពង់ថ្កូវ ខ្ញុំនឹកក្នុងចិត្តថា ប្រហែលយោធាខ្មែរក្រហមទំនាស់គ្នាហើយ ព្រោះខ្ញុំយល់ថាគ្មាននរណាធ្វើអ្វីខ្មែរក្រហមកើតទេនៅកណ្តាលប្រទេសបែបនេះ ។

នៅវេលាម៉ោង១០ព្រឹក ស្រាប់តែមានមានយុវជនពាក់អាវខ្មៅ បង់កក្រមា ដើរយ៉ាងលឿនតាមបណ្តោយទំនប់ ពីទិសខាងសៀមរាប សំដៅទៅភ្នំស្រុក ។ ពេលដើរមកដល់កន្លែងដែលយើងកំពុងធ្វើការ ដែលរួមមានទាំងកម្មាភិបាលខ្មែរក្រហមកំពុងឈរនៅទីនោះដែរ បានឮយុវជននោះស្រែកខ្លាំងៗថា “ពួកយួនចូលមកច្រើនណាស់ មានទាំងកងរថក្រោះផង ពេលប្រយុទ្ធគ្នានៅផ្សារកំពង់ថ្កូវ ពួកយួនបាញ់ឡានដឹកគ្រាប់យើងឆេះជាច្រើនគ្រឿង ចំណែកខ្ញុំបានលោតចុះពីលើឡានធ្លាក់ទឹក រួចរត់គេចខ្លួនចេញ ឥឡូវយើងបាក់ទ័ពហើយ” ។ យុវជននោះបានសួរមកយើងវិញថា ផ្លូវណាទៅខេត្តឧត្តរមានជ័យ? ពេលនោះ កងចល័តគ្រាន់តែស្តាប់ហើយ ឈរស្រឡាំងកាំង ចំណែកកម្មាភិបាលខ្មែរក្រហមក្រោយពីស្តាប់ឮហើយ ធ្វើប៉ុកដូចជាធម្មតា មិនខ្វល់ពីដំណឹងនោះទេ ។ ពេលនោះ ខ្ញុំនឹកក្នុងចិត្តថា ម្តេចក៏មិត្តនោះហ៊ាននិយាយរឿងខ្មែរក្រហមមិនខ្លាចស្លាប់ដូច្នេះ គ្រាន់តែនិយាយចប់ យុវជននោះក៏ធ្វើដំណើរទៅមុខសំដៅភ្នំស្រុកបាត់ ។ ខ្ញុំយល់ថា រឿងនេះប្រហែលខ្មែរក្រហមដឹងឮស្នុះសាយអស់ទៅហើយទើបមិនមាត់មិនកដូច្នេះ ។

## សេរីភាពវិលមក

ខ្ញុំបានរួចពីនរកលោកិយ ហើយសេរីភាពក៏កើតមានឡើងវិញបន្ទាប់ពីរស់នៅក្នុងរបបទាសភាព អស់រយៈពេលជិតបួនឆ្នាំ ព្រោះពេលនោះពួកក្អែកទឹកបានរត់ចោលយើងអស់ហើយ ។ គ្រាន់តែទទួលដំណឹងនេះភ្លាម ពួកអ្នក១៧ មេសា ដែលនៅតាមសហករណ៍ ភ្នំស្រុកបានចាត់គ្នាទៅពិនិត្យសភាពការណ៍ដើម្បីឲ្យដឹងច្បាស់ថាតើទ័ពយួនកំពុងចូលមកតាមផ្លូវជាតិពិតប្រាកដមែន ឬយ៉ាងណា? លុះត្រឡប់មកវិញ ពួកគេបាននិយាយថា ឃើញអ្នកភូមិឆ្ងាយៗ ដែលរស់នៅតំបន់ដាច់ស្រយាលពីផ្លូវជាតិ បាននាំគ្នាអូសរទេះ ឬរែកឥវ៉ាន់តម្រង់ទៅផ្លូវជាតិដើម្បីវិលត្រឡប់ទៅស្រុកកំណើតវិញយ៉ាងកុះករ ។ ប៉ុន្តែការធ្វើដំណើររបស់ប្រជាជនទាំងនោះមិនបានទៅតាមទិសដៅភ្លាមទេ គឺនៅរង់ចាំស្តាប់ដំណឹងបងប្អូនដែលរស់នៅភូមិខុសគ្នានៅពេលជម្លៀសដោយសួរដំណឹងតាមអ្នកភូមិ រួចចាត់គ្នាឲ្យតាមរកបងប្អូនឲ្យបានជុំគ្នាទើបធ្វើដំណើរទៅមុខ ។ គួរឲ្យអាសូរដល់អ្នក ១៧ មេសា កាលមកមានគ្នាច្រើន ដល់ទៅវិញមានគ្នាតិច បងប្អូនឪពុកម្តាយដែលមកជាមួយគ្នា ឥឡូវបាត់បង់យកឆ្អឹងមកចោលស្រុកគេ បងប្អូនជាទីស្រឡាញ់ត្រូវបែកគ្នាអស់បែកជារៀងរហូតគ្មានថ្ងៃត្រឡប់វិញ ហើយអ្នកនៅរស់បានសច្ចាថា ពេលទៅដល់ស្រុកកំណើតនិងធ្វើបុណ្យឧទ្ទិសកុសលដើម្បីឲ្យវិញ្ញាណក្ខន្ធអ្នកទាំងនោះបានស្ងប់ ។

**(នៅមានត)**

**ស៊ីវ ធួន**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម




មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។




***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ៈ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាសយដ្ឋាន) ។




***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 155, November 2012 ◆ Funded by USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.